# ព្រឹត្តិបត្រ

# កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

លេខ ៥ | ឆ្នាំ ២០១៨



# បុព្វកថា

គិតចាប់ពីជំហានដំបូងនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ យើងទាំងអស់គ្នាបានឆ្លងកាត់នូវរឿងរ៉ាវជាច្រើន សប្បាយផង, បារម្ភផង, ជូរចត់ផង ប៉ុន្តែដោយហេតុតែស្មារតី និងឆន្ទៈដ៏មោះមុតឥតងឿយហត់ ជាមួយនឹងអភិក្រម "**រៀនផង ធ្វើផង**" និងមានការជំរុញគាំទ្រយ៉ាងខ្លាំងក្លាពី **អគ្គមហារដ្ឋបុរស** គឺ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានធ្វើឱ្យអំរែកដ៏ធ្ងន់នេះ មានភាពធូរស្រាលបន្តិចម្តងៗ ហើយនៅទីបំផុត យើងសម្រេចបាននូវសមិទ្ធផលផ្លែផ្កាជាច្រើនគួរជាទីមោទនៈ ដែលបានរួមចំណែកសម្រេចនូវគោលបំណងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ។ ហេតុនេះហើយ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងនៅតែបន្តជាអាទិភាពមួយនៃរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមអភិក្រមជាខឿន បានបោះជំហានពីមួយដំណាក់កាលទៅមួយដំណាក់កាល និងជាជំហានៗ ជាមួយនឹងភាពជោគជ័យជាបន្តបន្ទាប់ ដោយបច្ចុប្បន្ន យើងបានឈានមកដល់ដំណាក់កាលទី៣ ដែលកំពុងផ្តោតសំខាន់លើ "**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**"។ ជាមួយនឹងចក្ខុវិស័យច្បាស់លាស់ និងប្រាកដប្រជា, កម្ពុជាបាននិងកំពុងប្រែក្លាយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលផ្តោតលើធាតុចូល និងមជ្ឈការ ទៅជាប្រព័ន្ធដែលផ្តោតលើលទ្ធផល និងវិមជ្ឈការ ស្របតាមស្តង់ដារអន្តរជាតិ។ បន្ថែមពីនេះ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០១៨-២០២៥ ដែលទើបទទួលបានការអនុម័តក្នុងសម័យប្រជុំគណៈរដ្ឋមន្ត្រីកាលពីខែមករា ឆ្នាំ២០១៨ ក៏បានដាក់ឱ្យអនុវត្តក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** កាលពីខែមេសា ឆ្នាំ២០១៨ កន្លងទៅ។

ក្នុងបរិការណ៍សេដ្ឋកិច្ចកំពុងមានការរីកចម្រើន, កម្មវិធីកែទម្រង់ក៏បានចូលរួមជំរុញកំណើនសេដ្ឋកិច្ចឱ្យសម្រេចបានជាមធ្យមក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ ប្រកបដោយសមធម៌, បរិយាប័ន្ន និងធន់នឹងវិបត្តិ ដែលរឹតតែធ្វើឱ្យកម្រិតជីវភាពប្រជាពលរដ្ឋកាន់តែប្រសើរឡើង។ លើសពីនេះ, ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ, ចំណូលចរន្តថវិការដ្ឋបានកើនទ្វេដង, ការអនុវត្តចំណាយកាន់តែខិតទៅជិតគោលដៅនៃច្បាប់ថវិកា ដែលបានជំរុញឱ្យមានអតិរេកសាច់ប្រាក់ និងកាត់បន្ថយឱនភាពសរុប ព្រមទាំងធានាមិនឱ្យមានបំណុលកកស្ទះដ៏រាំរ៉ៃ, និងបំណុលសាធារណៈ ក៏ត្រូវបានគ្រប់គ្រងយ៉ាងត្រឹមត្រូវ។ កត្តាទាំងអស់នេះ បានធានាថា ភាពទុកចិត្តនៃថវិកា កាន់តែប្រសើរឡើង ហើយជាពិសេសបានផ្តល់លទ្ធភាពឱ្យរាជរដ្ឋាភិបាលក្នុងការដំឡើងបៀវត្សរ៍ជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ ថែមទៀតផង។ ដោយឡែក គណនេយ្យភាពហិរញ្ញវត្ថុក៏ត្រូវបានធានាផងដែរ តាមរយៈការឆ្លុះបញ្ចាំងពីភាពបុរេសកម្មការងារជាពិសេសការរៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមបែបព័ត៌មានវិទ្យា (ដែលហៅកាត់ថា FMIS), ការពង្រឹងមុខងារសវនកម្មផ្ទៃក្នុងតាមក្រសួង- ស្ថាប័ន, ព្រមទាំងការរៀបចំ កែលម្អ និងការពង្រឹងច្បាប់និងបទបញ្ញត្តិគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តថវិកា។ ជាការគួរឱ្យកត់សម្គាល់, ក្នុងពេលថ្មីៗនេះ, របាយការណ៍អង្កេតតម្លាភាពថវិកាអន្តរជាតិបានវាយតម្លៃថា តម្លាភាពថវិកានៅកម្ពុជា មានវឌ្ឍនភាពល្អប្រសើរក្នុងឆ្នាំ២០១៧ បើធៀបនឹងឆ្នាំ២០១៥ កន្លងទៅ។ រីឯការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ក្នុងដំណាក់កាលទី៣ នេះ, គ្រប់ក្រសួង- ស្ថាប័ន បាននិងកំពុងអនុវត្តពេញលេញនូវថវិកាកម្មវិធី ទន្ទឹមគ្នាជាមួយនឹងការកែសម្រួលរចនាសម្ព័ន្ធគោលនយោបាយ, ផែនការយុទ្ធសាស្ត្រថវិកា, និងក្របខ័ណ្ឌគតិយុត្តនានា សម្រាប់ការអនុវត្តថវិកាកម្មវិធី។ លើសពីនេះទៀត, យន្តការអង្គភាពថវិកាដើម្បីជំរុញតម្លាភាព, គណនេយ្យភាព, ការផ្ទេរសិទ្ធអំណាច, ការទទួលខុសត្រូវ និងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ក៏ត្រូវបានរៀបចំ និងពង្រឹងជាបន្តបន្ទាប់។

ជាការពិត, ក្នុងរយៈពេល ២០ ឆ្នាំចុងក្រោយ, កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ ជាពិសេសក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយនេះ ដោយជាមធ្យមស្ថិតក្នុងរង្វង់ ៧%។ កំណើននេះ ត្រូវបានទទួលស្គាល់ និងវាយតម្លៃខ្ពស់ដោយស្ថាប័នអន្តរជាតិ ថាជាកំណើនដែលពុំធ្លាប់មានពីមុនមកក្នុងចំណោមបណ្តាប្រទេសក្នុងតំបន់។ ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨, ការកែលម្អរដ្ឋបាលសារពើពន្ធ និងការធ្វើទំនើបកម្មប្រព័ន្ធពន្ធដារ ដែលបង្កភាពងាយស្រួលក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ, ការវិភាជថវិកាកាន់តែចំគោលដៅអាទិភាព និងមានប្រសិទ្ធភាពខ្ពស់ជាងមុន, ព្រមទាំងការអនុវត្តនូវថវិកាកម្មវិធី គឺជាកត្តាជំរុញដ៏សំខាន់ក្នុងការសម្រេចបាននូវសមិទ្ធផលខាងលើ។ ម៉្យាងវិញទៀត, កម្មវិធីកែទម្រង់នេះ បានបង្កើតឱកាសជំរុញឱ្យគ្រប់ក្រសួង

ស្ថាប័ន ពង្រឹងការផ្តល់សេវាសាធារណៈ ឱ្យកាន់តែងាយស្រួល, តម្លាភាព, អាចជឿទុកចិត្តបាន, ឆាប់រហ័ស និងមានប្រសិទ្ធភាពសម្រាប់អ្នកប្រើប្រាស់សេវា ព្រមទាំងបានរួមចំណែកកសាងអភិបាលកិច្ចល្អនៅតាមស្ថាប័ននីមួយៗ ដែលជាចំណុចស្នូលនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។

ជារួម ដោយសារការប្រតិបត្តិឥតរួញរាក្រោមការចង្អុលបង្ហាញរបស់ប្រមុខរាជរដ្ឋាភិបាល, ការបង្កើតបាននូវសមិទ្ធផលដ៏ធំធេងទាំងនេះបានក្លាយជាមូលដ្ឋានគ្រឹះក្នុងការកសាងនូវទំនុកចិត្តកាន់តែខ្លាំងឡើងក្នុងចំណោមមន្ត្រីរាជការ, កងកម្លាំងប្រដាប់អាវុធ និងសាធារណជនចំពោះការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលសម្រេចបានជោគជ័យដ៏ធំធេងក្នុងការប្រែក្លាយកម្ពុជាពីប្រទេសមានចំណូលទាបមកជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥ កន្លងទៅ។ ទោះជាយ៉ាងនេះក្តី គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏នៅតែប្តេជ្ញាបន្តខិតខំអនុវត្តនូវចក្ខុវិស័យដែលជាគោលដៅសំខាន់ៗ របស់កម្មវិធីកែទម្រង់មួយនេះ ជាពិសេសបញ្ចប់ការងារអាទិភាពដែលនៅសេសសល់ក្នុងអាណត្តិទី៥ និងជំរុញការផ្តល់ការលើកទឹកចិត្តជូនក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅគ្រប់ក្រសួង- ស្ថាប័ន។

ក្នុងនាមគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ខ្ញុំសូមសម្តែងនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ និងការដឹងគុណដ៏ជ្រាលជ្រៅជាទីបំផុត ជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលសម្តេចគឺជា **អគ្គមេបញ្ជាការតែមួយ** ក្នុងការជំរុញកម្មវិធីកែទម្រង់ដ៏មុតស្រួចនេះ ឱ្យទទួលបានលទ្ធផលដ៏ធំធេងគួរជាទីមោទនៈ សម្រាប់គ្រប់ក្រសួង- ស្ថាប័នទាំងអស់។ ខ្ញុំក៏សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជូនចំពោះដៃគូអភិវឌ្ឍន៍ទាំងអស់ដែលតែងតែយកចិត្តទុកដាក់ និងបន្តគាំទ្រទាំងទិដ្ឋភាពបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃរាជរដ្ឋាភិបាល, ក្រសួង- ស្ថាប័នដែលជាតួអង្គចូលរួមយ៉ាងសកម្មក្នុងការរៀបចំ និងអនុវត្ត, ព្រមទាំងសហសេវិកនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៕■

ថ្ងៃ ពុធ ១០ កើត ខែ ភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

ចាប់តាំងពីការដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលគន្លឹះៗជាច្រើន។ ដំណាក់កាលទី៣ គឺជាដំណាក់កាលថ្មីមួយទៀត ដែលត្រូវបានគ្រោងសម្រាប់រយៈពេល ៥ ឆ្នាំ គឺចាប់ពីឆ្នាំ២ ០ ១ ៦ រហូតដល់ឆ្នាំ២ ០ ២ ០។ ឆ្នាំ២ ០ ១ ៨ នេះ គឺជាពេលវេលាដ៏សំខាន់មួយដែលគ្រប់ក្រសួង- ស្ថាប័ន តម្រូវឱ្យចូលរួមអនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកា។ ការសម្រេចបានជាច្រើនក្នុងដំណាក់កាលទី១ និងទី២ បានជំរុញការបោះជំហានទៅមុខរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មកកាន់ដំណាក់កាលទី៣ និងកំពុងត្រូវបានត្រួតពិនិត្យ និងវាយតម្លៃលើការចាប់ផ្តើមក្នុងដំណាក់កាលនេះផងដែរ។ វឌ្ឍនភាពដ៏គួរជាទីលើកទឹកចិត្តនេះ គឺជាសមិទ្ធផលដែលកើតចេញពីឆន្ទៈនយោបាយដ៏មុតស្រួច និងឥតរាថយ ព្រមទាំងការកំណត់ទិសដៅ និងយុទ្ធសាស្ត្រដ៏ត្រឹមត្រូវ និងប្រាកដនិយមរបស់រាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹងការចង្អុលណែនាំផ្ទាល់ជាប្រចាំរបស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គួបផ្សំនឹងការខិតខំប្រឹងប្រែងអនុវត្តរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួង- ស្ថាប័នទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមនេះ ក្នុងដំណើរនៃការបោះជំហាន ក៏បានជួបនូវបញ្ហាប្រឈមជាច្រើន ហើយដែលបង្កើនលទ្ធភាពឱ្យអ្នករៀបចំ និងអ្នកអនុវត្ត បន្ថែមភាពប្រុងប្រយ័ត្នខ្ពស់ផងដែរ ក្នុងនោះកត្តាធនធានមនុស្ស គឺជាបញ្ហាប្រឈមមួយដ៏សំខាន់ ដែលបានជួបប្រទះក្នុងកិច្ចដំណើរការនេះ។

ជាការពិត ការលើកកម្ពស់ធនធានមនុស្សក៏នៅតែបន្តយកចិត្តទុកដាក់ខ្លាំងចាប់តាំងពីដំណាក់កាលទី១ មក ហើយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាសេនាធិការក្នុងកិច្ចសម្របសម្រួល រៀបចំ និងតាមដានលើការអនុវត្តសកម្មភាពកែទម្រង់របស់ក្រសួង- ស្ថាប័ន ក៏បានចូលរួមចំណែកកសាងនូវប្រព័ន្ធ និងយន្តការនានាដើម្បីចូលរួមជំរុញប្រសិទ្ធភាពការងារនេះ តាមរយៈការសម្របសម្រួលរៀបចំសិក្ខាសាលាផ្សព្វផ្សាយ កិច្ចសហការសម្របសម្រួលលើការបណ្តុះបណ្តាល និងការរៀបចំឧបករណ៍ផ្សព្វផ្សាយនានា ដែលត្រូវបានចាត់ទុកជាសូចនាករដ៏សំខាន់ផងដែរ ក្នុងការរួមចំណែកបញ្ជ្រាប និងលើកកម្ពស់ការយល់ដឹងរបស់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ និងសាធារណជនទូទៅ។ ជាក់ស្តែង អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានស្ថាបនារៀបចំ និងបោះផ្សាយនូវព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចំនួន៤លេខ រួចមកហើយ ហើយដែលព្រឹត្តិបត្រលេខ ៥ នេះ ក៏ជាសមិទ្ធផលថ្មីសម្រាប់ឆ្នាំ២ ០ ១ ៨ នេះផងដែរ។ ព្រឹត្តិបត្រលេខ ៥ ឆ្នាំ២ ០ ១ ៨ នេះ បានប្រមូលផ្តុំនូវព័ត៌មានដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍ពាក់ព័ន្ធនឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងអត្ថបទដែលកើតពីការសិក្សាស្រាវជ្រាវបន្ថែមមួយចំនួនផងដែរ ដែលអាចរួមចំណែកបង្កើនពុទ្ធិ ក៏ដូចជាចំណេះដឹងមួយចំនួន ដល់អ្នកចង់ឈ្វេងយល់អំពីបច្ចុប្បន្នកម្មនៃកិច្ចដំណើរការកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល។

ជារួម តាមរយៈព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏លើកទឹកចិត្តដល់គ្រប់ក្រសួង- ស្ថាប័ន បន្តចូលរួមក្នុងការចែករំលែកនូវព័ត៌មាន និងអត្ថបទពាក់ព័ន្ធដែលអាចផ្តល់ប្រយោជន៍ជូនមន្ត្រីរាជការ និងសាធារណៈជន៕■

ថ្ងៃ ពុធ ០៥ រោច ខែ ទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០១៨

**អគ្គលេខាធិការ**

**អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំ**

**ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

# មាតិកា

## ព្រឹត្តិការណ៍


ទំព័រ ០១

- កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៧ និងការវាយតម្លៃសមិទ្ធផលរយៈពេល ៥ ឆ្នាំ

ទំព័រ ០៩

- លើកទី១ ដែលកម្ពុជាទទួលធ្វើជាម្ចាស់ផ្ទះ រៀបចំសន្និសិទពេញអង្គនៃបណ្តាញគ្រប់គ្រងចំណាយសាធារណៈប្រចាំអាស៊ី (PEMNA)

ទំព័រ ១៩

- សុន្ទរកថាបើករបស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ថ្លែងក្នុងសិក្ខាសាលាស្តីពី “**បុព្វហេតុ សមិទ្ធផល និងទស្សនវិស័យនៃការងារកែទម្រង់របស់រាជរដ្ឋាភិបាល**”


## អត្ថបទ


ទំព័រ ២៧

- ថវិកាជាតិ ឆ្នាំ២០១៨

ទំព័រ ៣៣

- បញ្ហា និងទស្សនៈ

ទំព័រ ៣៧

- លទ្ធផលនៃការអនុវត្តកម្មវិធីកែទម្រង់ក្នុងកិច្ចការគ្រប់គ្រង និងការប្រមូលចំណូលពន្ធដារ

ទំព័រ ៤១

- ការបង្កើនធនធានហិរញ្ញវត្ថុជូនរដ្ឋបាលថ្នាក់ក្រោមជាតិ

ទំព័រ ៤៣
ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា

ទំព័រ ៤៥
ការរួមចំណែករបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងតម្លាភាពថវិកានៅកម្ពុជា

ទំព័រ ៤៩
លទ្ធផលនៃការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០១៧

ទំព័រ ៥៣
សមិទ្ធផល និងទិសដៅ ៥ ឆ្នាំនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ទំព័រ ៥៧
ថវិកាសង្ខេបឆ្នាំ២០១៨ របស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## ទស្សនៈ និងមតិ

ទំព័រ ៥៩
ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**
*ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

ទំព័រ ៦០
លោកស្រី Ellen Goldstein
*នាយកធនាគារពិភពលោក ប្រចាំប្រទេសកម្ពុជា មីយ៉ាន់ម៉ា និងឡាវ*

ទំព័រ ៥៩
លោកជំទាវ **ខូន សុខា**
*រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

ទំព័រ ៦០
លោក FRANK VIAULT
*ប្រធានផ្នែកសហប្រតិបត្តិការនៃស្ថានតំណាងសហភាពអឺរ៉ុបប្រចាំកម្ពុជា*

ទំព័រ ៥៩
ឯកឧត្តម **រស់ សីលវ៉ា**
*អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

ទំព័រ ៦០
លោក Wansup Kim
*សហប្រធាននៃគណៈកម្មាធិការ PEMNA និងជាអគ្គនាយកគ្រប់គ្រងសមិទ្ធកម្មសារពើពន្ធ ក្រសួងយុទ្ធសាស្ត្រនិងហិរញ្ញវត្ថុ ប្រទេសកូរ៉េ*



ឆន្ទៈ និងភាពជាអ្នកដឹកនាំ

យុទ្ធសាស្ត្រ និង
គោលនយោបាយ
ច្បាស់លាស់








ប្រសិទ្ធភាពនៃការចូលរួម
ប្រកបដោយបរិយាប័ន្ន



**ប្រសិទ្ធភាពនៃកម្មវិធី
កែទម្រង់ការគ្រប់គ្រង
ហិរញ្ញវត្ថុសាធារណៈ**




ការអភិវឌ្ឍ និងកំណើន
ប្រកបដោយចីរភាព



ប្រសិទ្ធភាពនៃការរៀបចំ
និងការអនុវត្ត



ការផ្សព្វផ្សាយ និងតម្លាភាព

# ផ្នែកទី ១ ៖ ព្រឹត្តិការណ៍




# កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៧ និងការវាយតម្លៃសមិទ្ធផល រយៈពេល ៥ ឆ្នាំ

*នាព្រឹកថ្ងៃសុក្រ ៦កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី ២០ ខែមេសា ឆ្នាំ២០១៨ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ ២០១៧ និងការវាយតម្លៃសមិទ្ធផល ៥ ឆ្នាំ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់* ***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*** *នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។*

កិច្ចប្រជុំនេះ មានការចូលរួមពីសម្តេច ឯកឧត្តម លោកជំទាវ សមាជិក សមាជិការាជរដ្ឋាភិបាល, សមាជិកគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួង- ស្ថាប័ន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ, លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ, តំណាងដៃគូអភិវឌ្ឍន៍ និងតំណាងអង្គការ




មិនមែនរដ្ឋាភិបាល សរុបប្រមាណ ៥០០ នាក់។ កិច្ចប្រជុំត្រួតពិនិត្យនេះ ត្រូវបានបែងចែកជា ២ វគ្គ។ វគ្គទី១ គឺពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវ "យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០១៨-២០២៥" និងវគ្គទី២ គឺកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៧ និងការវាយតម្លៃសមិទ្ធផល ៥ឆ្នាំ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានថ្លែងសុន្ទរកថាស្វាគមន៍ ដោយឆ្លុះបញ្ចាំងអំពីសមិទ្ធផលសំខាន់ៗនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់តាំងពីការដាក់ឱ្យអនុវត្តជាផ្លូវការនាឆ្នាំ២០០៤ មក ជាពិសេសសមិទ្ធផលជាសារវន្តដែលសម្រេចបាននៅក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ ស្របពេលដែលអាណត្តិដឹកនាំរបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី ៥ នៃរដ្ឋសភានឹងត្រូវបញ្ចប់នៅក្នុងឆ្នាំ២០១៨ នេះ។ សមិទ្ធផលសំខាន់ៗ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះរួមមានជាអាទិ៍÷

- កសាងបានពេញលេញនូវមូលដ្ឋានគ្រឹះនៃភាពទុកចិត្តបាននៃថវិកា តាមរយៈការពង្រឹងយន្តការកៀរគរចំណូលថវិការដ្ឋ ការគ្រប់គ្រងប្រសិទ្ធភាពនៃចំណាយ និងការគ្រប់គ្រងបំណុលសាធារណៈបានត្រឹមត្រូវ។ បើគិតពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៨ ចំណូលចរន្តថវិការដ្ឋបានកើនឡើងជាង ២ ដង ពីប្រមាណ ២ ២៦៤ លានដុល្លារអាមេរិក ដល់ប្រមាណ ៤ ៥៦០ លានដុល្លារអាមេរិក ដែលបានផ្តល់លទ្ធភាពឱ្យរាជរដ្ឋាភិបាលបង្កើនចំណាយយ៉ាងច្រើន ជាពិសេសលើវិស័យសង្គមកិច្ច និងការលើកកម្ពស់គុណភាព និងពង្រីកវិសាលភាពនៃការផ្តល់សេវាសាធារណៈ ឱ្យកាន់តែខិតទៅជិតប្រជាពលរដ្ឋ។

*ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាយន្តការ និងជាឧបករណ៍មិនអាចខ្វះបានក្នុងការសម្រេចបាននូវគោលដៅនៃការអភិវឌ្ឍ និងវិបុលភាពក្នុងសង្គមជាតិ ដែលនាំឱ្យកម្ពុជាសម្រេចបាននូវបង្គោលចរដ៏សំខាន់មួយ គឺការប្រែក្លាយពីប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប។*

- សម្រេចបានយន្តការស្នូលនៃគណនេយ្យភាពហិរញ្ញវត្ថុ តាមរយៈការដាក់ឱ្យអនុវត្តសាកល្បងនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS) នៅផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងការពង្រីកជាបន្តបន្ទាប់ទៅតាមក្រសួង- ស្ថាប័ន, ការពង្រឹងមុខងារសវនកម្មផ្ទៃក្នុងតាមក្រសួង- ស្ថាប័ន និងការរៀបចំ, កែលម្អ



និងពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងថវិកា។

- សម្រេចបានជាសារវន្តនូវការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ តាមរយៈការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ នៅគ្រប់ក្រសួង-ស្ថាប័ន និងការពង្រឹង និងកែលម្អមួយកម្រិតខ្ពស់ថែមទៀតក្នុងការរៀបចំ និងការចរចាថវិកាដោយឆ្លុះបញ្ចាំងកាន់តែប្រសើរនូវអាទិភាពគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល។
- កែលម្អបន្ថែម លើការផ្សព្វផ្សាយព័ត៌មានថវិកា តាមរយៈការផ្តល់ព័ត៌មានថវិកានៅគ្រប់វដ្តនៃថវិកាចាប់តាំងពីការត្រៀមរៀបចំក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច, ការរៀបចំសេចក្តីព្រាង, ការអនុម័ត និងការអនុវត្តច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដើម្បីប្រសិទ្ធភាពគណនេយ្យភាព និងតម្លាភាពនៃថវិកា។
- សម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ ជាមួយនឹងការបែងចែកផលនៃកំណើនប្រកបដោយសមធម៌ ព្រមទាំងការរក្សាបានជារួមនូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចរឹងមាំ និងអនុគ្រោះក្នុងបរិការណ៍អតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាព រួម-






នឹងវិធានការគោលនយោបាយដោះស្រាយទុក្ខលំបាក, ក្តីកង្វល់ និងបំណងប្រាថ្នាប្រជាពលរដ្ឋ និងគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាលដែលកំពុងតែផ្តល់ជាគុណប្រយោជន៍ដល់ប្រជាពលរដ្ឋទូទៅ ជាពិសេសអ្នកមានចំណូលទាប។

ជាមួយគ្នានេះ លោក FRANK VIAULT ប្រធានផ្នែកសហប្រតិបត្តិការ នៃស្ថានតំណាងសហភាពអឺរ៉ុបប្រចាំកម្ពុជា និងជា




គន្លឹះ ដោយបានវាយតម្លៃខ្ពស់លើកិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, និងគ្រប់ក្រសួង- ស្ថាប័នទាំងអស់ដែលបានចូលរួមអនុវត្តកម្មវិធីកែទម្រង់រហូតសម្រេចបាននូវសមិទ្ធផលជាសារវន្តដូចខាងលើនេះ។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាយន្តការ និងជាឧបករណ៍មិនអាចខ្វះបាន មិនត្រឹមតែក្នុងការសម្រេចបានគោលដៅនៃការអភិវឌ្ឍនិងវិបុលភាពក្នុងសង្គមជាតិ ដែលនាំឱ្យកម្ពុជាសម្រេចបាននូវបង្គោលចរដ៏សំខាន់មួយ គឺការប្រែក្លាយពីប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប និងត្រូវបានចាត់ទុកជាខ្លាសេដ្ឋកិច្ចថ្មីមួយក្នុងតំបន់អាស៊ី ប៉ុណ្ណោះទេ ប៉ុន្តែក៏ចាំបាច់បំផុត សម្រាប់ការខិតខំដើម្បីសម្រេចបាននូវចក្ខុវិស័យ នៃការប្រែក្លាយកម្ពុជា ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ផងដែរ។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក៏បានផ្តល់អនុសាសន៍ណែនាំប្រកបដោយគតិបណ្ឌិត

តំណាងដៃគូអភិវឌ្ឍន៍ បានសម្តែងនូវការអបអរសាទរដល់រាជរដ្ឋាភិបាលកម្ពុជា ដែលសម្រេចបានសមិទ្ធផលសំខាន់ៗ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបញ្ជាក់ជំហររបស់សហភាពអឺរ៉ុប ថានឹងបន្តកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ ជាមួយរាជរដ្ឋាភិបាលកម្ពុជា លើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

បន្ទាប់មក **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានថ្លែងសុន្ទរកថា





និងចក្ខុវិស័យវែងឆ្ងាយ ដល់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាគ្រប់ក្រសួងស្ថាប័ន ឱ្យផ្តោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗចំនួន ៥ រួមមាន÷

- បង្កើនភាពជាម្ចាស់ក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមក្រសួង-ស្ថាប័ន
- ផ្តល់ការលើកទឹកចិត្តដល់ក្រុមការងារកែទម្រង់នៅតាមក្រសួង-ស្ថាប័ន
- បន្តពង្រឹងយន្តការសម្របសម្រួល និងភាពប្រទាក់ក្រឡាគ្នារវាងការកែទម្រង់ទាំង៣ ក្នុងនោះ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, រដ្ឋបាលសាធារណៈ ព្រមទាំងវិមជ្ឈការនិងវិសហមជ្ឈការ
- បន្តពង្រឹងសមត្ថភាពមន្ត្រីនៃក្រសួងស្ថាប័ន ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យកចិត្តទុកដាក់ខ្ពស់ដល់ការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥។

ក្នុងន័យនេះ គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគ្រប់ក្រសួង-ស្ថាប័ន ត្រូវប្រកាន់ខ្ជាប់នូវស្មារតីនៃភាពប្រាកដនិយម និងភាពជាម្ចាស់ខ្ពស់ ព្រមទាំងអភិក្រមទន់ភ្លន់ តែម៉ឺងម៉ាត់ នៅក្នុងការអនុវត្តស្របតាមគោលការណ៍ "ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់"។

សម្រាប់នាពេលរសៀលថ្ងៃដដែល ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានអញ្ជើញដឹកនាំ និងសម្របសម្រួលកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ ២០១៧ និងការវាយតម្លៃសមិទ្ធផល ៥ ឆ្នាំ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។ កិច្ចប្រជុំនាពេលរសៀលនេះ រៀបចំឡើងក្នុងគោលបំណងពិភាក្សាលម្អិតអំពីសមិទ្ធផល, បញ្ហាប្រឈម និង

*ការផ្ទេរមុខងារ ដើម្បីធានាថាការផ្ទេរមុខងារពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ មានភាពរលូនដែលមានគោលបំណង ដើម្បីបង្កិតសេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។*






ទិសដៅនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ជាកិច្ចចាប់ផ្ដើម អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានធ្វើសេចក្ដីរាយការណ៍សង្ខេបអំពីលទ្ធផល នៃរបាយការណ៍ត្រួតពិនិត្យវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំឆ្នាំ២០១៧ ព្រមទាំងសន្និដ្ឋានថា សមិទ្ធកម្មរបស់អង្គភាពនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសមិទ្ធកម្មរបស់ក្រសួង-ស្ថាប័ន សម្រេចបានលទ្ធផលល្អ ដោយស្ទើរគ្រប់សកម្មភាពដែលបានដាក់ចេញក្នុងផែនការសកម្មភាពសម្រេចបានតាមគោលដៅ។ កត្តានេះ បានបង្ហាញអំពីការខិតខំនៃអង្គភាពនីមួយៗ ដើម្បីឈានទៅសម្រេចគោលដៅរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្នុងរយៈពេល ៥ ឆ្នាំ ពីឆ្នាំ២០១៣-២០១៧ ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រេចបានសមិទ្ធផលសំខាន់ៗមានជាអាទិ៍÷

- ថវិកាកាន់តែមានភាពជឿទុកចិត្ត និងបានក្លាយជាកម្លាំងចលករក្នុងការទ្រទ្រង់ និងជំរុញកំណើនសេដ្ឋកិច្ច,
- បុរេលក្ខណៈសំខាន់ៗត្រូវបានកសាង និងពង្រឹងបន្ថែម ដើម្បីធានាគណនេយ្យភាពហិរញ្ញវត្ថុ
- ក្របខ័ណ្ឌថវិកាកម្មវិធី ត្រូវបានរៀបចំពង្រឹង និងពង្រីកការអនុវត្ត ដែលជាឧបករណ៍សំខាន់សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល
- សមត្ថភាពមន្ត្រីនៃក្រសួង-ស្ថាប័នក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានពង្រឹង
- ការយល់ដឹង និងការចូលរួមអនុវត្តកម្មវិធីកែទម្រង់កើនឡើងជាលំដាប់។

ទន្ទឹមនេះ ឯកឧត្តម **ពិត ចំណាន** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា លោក **យូ ពិសី** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុនៃក្រសួងសុខាភិបាល និងលោកស្រី **គង់ សុធីរី** ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្ដល់ចំណាប់អារម្មណ៍ ដោយសម្ដែង






នូវការយកចិត្តទុកដាក់លើការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយទទួលបានអត្ថប្រយោជន៍ជាវិជ្ជមាន ដោយសម្រេចបាន សមិទ្ធផលជាច្រើន ជាពិសេសលើការអនុវត្តថវិកាកម្មវិធី។

ជាមួយគ្នានេះ ឯកឧត្តម **ម៉ាន់ ចំរើន** អនុប្រធានលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប.) បានលើកឡើងថា លេខាធិការដ្ឋាន គ.ជ.អ.ប. បានខិតខំសម្របសម្រួលជាមួយក្រសួង ស្ថាប័ន ធ្វើការផ្ទេរមុខងារ ដើម្បីធានាថា ការផ្ទេរមុខងារពីថ្នាក់ជាតិ ទៅថ្នាក់ក្រោមជាតិមានភាពរលូនដែលមានគោលបំណង ដើម្បីបង្កិតសេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ រីឯ ឯកឧត្តម **គង់ សុភី** ប្រធានលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានបញ្ជាក់បន្ថែមថា ការកែទម្រង់រចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័ន ឱ្យស្របតាមបរិបទប្រព័ន្ធថវិកាថ្មី គឺជាការងារចំពោះមុខដែលគ្រប់ក្រសួង-ស្ថាប័ន គួផ្ដោតការយកចិត្តទុកដាក់។

ទន្ទឹមនេះ លោក FRANK VIAULT ប្រធានផ្នែកសហប្រតិបត្តិការ នៃស្ថានតំណាងសហភាពអឺរ៉ុបប្រចាំកម្ពុជា និងជាតំណាងដៃគូអភិវឌ្ឍន៍ បានអបអរសាទរដល់រាជរដ្ឋាភិបាលចំពោះសមិទ្ធផលសម្រេចបាន ពីការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងស្នើគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនូវសំណើមានជាអាទិ៍ (១). ជំរុញការអនុវត្តនីតិវិធីការងារនៅតាមក្រសួង-ស្ថាប័នឱ្យបានលឿន និងបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការផ្លាស់-





ប្តូរ នៅតាមក្រសួង- ស្ថាប័ន ដើម្បីធានានូវប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង(២). បង្កើនការទទួលខុសត្រូវរបស់អង្គភាពថវិកាតាមក្រសួង- ស្ថាប័ន ស្របពេលនឹងការដាក់ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងថវិកាកម្មវិធី។



*ការកែទម្រង់រចនាសម្ព័ន្ធរបស់ក្រសួង- ស្ថាប័ន ឱ្យស្របតាមបរិបទប្រព័ន្ធថវិកាថ្មី គឺជាការងារចំពោះមុខដែលគ្រប់ក្រសួង- ស្ថាប័នគួរផ្តោតការយកចិត្តទុកដាក់។*

ឆ្លើយតបនឹងសំណើរបស់ក្រសួង- ស្ថាប័ន និងដៃគូអភិវឌ្ឍន៍, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានគូសបញ្ជាក់ និងសង្កត់ធ្ងន់ថា គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានដាក់បញ្ចូលគ្រប់ចំណុចដែលបានលើកឡើងក្នុងទិសដៅនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរយៈពេល ៥ ឆ្នាំ (២០១៨-២០២២)។

ជាចុងបញ្ចប់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានសម្តែងកតញ្ញូតាធម៌ និងកតវេទិតាធម៌ដ៏ថ្លៃវិសេសបំផុតជូន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះគុណូបការៈដ៏ឧត្តុងឧត្តមក្នុងឋានៈសម្តេចជា "**អគ្គមេបញ្ជាការតែមួយ**" នៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ជាតិ។ ជាមួយគ្នានេះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ បានធ្វើការវាយតម្លៃខ្ពស់ និងការកោតសរសើរដ៏ស្មោះចំពោះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងស្ថាប័ន និងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលបានធ្វើសកម្មភាពកែទម្រង់ផ្ទាល់ប្រចាំថ្ងៃ ដោយក្លាហាន ភ្ញាក់រលឹក និងម្ចាស់ការ។ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ក៏បានថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍន៍នានា ដែលបានបន្តផ្តល់ការគាំទ្រចាំបាច់ ទាំងហិរញ្ញប្បទាន និងជំនួយបច្ចេកទេសប្រកបដោយសុឆន្ទៈចំពោះការងារកែទម្រង់ និងជានិច្ចកាល តែងបានលើកតម្កើងភាពជាម្ចាស់របស់កម្ពុជា៕■



# លើកទី១ ដែលកម្ពុជាទទួលធ្វើជាម្ចាស់ផ្ទះ រៀបចំសន្និសិទពេញអង្គនៃបណ្តាញគ្រប់គ្រងចំណាយសាធារណៈ ប្រចាំអាស៊ី (PEMNA)

*ប្រទេសមួយចំនួននៅតំបន់អាស៊ីបានធ្វើកំណែទម្រង់នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមអភិក្រមផ្សេងៗគ្នា និងតាមបរិការណ៍នៃប្រទេសនីមួយៗ។*




ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគឺជាប្រព័ន្ធនៃកិច្ចដំណើរការក្នុងការរៀបចំការគ្រប់គ្រងចំណូល និងការគ្រប់គ្រងចំណាយសាធារណៈ និងកិច្ចដំណើរការសវនកម្ម ជាមួយនឹងក្របខ័ណ្ឌគតិយុត្ត និងច្បាប់។ ការគ្រប់គ្រងចំណាយសាធារណៈគឺជាកិច្ចការដ៏សំខាន់ក្នុងការធានានូវប្រសិទ្ធភាពនៃការបែងចែកធនធាន សម្រាប់អាទិភាពគោលនយោបាយសំខាន់ៗរបស់រដ្ឋាភិបាលដើម្បីការអភិវឌ្ឍប្រទេស។

ជារៀងរាល់ឆ្នាំ ប្រទេសមួយចំនួននៅអាស៊ីតែងតែជួបជុំគ្នាក្នុងកិច្ចពិភាក្សាពេញអង្គក្នុងការផ្លាស់ប្តូរ និងចែករំលែករវាងគ្នាលើបទពិសោធក្នុងកិច្ចការគ្រប់គ្រងចំណាយសាធារណៈរបស់ខ្លួន។ ការជួបជុំនេះ គឺត្រូវបានរៀបចំឡើង រវាងបណ្តាប្រទេសដែលជាសមាជិក នៃបណ្តាញគ្រប់គ្រងចំណាយសាធារណៈនៅអាស៊ី (Public Expenditure Management Network in Asia-PEMNA)។

**តើអ្វីជាបណ្តាញគ្រប់គ្រងចំណាយសាធារណៈនៅអាស៊ី (Public Expenditure Management Network in Asia-PEMNA)?**

បណ្តាញគ្រប់គ្រងចំណាយសាធារណៈនៅអាស៊ី (PEMNA) គឺជាការប្រមូលផ្តុំនូវបណ្តាញមួយ ដើម្បីផ្លាស់ប្តូរនូវបទពិសោធ និងគំនិតរវាងសមាជិកដែលជាអ្នកបដិបត្តិផ្ទាល់ក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។







PEMNA ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១២ ក្នុងគោលបំណងសម្របសម្រួលរវាងប្រទេសជាសមាជិកចំនួន១៤ ដើម្បីផ្លាស់ប្តូរបទពិសោធ នៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ បណ្តាញនេះ ត្រូវបានរៀបចំឡើងជាទម្រង់នៃកិច្ចប្រជុំ ២ ប្រភេទ ដែលហៅថា Budget Community of Practice (B-CoP) សម្រាប់អ្នកកាន់ការងារថវិកា និង Treasury Community of Practice (T-CoP) សម្រាប់អ្នកកាន់ការងាររតនាគារ។ សមាជិកដែលជាអ្នកកាន់ការងារថវិកា និងអ្នកកាន់ការងាររតនាគារ តែងតែជួបប្រជុំគ្នាជារៀងរាល់ឆ្នាំ ដែលកិច្ចប្រជុំនោះ ហៅថាសន្និសីទពេញអង្គប្រចាំឆ្នាំ ដែលមិនត្រឹមតែអ្នកកាន់ការងារផ្ទាល់ចូលរួមប៉ុណ្ណោះទេ ប៉ុន្តែក៏មានជំនាញការបរទេសជាច្រើន ត្រូវបានអញ្ជើញចូលរួមក្នុងការចែករំលែកនូវទ្រឹស្តី និងរបកគំហើញថ្មីៗក្នុងក្របខ័ណ្ឌនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផងដែរ។

សន្និសីទពេញអង្គ នៃបណ្ដាញគ្រប់គ្រងចំណាយសាធារណៈនៅអាស៊ី ត្រូវបានរៀបចំឡើង ៧ លើក រួចមកហើយគិតចាប់តាំងពីឆ្នាំ២០១២ មកម្ល៉េះ ដែលរួមមាននៅថៃ កូរ៉េខាងត្បូង ចិន ម៉ុងហ្គោលី មីយ៉ាន់ម៉ា ហ្វីលីពីន និងឥណ្ឌូនេស៊ី។ ដោយឡែក សម្រាប់ឆ្នាំ២០១៨ នេះ កម្ពុជាត្រូវបានផ្តល់កិត្តិយសធ្វើជាម្ចាស់ផ្ទះ លើកទី៨ សម្រាប់សន្និសីទពេញអង្គនៃបណ្តាញគ្រប់គ្រងចំណាយសាធារណៈ ប្រចាំអាស៊ីនេះ។

ជាការពិត ក្នុងក្របខ័ណ្ឌនៃសុខសន្តិភាព និងឯកភាពទឹកដី ព្រះរាជាណាចក្រកម្ពុជាពិតជាមានកាលានុវត្តភាពជាច្រើនក្នុងការបង្ហាញអន្តរជាតិអំពីវឌ្ឍនភាព និងភាពរីកចម្រើននានា ដែលជាកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងការចូលរួមរបស់ប្រជាពលរដ្ឋកម្ពុជា។ ជាក់ស្តែង សន្និសីទពេញអង្គនៃបណ្តាញគ្រប់គ្រងចំណាយសាធារណៈប្រចាំអាស៊ី គឺបានបង្កើតកាលានុវត្តភាពថ្មីមួយទៀតសម្រាប់កម្ពុជា ក្នុងការចែករំលែកបទពិសោធ និងភាពជោគជ័យ លើការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ខ្លួន។

សន្និសីទពេញអង្គនេះ ត្រូវបានរៀបចំឡើងលើទឹកដីដ៏បវរនៃខេត្តសៀមរាប កាលពីថ្ងៃទី២-៤ ខែឧសភា ឆ្នាំ២០១៨ ដែលមានអ្នកចូលរួមប្រមាណ ៣៥០ នាក់ ពីបណ្ដាប្រទេសជាសមាជិកចំនួន១៤, ដៃគូអភិវឌ្ឍន៍, អ្នកជំនាញការអន្តរជាតិ, និងមន្ត្រីរាជការនៃរាជរដ្ឋាភិបាលកម្ពុជា។ ការរៀបចំសន្និសីទពេញអង្គនេះ ត្រូវបានរៀបចំក្រោមប្រធានបទរួមគឺ "**ការពង្រឹងចំណូល និងការគ្រប់គ្រងថវិកាដើម្បីទ្រទ្រង់អាទិភាពគោលនយោបាយជាតិ** (Strengthening Revenue and Budget Management to Support National Policy Priorities)"។ សន្និសីទពេញអង្គនេះ មានរយៈ




ពេលពីរថ្ងៃកន្លះ និងមានការចូលរួមផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមកិច្ចសហការរៀបចំ និងសម្របសម្រួលដោយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញ-វត្ថុសាធារណៈ និងលេខាធិការដ្ឋាន PE-MNA។ ទន្ទឹមនេះ ថ្ងៃទី២ នៃអង្គសន្និសីទ គឺជាកិច្ចប្រជុំបច្ចេកទេសរបស់អ្នកកាន់ការ-ងារថវិកា និងរតនាគារផងដែរ។

ជាការកត់សម្គាល់ផងដែរក្នុងរយៈពេលពីរថ្ងៃកន្លះនេះ មានប្រធានបទជាច្រើនត្រូវបានលើកយកមកពិភាក្សា ចែករំលែក និងផ្លាស់ប្តូរបទពិសោធ រវាងអ្នកចូលរួម

*ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាប្រព័ន្ធនៃកិច្ចដំណើរការក្នុងការរៀបចំការគ្រប់គ្រងចំណូល និងការគ្រប់គ្រងចំណាយសាធារណៈ និងកិច្ចដំណើរការសវនកម្ម ជាមួយនឹងក្របខ័ណ្ឌគតិយុត្ត និងច្បាប់។*

ជាមួយនឹងវាគ្មិនកិត្តិយស ដែលអញ្ជើញពីប្រទេសជាសមាជិក និងជំនាញការបរទេសផងដែរ។ ប្រធានបទទាំងនោះរួមមាន÷

- Translating National Development Policies into Strategic Actions សំដៅលើគោលនយោបាយកម្រិតថ្នាក់ជាតិ តាមវិស័យ និងក្រសួងដែលត្រូវអនុវត្ត និងទាមទារនូវការគាំទ្រ និងសហប្រតិបត្តិការពីគ្រប់តួអង្គពាក់ព័ន្ធ ដើម្បីធានាការសម្រេចបាន ដែលកិច្ច-ការនេះ តម្រូវឱ្យមានការរៀបចំជាផែនការសកម្មភាពច្បាស់លាស់ និងប្រសិទ្ធភាពនៃការវិភាជ។
- Strengthening Revenue Mobilization with Efficiency, Equity and Sustainability ត្រូវបានពិភាក្សាលើការគ្រប់គ្រងចំណូលសារពើពន្ធដែលជួបប្រទះក្នុងក្របខ័ណ្ឌរដ្ឋបាលសារពើពន្ធដូចជាការមិនមានអនុលោម-ភាព ហើយត្រូវស្វែងរកនូវឧបករណ៍កែលម្អលើកិច្ចការងារនេះ។ លើសពី




នេះ ការពិភាក្សាស្វែងរកនូវដំណោះស្រាយ និងគន្លឹះលើការកាត់បន្ថយគម្លាតអនុលោមភាព និងការជំរុញការប្រមូលចំណូលប្រកបដោយប្រសិទ្ធភាពខ្ពស់។

- A Paradigm Shift Towards Linking Formulation, Execution and Strategic Reviews សំដៅដល់ការផ្លាស់ប្តូរក្នុងការផ្តោតលើការរៀបចំផែនការយុទ្ធសាស្ត្រក្នុងក្របខ័ណ្ឌនៃថវិកាកម្មវិធី។
- International Experience in Strengthening Budget and Revenue Management Systems ដែលមានការចែករំលែកនូវបទពិសោធអន្តរជាតិលើកិច្ចការពង្រឹងប្រព័ន្ធគ្រប់គ្រងថវិកា និងចំណូល។
- Strengthening Budget-Policy Linkages to Improve Public Sector Performance ដែលជាប្រធានបទនៃកិច្ចប្រជុំរវាងអ្នកកាន់ការងារថវិកា ហើយត្រូវបានផ្តោតកិច្ចពិភាក្សាលើការផ្សារភ្ជាប់ផែនការ





យុទ្ធសាស្ត្រជាតិ ជាមួយនឹងកម្មវិធីថវិកាប្រចាំឆ្នាំ (Linking National Strategic Plans to Annual



Budget Programs), ការបំលែងគោលនយោបាយទៅជាការអនុវត្តក្នុងថវិកាកម្មវិធី, ការរៀបចំយុទ្ធសាស្ត្រ និងការកំណត់បញ្ហាប្រឈមនានា (Converting Policy to Action in Program Budgets; Strategies and Challenges), ការដោះស្រាយបញ្ហាប្រឈមលើការអនុវត្ត និងសមាហរណកម្មខ្សែបណ្ដោយ និងខ្សែទទឹង (Addressing the Challenges of Vertical and Horizontal Alignment and Integration), និងការធ្វើសមាហរណកម្មថវិកាឱ្យមានភាពគ្រប់ជ្រុងជ្រោយ និងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ (Integrated Budgeting for Comprehensive and Effective Budget-Policy Linkage)។

- Developing an Effective Government Revenue and Management System ជាប្រធានបទនៃកិច្ចប្រជុំរវាងអ្នកកាន់ការងាររតនាគារ ហើយផ្ដោតកិច្ចពិភាក្សាលើការបង្កើតកិច្ចសហប្រតិបត្តិការរវាងអង្គភាពធនាគារ ឬមិនមែនធនាគារ ក្នុងការជំរុញប្រសិទ្ធភាពនៃការប្រមូលចំណូល (Developing Collaboration with Banking/Non-banking Institution in Accelerating Revenue Collection), ការបង្កើតនូវប្រព័ន្ធអនុម័តលើប្រតិបត្តិការចំណូលតាមប្រព័ន្ធអេឡិចត្រូនិច, (Developing



*គោលនយោបាយកម្រិតថ្នាក់ជាតិ តាមវិស័យ និងក្រសួង ដែលត្រូវអនុវត្តដែលទាមទារនូវការគាំទ្រ និងសហប្រតិបត្តិការពីគ្រប់អង្គភាពពាក់ព័ន្ធ ដើម្បីធានាការសម្រេចបាន ដែលកិច្ចការនេះ តម្រូវឱ្យមានការរៀបចំ ជាផែនការសកម្មភាពច្បាស់លាស់ និងប្រសិទ្ធភាពនៃការវិភាជ។*






Approv al System of Revenue Transa ction Electronically),

ការកែលម្អគុណភាពនៃការព្យាករសាច់ប្រាក់សម្រាប់ចំណូលសាធារណៈ

(Improving the Cash Forecasting Quality for Government Reve-






nue), និងការបង្កើតនូវប្រព័ន្ធត្រួតពិនិត្យ និងគណនេយ្យភាពសម្រាប់អង្គភាពចំណាយដែលផ្តល់ភាពបត់បែន និងសមត្ថកិច្ចសម្រាប់ការប្រើប្រាស់ចំណូលមិនមែនសារពើពន្ធ (Developing Control and Accountability of the Spending Unit that has Flexibility/ Authority

*សន្និសិទពេញអង្គនៃបណ្តាញគ្រប់គ្រងចំណាយសាធារណៈនៅអាស៊ីលើកទី៨ ដែលរៀបចំនៅខេត្តសៀមរាបនៃព្រះរាជាណាចក្រកម្ពុជា មិនត្រឹមតែផ្តល់នូវធាតុចូលថ្មីៗ តាមរយៈការចែករំលែករវាងគ្នា និងគ្នាលើប្រធានបទទាំងអស់ខាងលើតែប៉ុណ្ណោះទេ ប៉ុន្តែក៏បានបង្កើតបរិយាកាសស្និតស្នាលជាមិត្តភាពរវាងបណ្តាប្រទេសជាសមាជិកផងដែរ។*

to Use Non- tax Revenue)។ ជារួម សន្និសីទពេញអង្គនៃបណ្តាញគ្រប់គ្រងចំណាយសាធារណៈនៅអាស៊ីលើកទី៨ ដែលរៀបចំនៅខេត្តសៀមរាបនៃព្រះរាជាណាចក្រកម្ពុជា មិនត្រឹមតែផ្តល់នូវធាតុចូលថ្មីៗ តាមរយៈការចែករំលែក






រវាងគ្នា និងគ្នាលើប្រធានបទទាំងអស់ខាងលើតែប៉ុណ្ណោះទេ ប៉ុន្តែក៏បានបង្កើតបរិយាកាសស្និទ្ធស្នាលជាមិត្តភាព រវាងបណ្តាប្រទេសជាសមាជិកផងដែរ ដែលក្រោមពាក្យស្លោកឆ្លុះបង្ហាញតាមរយៈអត្តសញ្ញាណ PEMNA Plenary Conference 2018 in Cambodia គឺសមាហរណកម្ម (Integration), គុណតម្លៃ (Value), និងភាពរុងរឿង (Prosperity) ជាមួយគ្នា៕■




ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
PEMNA
Public Expenditure
Management Networ
in Asia
THE 2018 PEMNA PL


WORLD BANK GROUP
ENARY CONFERENCE




# សុន្ទរកថាបើករបស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ថ្លែងក្នុងសិក្ខាសាលា ស្ដីពី "បុព្វហេតុ សមិទ្ធផល និងទស្សនវិស័យ នៃការងារកែទម្រង់របស់រាជ-រដ្ឋាភិបាល"

*សិក្ខាសាលាស្ដីពី "បុព្វហេតុ សមិទ្ធផល និងទស្សនវិស័យ នៃការងារកែទម្រង់របស់រាជរដ្ឋាភិបាល ត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការកែទម្រង់គន្លឹះទាំង ៤ របស់រាជរដ្ឋាភិបាលកម្ពុជាដែលរួមមាន÷ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, គណៈកម្មាធិការកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងវិស័យយុត្តិធម៌ក្រោមកិច្ចសហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា ដែលហៅកាត់ថា ស.ស.យ.ក.។*

ថ្ងៃនេះ ខ្ញុំពិតជាមានសេចក្ដីសោមនស្សក្រៃលែងដែលបានមកចូលរួមជាមួយនឹងឯកឧត្ដម លោកជំទាវ អស់លោក លោកស្រី ជាពិសេសប្អូនៗយុវជនដែលជាសសរទ្រូងដ៏រឹងមាំនៃប្រទេសជាតិរបស់យើង នៅក្នុងសិក្ខាសាលាស្ដីពី "**បុព្វហេតុ សមិទ្ធផល និងទស្សនវិស័យនៃការងារកែទម្រង់របស់រាជរដ្ឋាភិបាល**" ដែលត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការកែទម្រង់គន្លឹះទាំង ៤ របស់រាជរដ្ឋាភិបាលកម្ពុជា គឺ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, គណៈ-កម្មាធិការកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, គណៈ-កម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងវិស័យយុត្តិធម៌ក្រោមកិច្ចសហការជា-មួយសហភាពសហព័ន្ធយុវជនកម្ពុជាដែល

ហៅកាត់ថា ស.ស.យ.ក.។

*សុខសន្តិភាព ដែលយើងបាននិងកំពុងអាស្រ័យផលរយៈពេលជិត២ទសវត្សរ៍ចុងក្រោយនេះ គឺជាមហាសមិទ្ធិដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន ដែលយុវជនកម្ពុជាជំនាន់មុន បានស្ថាបនាឡើងដោយការលះបង់គ្រប់បែបយ៉ាង រួមទាំងអាយុជីវិតផ្ទាល់ខ្លួន និងសេចក្ដីសុខក្នុងគ្រួសារផងដែរ។*

បើពិនិត្យលើរបៀបវារៈ យើងឃើញថា សិក្ខាសាលាមួយថ្ងៃពេញនេះត្រូវបានរៀបចំឡើងប្រកបដោយគុណភាព និងស្តង់ដារវិជ្ជាជីវៈខ្ពស់ ដោយមានបទបង្ហាញគន្លឹះៗនៃការដ្ឋានកែទម្រង់ស្នូលទាំង៤ ដែលធ្វើឡើងដោយថ្នាក់ដឹកនាំជាន់ខ្ពស់នៃកម្មវិធីកែទម្រង់នីមួយៗដែលសុទ្ធតែជាអ្នកជំនាញប្រកបដោយបទពិសោធជ្រៅជ្រះ និងគុណកោសល្យវិជ្ជាជីវៈខ្ពង់ខ្ពស់ក្នុងក្របខ័ណ្ឌជាមន្ត្រីរាជការ។ រីឯវគ្គពិភាក្សានឹងប្រព្រឹត្តទៅដោយផ្ដោតលើ បុព្វហេតុ សមិទ្ធផល និងទស្សនវិស័យនៃការងារកែទម្រង់ទាំង៤ ជាពិសេសគឺភាពប្រទាក់ក្រឡាគ្នា, ទំនាក់ទំនង, កិច្ចសហការ, កិច្ចសហប្រតិបត្តិការ, និងការគាំទ្រគ្នា ឬការពឹងផ្អែកឱ្យគ្នា ទៅវិញទៅមក នៃកម្មវិធីកែទម្រង់នីមួយៗ សំដៅសម្រេចបាននូវស្នូលនៃយុទ្ធសាស្ត្រចតុកោណ គឺអភិបាលកិច្ចល្អ ដើម្បីកំណើន, ការងារ, សមធម៌, និងប្រសិទ្ធភាព។

ខ្ញុំរំពឹងទុកថា សិក្ខាសាលារបស់យើងនាថ្ងៃនេះ គឺជាឱកាសនៃការជួបជុំដ៏រស់រវើក និងអន្តរសកម្ម នៃការចែករំលែកពុទ្ធិជាមេរៀន និងបទពិសោធ អំពីការងារកែទម្រង់ស្នូលរបស់រាជរដ្ឋាភិបាលក្នុងចំណោមយុវជនទាំងជំនាន់មុន ក៏ដូចជាជំនាន់បច្ចុប្បន្ន។

ក្នុងន័យនេះ ខ្ញុំសូមរំលឹកអំពីចំណុចប្រវត្តិសាស្ត្រមួយចំនួន ជូនដល់យុវជនយើងផងដែរថា ថ្វីត្បិតយើងបានបង្កើតកម្មវិធីកែទម្រង់ជាច្រើននៅសម័យក្រោយទទួលបានសន្តិភាពពេញបរិបូណ៌ក៏ពិតមែន; ក៏ប៉ុន្តែការងារកែទម្រង់នេះបានចាក់ឫសគល់របស់ខ្លួន ចាប់ផ្ដើមតាំងពីយើងស្ថិតនៅក្នុងដំណាក់កាលដ៏លំបាកបំផុតក្រោយការរំដោះប្រទេសពីរបបប្រល័យពូជសាសន៍ ប៉ុល ពត មកម្លេះ។ សុខសន្តិភាពដែលយើងបាននិងកំពុងអាស្រ័យផលរយៈពេលជិត ២ ទសវត្សរ៍ចុងក្រោយនេះ គឺជាមហាសមិទ្ធិដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន ដែលយុវជនកម្ពុជាជំនាន់មុន បានស្ថាបនាឡើងដោយការលះបង់គ្រប់បែបយ៉ាង រួមទាំងអាយុជីវិតផ្ទាល់ខ្លួន និងសេចក្ដីសុខក្នុងគ្រួសារផងដែរ។

ខ្ញុំសូមគូសរំលេចជាពិសេស ជូនប្អូនៗថា តាំងពីនៅក្នុងដំណាក់កាលដែលប្រទេសយើងស្ថិតក្នុងស្ថានភាពមានសន្តិភាពផង និងមានសង្គ្រាមផងមកម្លេះ ថ្នាក់ដឹកនាំ និងយុវជនជំនាន់មុន ជាពិសេសគឺ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ផ្ទាល់តែម្ដង បានយល់ដឹងច្បាស់ និងប្រកាន់ខ្ជាប់រួចទៅហើយថា ការងារកែទម្រង់គឺជាកិច្ចការស្លាប់-រស់របស់ប្រទេសជាតិដែលយើងត្រូវតែធ្វើ ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ។ ជាក់ស្ដែង នៅក្រោមការដឹកនាំប្រកបដោយភាពវៃឈ្លាស, ប្រាកដនិយម, ពោរពេញដោយភាពក្លាហាន និងគតិបណ្ឌិតព្រមទាំងចក្ខុវិស័យវែងឆ្ងាយរបស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អគ្គមហារដ្ឋបុរសនៃយើង កម្ពុជាបានចាប់ប្រកាន់យកនូវការកែទម្រង់ជាបន្តបន្ទាប់





ឥតរាថយឡើយ ដោយចាប់ផ្តើមពីការបញ្ចប់ភាពអត់ឃ្លានដ៏រ៉ាំរ៉ៃក្រោយការរំដោះប្រទេសជាតិ ៧ មករា ឆ្នាំ១៩៧៩ និងបានឆ្លងកាត់ការកែទម្រង់របបសេដ្ឋកិច្ចជាតិពីសេដ្ឋកិច្ចផែនការ មកជាសេដ្ឋកិច្ចទីផ្សារនៅក្នុងខណៈដែលស្ថាប័ននយោបាយរបស់យើង កំពុងស្ថិតក្នុងស្ថានភាពផ្លាស់ប្តូរជាបណ្តើរៗ និងបានបន្តរហូតមកដល់ការដាក់ឱ្យដំណើរការកម្មវិធីកែទម្រង់គ្រប់ជ្រុងជ្រោយ ទៅតាមអភិក្រមគ្របដណ្តប់តាមវិស័យ ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិនាពេលបច្ចុប្បន្ននេះ។

ពិនិត្យជារួម សារវតារនៃការដឹកនាំកសាងខឿនសេដ្ឋកិច្ចកម្ពុជា តាំងពីក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ មកទល់បច្ចុប្បន្ននេះ គឺជាប្រវត្តិសាស្ត្រនៃការដឹកនាំកែទម្រង់ប្រកបដោយភាពក្លាហាន, មោះមុតឥតរាថយនៅលើមាគ៌ាគោលនយោបាយមួយដែលមានគោលដៅច្បាស់លាស់, មានភាពប្រាកដនិយម និងមានចក្ខុវិស័យវែងឆ្ងាយ ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងសង្គតិភាព។ នោះ គឺជាប្រវត្តិសាស្ត្រនៃការដឹកនាំកសាង "សេដ្ឋកិច្ចទីផ្សារប្រជាជន" ដែលខ្ញុំបានស្នើប្រសិទ្ធនាមថា"**ហ៊ុនសែនណូមិកស៏** (Honsenomics)"។ អ្វីទៅជា "សេដ្ឋកិច្ចទីផ្សារប្រជាជន"? ដោយសារមិនមានពេលវេលាគ្រប់គ្រាន់ ខ្ញុំមិនអាចអធិប្បាយពន្យល់អំពីការយល់ឃើញរបស់ខ្ញុំ លើទស្សនាទានគ្រប់ជ្រុងជ្រោយខាងផ្នែកទ្រឹស្តីនៃ "សេដ្ឋកិច្ចទីផ្សារប្រជាជន" នាពេលនេះបានទេ; ប៉ុន្តែខ្ញុំសូមផ្តល់ជូននូវនិយមន័យនៃ "សេដ្ឋកិច្ចទីផ្សារប្រជាជន" នេះដូចតទៅ÷

"សេដ្ឋកិច្ចទីផ្សារប្រជាជន នៅក្នុងបរិការណ៍កម្ពុជា គឺជាសំណុំនៃល្បាយគោលនយោបាយ និងការដឹកនាំកសាងខឿនសេដ្ឋកិច្ចមួយ ប្រកបដោយបរិយាប័ន្ន; មានលក្ខណៈបើកចំហ; សមាហរណកម្មជាមួយសេដ្ឋកិច្ចតំបន់ និងសកលលោក; ឆ្លើយតបយ៉ាងរស់រវើកទៅនឹងនិន្នាការប្រែប្រួលនានាទាំងក្នុង និងក្រៅប្រទេស; ឈរលើគោលការណ៍ និងយន្តការទីផ្សារ ពិសេសការគោរព និងការការពារកម្មសិទ្ធិឯកជន ព្រមទាំងការប្រកួតប្រជែងដោយយុត្តិធម៌; ដោយក្នុងនោះ វិស័យឯកជនដើរតួនាទី



ជាកម្លាំងចលករនៃកំណើនសេដ្ឋកិច្ច ហើយ រដ្ឋមានតួនាទីជាទស្សនវិទូ ជាយុទ្ធសាស្ត្រវិទូ និងជាអ្នកគ្រប់គ្រងកិច្ចអភិវឌ្ឍ តាមរយៈការផ្គត់ផ្គង់នូវហេដ្ឋារចនាសម្ព័ន្ធ និងការសម្របសម្រួលចាំបាច់នានា ព្រមទាំងការបង្កើតនូវបរិយាកាសអនុគ្រោះអំណោយផលដល់កិច្ចដំណើរការទីផ្សារ ក៏ដូចជាការធ្វើអន្តរាគមន៍នៅពេលចាំបាច់ ដើម្បីតម្រង់ទិសយន្តការទីផ្សារ សំដៅធានាឱ្យប្រជាជនកម្ពុជាគ្រប់ស្រទាប់ជាន់ថ្នាក់ និងគ្រប់រូបអាចចូលរួមយ៉ាងសកម្មក្នុងសកម្មភាពអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ជាមួយនឹងការចែករំលែកប្រកបដោយសមធម៌នូវផលផ្លែផ្កានៃការអភិវឌ្ឍ ដោយមិនបោះបង់ចោលអ្នកណាម្នាក់ឡើយ។” សរុបខ្លី “សេដ្ឋកិច្ចទីផ្សារប្រជាជន” ឬ“**ហ៊ុនសែនណូមិកស៍**” គឺជារបៀបនៃការដឹកនាំ(ពោលគឺជារបៀបដឹកនាំរបស់ **សម្តេចតេជោ ហ៊ុន សែន**) ឆ្លងកាត់ដំណាក់កាលជាច្រើន នៅក្នុងរយៈពេលវែង សំដៅកសាងខឿនសេដ្ឋកិច្ចទំនើបមួយរបស់កម្ពុជា ដោយឈរលើគោលការណ៍ និងយន្តការសេដ្ឋកិច្ចទីផ្សារបើកចំហ ហើយប្រើប្រាស់ និងគ្រប់គ្រងយន្តការសេដ្ឋកិច្ចទីផ្សារនេះ ឱ្យបម្រើផលប្រយោជន៍ប្រជាជនគ្រប់ស្រទាប់ សំដៅធានាឱ្យប្រជាជាតិកម្ពុជាទាំងមូលអាចក្តាប់ជាប់ និងធ្វើជាម្ចាស់យ៉ាងពេញលេញ លើជោគវាសនារបស់ខ្លួន ក្នុងភាពថ្លៃថ្នូរចម្រើនរុងរឿង។ ជាលទ្ធផលនៃការដឹកនាំកែទម្រង់ឆ្លងកាត់បណ្តាដំណាក់កាលដ៏លំបាកស្មុគស្មាញជាបន្តបន្ទាប់ កម្ពុជាសម្រេចបាននូវការផ្លាស់ប្តូរមុខមាត់ថ្មីដ៏គួរជាទីមោទនៈបំផុត។ ដូច **សម្តេចតេជោ** បានគូសបញ្ជាក់ជារឿយៗ, បើពិនិត្យមើលតែត្រឹមរយៈពេលជាងពីរទស្សវត្សរ៍ចុងក្រោយនេះ យើងទាំងអស់គ្នាពិតជានៅចងចាំមិនភ្លេចទេថា កាលពីជាងម្ភៃឆ្នាំមុន កម្ពុជាគឺជាប្រទេសដែលទទួលយកទាហានមួកខៀវរបស់អង្គការសហប្រជាជាតិ ដើម្បីមកធ្វើប្រតិបត្តិការរក្សាសន្តិភាព នៅលើទឹកដីដ៏កម្សត់ ដែលពោរពេញដោយជម្លោះ និងការហែកហួរគ្នានេះ។ ឥឡូវ កម្ពុជាបានក្លាយជាប្រទេសដែលបញ្ជូនកងកម្លាំងរបស់ខ្លួន ឱ្យពាក់មួកខៀវទៅចូលរួមក្នុងប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ នៅក្នុងប្រទេសមួយចំនួនដែលជាចំណុចក្តៅនៅលើសកលលោក។ កម្ពុជាដែលពីមុនល្បីថាជាវាលពិឃាត, ជាតំបន់អសន្តិសុខ, ជាចម្ការមីនដែលគេភ័យខ្លាចគ្រប់គ្នា, ឥឡូវនេះ បានក្លាយទៅជា “**កោះសន្តិភាព**” និងជាតំបន់ទេសចរណ៍ប្រកបដោយប្រជាប្រិយភាពនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលទទួលបានភ្ញៀវទេសចររាប់លាននាក់ក្នុងមួយឆ្នាំ។ កម្ពុជា ដែលពីមុនល្បីក្នុងការប្រើប្រាស់អាវុធដើម្បីដណ្តើមអំណាចគ្នា និងក្នុងការផ្លាស់ប្តូររដ្ឋាភិបាល, ឥឡូវនេះបានក្លាយទៅជាប្រទេសមួយដែលគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស តាមរយៈការរៀបចំយ៉ាងទៀងទាត់ នូវការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដើម្បីឱ្យប្រជាពលរដ្ឋជ្រើសតាំងតំណាងដឹកនាំប្រទេស ជានីតិរដ្ឋដែលគោរពគោលការណ៍ច្បាប់ដោយឥតងាករេ និងជារដ្ឋអធិបតេយ្យដែលមានបូរណភាពទឹកដីពេញលេញ។ កម្ពុជា ដែល



ពីមុនជាប្រទេសត្រូវទទួលរងការហ៊ុមព័ទ្ធ និងឯកោ ទាំងខាងនយោបាយ និងសេដ្ឋកិច្ច, ឥឡូវនេះ បានក្លាយជាប្រទេសមួយដែលកំពុងសមាហរណកម្មខ្លួនយ៉ាងសកម្ម ទៅក្នុងរចនាសម្ព័ន្ធ និងនិម្មាបនកម្មតំបន់ និងពិភពលោក និងជាប្រទេសដែលកំពុងតែដើរតួនាទីយ៉ាងសកម្ម ដោយស្មើសិទ្ធិ និងស្មើភាពក្នុងគ្រប់កិច្ចការតំបន់ និងនៅលើឆាកអន្តរជាតិ។ កម្ពុជា ដែលពីមុនជាប្រទេសអន់ថយខាងផ្នែកសេដ្ឋកិច្ច, គ្របដណ្តប់ទៅដោយភាពក្រីក្រ និងមានអសន្តិសុខស្បៀង, ឥឡូវនេះ បានក្លាយជាប្រទេសនាំស្បៀងចេញ, ហើយស្ថិតនៅក្នុងចំណោមប្រទេសឯតទគ្គៈលើពិភពលោក ដែលសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ និងជាប្រទេសដែលសម្រេចបាននូវវឌ្ឍនភាពដ៏ល្អប្រសើរក្នុងការកាត់បន្ថយភាពក្រីក្រ ក៏ដូចជាការកែលម្អសូចនាករផ្នែកសង្គមកិច្ច ហើយបានឆ្លងកាត់ដោយជោគជ័យ ពីចំណាត់ថ្នាក់នៃប្រទេសមានចំណូលទាបក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប កាលពីពេលថ្មីៗកន្លងទៅ។



ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងប្អូនៗយុវជនជាទីមេត្រី!

សមិទ្ធផល ដែលយើងសម្រេចបាននាពេលកន្លងមក បានចង្អុលប្រាប់យ៉ាងប្រត្យក្សថា ការកែទម្រង់គឺជាមាគ៌ាដ៏ត្រឹម-





ត្រូវ តែមួយគត់ ដែលយើងបានសម្រេចជ្រើសរើសយកមកប្រតិបត្តិដោយឥតងាករេ និងម៉ឺងម៉ាត់ក្លៀវក្លាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត បញ្ញាញាណវាងវៃ និងចក្ខុវិស័យវែងឆ្ងាយរបស់អគ្គមហារដ្ឋបុរសនៃយើង គឺ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងន័យនេះ ការយល់ដឹងរបស់យុវជន អំពីការងារកែទម្រង់របស់រាជរដ្ឋាភិបាល គឺជាលក្ខខណ្ឌសម្រាប់ធានានិរន្តរភាព និងចីរភាពនៃការអភិវឌ្ឍប្រទេសជាតិ ពីមួយជំនាន់ទៅកាន់មួយជំនាន់ទៀតជាបន្តបន្ទាប់; ការឈានទៅមុខ ពិសេសការឈានទៅសម្រេចបាននូវចក្ខុវិស័យនៃការប្រែក្លាយកម្ពុជាទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០ និងជាប្រទេសមានចំណូលខ្ពស់ នៅឆ្នាំ២០៥០ ទន្ទឹមនឹងទស្សនវិស័យដែលកំណត់ថា ការកែទម្រង់គឺជាគន្លឹះជោគជ័យនៃការអភិវឌ្ឍស្ថាប័ន ប្រកបដោយនិរន្តរភាព និងចីរភាព។

*"ហ៊ុនសែនណូមិកស៍ (Hunsenomics)" ឬ "សេដ្ឋកិច្ចទីផ្សារប្រជាជន" ក្នុងបរិការណ៍កម្ពុជាគឺជាសំណុំនៃល្បាយគោលនយោបាយ និងការដឹកនាំកសាងខឿនសេដ្ឋកិច្ចមួយប្រកបដោយបរិយាប័ន្ន; មានលក្ខណៈបើកចំហ; សមាហរណកម្មជាមួយសេដ្ឋកិច្ចតំបន់ និងសាកលលោក; ឆ្លើយតបយ៉ាងរស់រវើកទៅនឹងនិន្នាការប្រែប្រួលនានា ទាំងក្នុង និងក្រៅប្រទេស; ឈរលើគោលការណ៍ និងយន្តការទីផ្សារ ពិសេសការគោរព និងការការពារសិទ្ធិឯកជន ព្រមទាំងការប្រកួតប្រជែងដោយយុត្តិធម៌។*

ខ្ញុំជឿជាក់ថា សិក្ខាសាលាស្តីពីការងារកែទម្រង់របស់រាជរដ្ឋាភិបាល ដែលត្រូវបានរៀបចំឡើងសម្រាប់ផ្តល់ជូនជាពិសេសដល់យុវជនយើងនាពេលនេះ គឺជាការចាប់ផ្តើមមួយដ៏ប្រសើរ ក្នុងការបំពាក់ស្មារតីនៃភាពជាអ្នកដឹកនាំឆ្នើមនៃការងារកែទម្រង់ដល់យុវជនយើង។

ហេតុនេះ ខ្ញុំសូមលើកទឹកចិត្តឱ្យមានការរៀបចំសិក្ខាសាលានេះជាបន្តបន្ទាប់ទៀត ពីព្រោះ ទី១) ការងារកែទម្រង់ជាការងារស្លាប់-រស់របស់ប្រទេសជាតិ ទាំងសម្រាប់ពេលបច្ចុប្បន្ន និងជាពិសេសសម្រាប់អនាគត ដែលប្រការនេះ តែងត្រូវបានលើកឡើងដោយ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ទី២) ការកែទម្រង់មានគោលបំណងដើម្បីលើកកម្ពស់ភាពប្រសើរឡើងនៃអភិបាលកិច្ចល្អ និងសេវាសាធារណៈ ជូនដល់ប្រជាពលរដ្ឋ ជាពិសេសគឺយុវជន ហើយដែលយុវជនគឺជាកម្លាំងដ៏មានសក្តានុពលបំផុតផ្សារភ្ជាប់នឹងការងារកែទម្រង់។ ដូចនេះ ខ្ញុំអាចនិយាយបានថា បុព្វហេតុនៃការកែទម្រង់ គឺដើម្បីយុវជន រីឯបុព្វហេតុយុវជន គឺដើម្បីការកែទម្រង់ សំដៅឆ្ពោះទៅកាន់ត្រើយតែមួយ គឺការអភិវឌ្ឍ និងវិបុលភាពនៃប្រទេសជាតិរបស់យើង។

ផ្អែកលើទស្សនាទានខាងលើ សិក្ខាសាលានាថ្ងៃនេះ នឹងក្លាយទៅជាជំហានយុទ្ធសាស្ត្រថ្មីមួយទៀតនៃការផ្សារភ្ជាប់យុវជនទៅនឹងការងារកែទម្រង់របស់រាជរដ្ឋាភិបាល ដែលផ្តល់កាលានុវត្តភាពដ៏ទូលំទូលាយដល់យុវជនយើងក្នុងការចូលរួមចំណែក ប្រកបដោយភាពជាម្ចាស់លើការដ្ឋានកែទម្រង់នានារបស់រាជរដ្ឋាភិបាល ជាពិសេសគឺការងារកែទម្រង់ស្នូលជាប្រព័ន្ធទាំង៣ រួមបន្ថែមនូវការងារកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មួយទៀត គម្រប់ជា៤។



ជាជំហានបន្ទាប់ ខ្ញុំសូមលើកទឹកចិត្តបន្ថែមទៀត ដល់លេខាធិការដ្ឋានកែទម្រង់ទាំង៤ និងសហភាពសហព័ន្ធយុវជនកម្ពុជា ឱ្យបន្តរៀបចំ និងអនុវត្តផែនការផ្សព្វផ្សាយអំពីការងារកែទម្រង់ទាំង៤ ជូនដល់យុវជនរបស់យើងនៅតាមរាជធានី-ខេត្ត ទៅតាមគំនិតផ្តួចផ្តើម ដែលបានសម្រេចគ្នានៅក្នុងក្រុមការងារបច្ចេកទេសក្នុងពេលកន្លងមក។

*ការយល់ដឹងរបស់យុវជនអំពីការងារកែទម្រង់របស់រាជរដ្ឋាភិបាល គឺជាលក្ខខណ្ឌសម្រាប់ធានានិរន្តរភាព និងចីរភាពនៃការអភិវឌ្ឍប្រទេសជាតិពីមួយជំនាន់ទៅកាន់មួយជំនាន់ទៀតជាបន្តបន្ទាប់; ការឈានទៅមុខពិសេសការឈានទៅសម្រេចបាននូវចក្ខុវិស័យនៃការប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។*

ខ្ញុំមានជំនឿថា តាមរយៈសិក្ខាសាលាក្នុងថ្ងៃនេះ ប្អូនៗប្រាកដជានឹងបានដឹងយ៉ាងស៊ីជម្រៅអំពីសារៈតារ បុព្វហេតុ កិច្ច-ដំណើរការ សមិទ្ធផល និងទស្សនវិស័យ ព្រមទាំងបញ្ហាប្រឈមរួម និងបញ្ហាប្រឈមដោយឡែកនៃការងារកែទម្រង់ទាំង ៤ នេះ ដែលរាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញ និងអនុវត្តអស់ជាច្រើនទសវត្សមកហើយ។ ក្នុងន័យនេះ សិក្ខាសាលានេះ នឹងផ្តល់កាលានុវត្តភាពថ្មីមួយទៀត ដល់យុវជនកម្ពុជាក្នុងការលើកកម្ពស់សមត្ថភាពយល់-ដឹងរបស់ខ្លួន ដើម្បីចូលរួមចំណែកថែរក្សាសុខសន្តិភាព និងការអភិវឌ្ឍប្រទេសជាតិ។ លើមូលដ្ឋាននេះ ខ្ញុំសូមទាញការយកចិត្តទុកដាក់របស់យុវជនកម្ពុជា មកលើកិច្ចការគន្លឹះមួយចំនួន សម្រាប់យុវជនយើងយកទៅពិចារណាដូចតទៅ÷

- សូមខិតខំស្វែងយល់អំពីអត្ថន័យពិតប្រាកដនៃការងារកែទម្រង់របស់រាជ-រដ្ឋាភិបាល ព្រមទាំងផ្តល់មតិយោបល់កែលម្អដល់ការងារកែទម្រង់ក្នុងស្មារតីនៃភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់ចំពោះជោគវាសនានៃប្រទេសជាតិរបស់ខ្លួន។
- សូមចូលរួមគាំទ្រ និងពង្រីកការយល់-ដឹង និងភាពចាំបាច់នៃការកែទម្រង់របស់រាជរដ្ឋាភិបាល ឱ្យកាន់តែទូលំ-ទូលាយថែមទៀត នៅក្នុងមជ្ឈដ្ឋានរបស់ខ្លួន។ សូមយុវជនយើង ធ្វើជាភ្នាក់ងារចម្លង ជូនទៅមជ្ឈដ្ឋានយុវជនយើង។
- សូមពិនិត្យលទ្ធភាពចូលរួមដោយផ្ទាល់ និងដោយស្មារតីនៃភាពជាម្ចាស់ ក្នុងការងារកែទម្រង់របស់រាជរដ្ឋាភិបាល ក្នុងករណីយកិច្ចនីត្យានុកូលនានា ក្នុងនាមជាពលរដ្ឋ និយោជិត ធុរជន សហ-គ្រិន មន្ត្រីរាជការ អ្នកនយោបាយ អា-ស្រ័យតាមអង្គវិជ្ជាជីវៈរបស់ខ្លួនរៀងៗខ្លួន។

ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្អូនៗយុវជន ជាទីស្រឡាញ់រាប់អាន!

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះគណៈកម្មាធិការកែទម្រង់ទាំង៤



ដែលរួមមាន÷គណៈកម្មាធិការកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ, និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ព្រមទាំងសហភាពសហព័ន្ធយុវជនកម្ពុជា ដែលបានផ្តល់កិច្ចសហការ និងសម្របសម្រួលលើការរៀបចំសិក្ខាសាលាមួយនេះ ឱ្យលេចជារូបរាងឡើងនៅថ្ងៃនេះ។



ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជ័យជូនឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, និងប្អូនៗយុវជនទាំងអស់ បានប្រកបដោយសុខភាពល្អ កម្លាំងពលមាំមួន និងសម្រេចបានជោគជ័យដ៏ត្រចះត្រចង់ ក្នុងគ្រប់ភារកិច្ច ដើម្បីបុព្វហេតុជាតិ, មាតុភូមិ និងការអភិវឌ្ឍ៕■




យុទ្ធសាស្ត្រ និង
គោលនយោបាយ
ច្បាស់លាស់
ឆន្ទៈ និងភាពជាអ្នកដឹកនាំ
កំណើន
ការងារ
សមធម៌
ប្រសិទ្ធភាព
គោលនយោបាយរបស់
រាជរដ្ឋាភិបាល
ប្រសិទ្ធភាពនៃការចូលរួម
ប្រកបដោយបរិយាប័ន្ន
ប្រសិទ្ធភាពនៃកម្មវិធី
កែទម្រង់ការគ្រប់គ្រង
ហិរញ្ញវត្ថុសាធារណៈ
2006 2009 2012 2015 2018
7%
កំណើន ផ.ស.ស ប្រចាំឆ្នាំ
ការអភិវឌ្ឍ និងកំណើន
ប្រកបដោយចីរភាព



ប្រសិទ្ធភាពនៃការរៀបចំ
និងការអនុវត្ត

# ផ្នែកទី ២ ៖ អត្ថបទ



ការផ្សព្វផ្សាយ និងតម្លាភាព

# ថវិកាជាតិ ឆ្នាំ២០១៨

*រាជរដ្ឋាភិបាលកម្ពុជាសម្រេចបាននូវបង្គោលចរមួយដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន គឺការក្លាយខ្លួនជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ២០១៥ កន្លងទៅក៏ដូចជាសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សំខាន់ៗផ្សេងៗទៀត។*

### ការចូលរួមចំណែកពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ផ្សារួមយនឹងការដាក់ចេញ និងការអនុវត្តប្រកបដោយឆន្ទៈ និងមហិច្ឆិតាលើកម្មវិធីកែទម្រង់ ដែលជាសសរស្តម្ភនៃការកែប្រែទាំងក្របខ័ណ្ឌវិមជ្ឈការ, ការផ្ទេរធនធាន, ការកែប្រែប្រព័ន្ធថវិកា, និងការអភិវឌ្ឍធនធានមនុស្ស, ព្រះរាជាណាចក្រកម្ពុជា បានចាប់ផ្តើមជាបណ្តើរៗក្នុងសន្ទុះឥតឈប់ឈរ ដើម្បីប្តេជ្ញាកែប្រែប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅកាន់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលផ្តោតលើលទ្ធផល និងវិមជ្ឈការស្របតាមស្តង់ដារអន្តរជាតិ។ ជាក់ស្តែង ការអនុវត្តថវិកាមានភាពប្រសើរឡើង ដោយលំហូរចំណូល និងចំណាយកាន់តែមានភាពរលូន ដោយជំរុញការទូទាត់សាច់ប្រាក់បានទាន់ពេលវេលា, កាត់បន្ថយបានទាំងស្រុងនូវបំណុលកកស្ទះដ៏រ៉ាំរ៉ៃ, ព្រមទាំងបានដាក់ឱ្យអនុវត្តនូវប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាដើម។ កិច្ចខិតខំប្រឹងប្រែងទាំងនេះត្រូវបានទទួលស្គាល់និងវាយតម្លៃខ្ពស់ពីដៃគូអភិវឌ្ឍន៍ និងប្រព័ន្ធវាយតម្លៃអន្តរជាតិរួមមាន÷ ក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ ដែលហៅកាត់ថា PEFA។

### សេចក្តីផ្តើមពីថវិកា ឆ្នាំ២០១៨

ឈរលើមូលដ្ឋានខាងលើនេះ ថវិកាឆ្នាំ២០១៨ ត្រូវបានគិតគូរ និងរៀបចំដើម្បីធានាចលនការនៃការកែទម្រង់របស់ខ្លួន ដែលរាជរដ្ឋាភិបាលបាននិងកំពុងបន្តជំរុញអនុវត្តយ៉ាងសស្រាក់សស្រាំតាំងពីដើមនីតិកាលមក ជាពិសេសដើម្បីសម្រេចឱ្យបានជាអតិបរមានូវគោលដៅយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដើម្បីកំណើន, ការងារ, សមធមិ, និងប្រសិទ្ធភាពនៅកម្ពុជា ដែលជារបៀបវារៈគោលនយោបាយសង្គមសេដ្ឋកិច្ច នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា។

*ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពជាតិ ឯកភាពទឹកដី និងស្ថិរភាពនយោបាយដែលកើតចេញពីនយោបាយឈ្នះ-ឈ្នះ និងការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ, នីតិរដ្ឋ និងការគោរពសិទ្ធមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញ និងច្បាប់, ព្រះរាជាណាចក្រកម្ពុជា សម្រេចបាននូវការអភិវឌ្ឍរីកចម្រើនលូតលាស់លើគ្រប់វិស័យ។*






### សង្ខេបពីសូចនាករម៉ាក្រូសេដ្ឋកិច្ច

តាមការព្យាករ, កំណើនសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០១៨ នឹងអាចបន្តសម្រេចបានក្នុងរង្វង់៧% ក្នុងមួយឆ្នាំ ដែលធ្វើឱ្យផលិតផលក្នុងស្រុកសរុប (ផ. ស. ស) នៃថ្លៃបច្ចុប្បន្នកើនឡើងដល់ 99 116 ប៊ីលានរៀល (ប្រមាណ24,6 ប៊ីលានដុល្លារអាមេរិក) ខណៈដែលផលិតផលក្នុងស្រុកសរុប (ផ. ស. ស) សម្រាប់មនុស្សម្នាក់ត្រូវបានរំពឹងថានឹងកើនឡើងដល់ 1 568 ដុល្លារអាមេរិក (ឆ្នាំ២០១៣÷1042 ដុល្លារអាមេរិក)។ កំណើននេះទ្រទ្រង់ដោយ÷

- កំណើននៃវិស័យឧស្សាហកម្មប្រមាណ 8,6% (ផលិតកម្មគ្រឿងបង្គុំអេឡិចត្រូនិច, ម្ហូបអាហារ និងភេសជ្ជៈ, កាត់ដេរ, សំណង់...)
- កំណើននៃវិស័យសេវាកម្មប្រមាណ 7,6% (ដឹកជញ្ជូន និងទូរគមនាគមន៍, សណ្ឋាគារ និងភោជនីយដ្ឋាន, ទេសចរ, វិស័យអចលនទ្រព្យ...)
- និងកំណើននៃវិស័យកសិកម្មប្រមាណ 2,0% (ដំណាំ, ជលផល, ប្រព័ន្ធស្រោចស្រព...)




រីឯអត្រាអតិផរណាមធ្យមប្រចាំឆ្នាំត្រូវបានប៉ាន់ស្មានក្នុងអត្រា 3,5% ដោយសារការងើបឡើងវិញជាបណ្តើរៗនៃថ្លៃប្រេងលើទីផ្សារអន្តរជាតិ និងថ្លៃកសិផលមួយចំនួន។ ចំណែកឯអត្រាប្តូរប្រាក់រៀល ត្រូវបានរក្សាក្នុងស្ថិរភាពអាចគ្រប់គ្រងបានដោយស្ថិតក្នុងរង្វង់ 4 037 រៀល ក្នុងមួយដុល្លារអាមេរិក។ អត្រានៃភាពក្រីក្រមានការធ្លាក់ចុះពី 53,5% ក្នុងឆ្នាំ២០០៤ មកត្រឹម

13,5% ក្នុងឆ្នាំ២០១៤ និងបន្តធ្លាក់ជាបន្តបន្ទាប់ទៀត។ ទុនបម្រុងអន្តរជាតិក៏បានកើនឡើង ពី 3,64 ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០១៣ ដល់ 7,85 ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០១៨ ដោយសារការវិនិយោគផ្ទាល់ពីបរទេស និងនៅបន្តមានកំណើនល្អ។

## កំណើនថវិកា ឆ្នាំ២០១៨

ក្នុងបរិការណ៍នៃស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ប្រកបដោយសមធម៌, បរិយាប័ន្ន និងធន់នឹងវិបត្តិ, ថវិកាឆ្នាំ២០១៨ត្រូវបានរៀបចំដើម្បីឆ្លើយតបនឹងគោលនយោបាយសំខាន់ និងជាអាទិភាពគន្លឹះៗរបស់រាជរដ្ឋាភិបាល។ តាមរយៈការជំរុញអនុវត្តវិធានការនៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ទំហំចំណូលចរន្តថវិការដ្ឋបានកើនឡើងប្រមាណ ២ ដង គឺពី 2 264 លានដុល្លារអាមេរិកនៅឆ្នាំ២០១៣ រហូតដល់ 4080 លានដុល្លារអាមេរិកនៅឆ្នាំ២០១៨។ ការសម្រេចបាននូវចំណូលដ៏ខ្ពស់ និងមិនធ្លាប់មាននៅក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ បាននាំកម្ពុជាដែលធ្លាប់មានចំណូលថវិកាជាតិធៀបនឹង ផ.ស.ស. ទាបជាងគេក្នុងតំបន់ ឱ្យឡើងដល់កម្រិតកណ្តាលធៀបនឹងប្រទេសក្នុងតំបន់ ហើយមូលនិធិរូបិយវត្ថុអន្តរជាតិ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិដទៃទៀតក៏បានវាយតម្លៃខ្ពស់លើសមិទ្ធផលនេះផងដែរ។

*ទំហំចំណូលចរន្តថវិការដ្ឋ បានកើនឡើងប្រមាណ ២ ដង គឺពី 2 264 លានដុល្លារអាមេរិកនៅឆ្នាំ២០១៣ រហូតដល់ 4 080 លានដុល្លារអាមេរិក នៅឆ្នាំ២០១៨។*

ជារួម ចំណូលសរុបថវិកាជាតិ ត្រូវបានព្យាករកើនដល់ប្រមាណ 23 383 ប៊ីលានរៀល ស្មើនឹង23,59% ធៀបនឹងផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) ដែលមានកំណើន10,6% ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ចំណែកឯចំណាយសរុបថវិកាជាតិត្រូវបានគ្រោងចំនួន24 375 ប៊ីលានរៀល (សមមូល 6 ប៊ីលានដុល្លារអាមេរិក) ស្មើនឹង 24,59% នៃផ.ស.ស. និងមានកំណើន 15,2% ធៀបនឹងច្បាប់ឆ្នាំ២០១៧ពោលគឺចំណាយសរុបថវិកាជាតិនេះត្រូវបានបង្កើនជិត ២ ដង គឺពីប្រមាណ3,35 ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ ២០១៣ រហូតដល់ប្រមាណ 6 ប៊ីលានដុល្លារអាមេរិកនៅឆ្នាំ២០១៨។ ជាលទ្ធផល អតិរេកថវិកាចរន្តអាចរក្សាបានក្នុងកម្រិតប្រមាណ2,48% នៃផ.ស.ស. នៅឆ្នាំ២០១៨ នេះ។

## អាទិភាពថវិកា ឆ្នាំ២០១៨ តាមវិស័យ

ជាមួយនឹងការគ្រោងចំណាយសរុបថវិកាជាតិ, សម្រាប់ឆ្នាំ២០១៨ រាជរដ្ឋាភិបាលបានបន្តយកចិត្តទុកដាក់លើវិស័យសំខាន់ៗដូចជា÷

- វិស័យសង្គមកិច្ច ត្រូវបានចាត់ទុកជាវិស័យអាទិភាពទី១ ក្នុងការវិភាជថវិកាជាតិឆ្នាំ២០១៨ដែលត្រូវបានគ្រោងថវិកាចំណាយប្រមាណ5 658 ប៊ីលានរៀល (សមមូល1,4 ប៊ីលានដុល្លារអាមេរិក) ស្មើនឹង4,71% នៃផ.ស.ស. និងមានកំណើនស្មើនឹង17,0% ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ការគ្រោងនេះ គឺដើម្បីពង្រឹងគុណភាព និងសេវាអប់រំ, អភិវឌ្ឍ






ជំនាញ និងវិស័យការងារ, លើកកម្ពស់គុណភាពសេវាសុខាភិបាល, ឧបត្ថម្ភគាំទ្រដល់សមាគមអតីតយុទ្ធជន និងបង្កើនថវិកាគាំទ្រដល់ការបង្កើតសមាគមន៍មនុស្សចាស់នៅតាមឃុំ- សង្កាត់ចំនួន១ ២៤២ នៅទូទាំងប្រទេស, ការផ្តល់ថវិកាគាំទ្រដល់ការដោះស្រាយជីវភាពជនក្រីក្រតាមសហគមន៍ក្នុងជំហានសាកល្បង, ព្រមទាំងអភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិជាដើម។ ជារួម បើធៀបនឹងឆ្នាំ២០១៣, ក្នុងឆ្នាំ២០១៨ នេះ ថវិកាក្រសួងអប់រំ យុវជន និងកីឡាត្រូវបានបង្កើនជាង៣ដងធៀបនឹងឆ្នាំ២០១៣, ក្រសួងសុខាភិបាលត្រូវបានបង្កើនជិត ២ ដងកន្លះ។

- វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ត្រូវបានគ្រោងថវិកាប្រមាណ 3 894 ប៊ីលានរៀល (សមមូល 0,9 ប៊ីលានដុល្លារអាមេរិក) ស្មើនឹង3,93% នៃផ. ស. ស. និងមានកំណើនស្មើនឹង 16,7% ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ការគ្រោងនេះ គឺដើម្បីគាំទ្រដល់កិច្ចដំណើរការរបស់សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងរដ្ឋបាលតុលាការ, ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ស្ត្រី និងកុមារ, ការផ្តោតយកចិត្តទុកដាក់លើជីវភាព និងសុខុមាលភាពកងកម្លាំងប្រដាប់អាវុធ ក្នុងបុព្វហេតុបន្តធានាកិច្ចការពារនូវអធិបតេយ្យភាពជាតិ បូរណភាពទឹកដី សុខសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ជាដើម។
- វិស័យរដ្ឋបាលទូទៅត្រូវបានគ្រោងថវិកាប្រមាណ 2 263 ប៊ីលានរៀល (សមមូល0,5 ប៊ីលានដុល្លារអាមេរិក) ស្មើនឹង 2,28% នៃផ. ស. ស. និងមានកំណើនស្មើនឹង13,9% ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ការគ្រោងនេះ គឺដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨ ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ និងការបន្តគាំទ្រដល់សវនកម្មផ្ទៃក្រៅ ដើម្បីលើកស្ទួយអភិបាលកិច្ច និងការប្រើប្រាស់ធនធានសាធារណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ល។
- វិស័យសេដ្ឋកិច្ចត្រូវបានគ្រោងថវិកាប្រមាណ1 379 ប៊ីលានរៀល (សមមូល 0,3 ប៊ីលានដុល្លារអាមេរិក) ស្មើនឹង 1,39% នៃផ. ស. ស. និងមានកំណើនស្មើនឹង 5,6% ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ការគ្រោងនេះ គឺដើម្បីលើកកម្ពស់ផលិតភាព, ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្ម ក្នុងវិស័យកសិកម្ម, ការជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធ, ការជំរុញការអភិវឌ្ឍទឹកស្អាត និងអនាម័យជនបទ, ការពង្រឹងគុណភាពសេវាទេសចរណ៍, ការបន្តបើកទីផ្សារសម្រាប់ការនាំចេញ, និងការពង្រឹងនូវយន្តការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម។ល។ ជារួម បើធៀបនឹងឆ្នាំ២០១៣, ក្នុងឆ្នាំ២០១៨ នេះ ថវិកាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង




នេសាទត្រូវបានបង្កើនជិត ៣ ដង។

## ការលើកកម្ពស់ធនធានមនុស្ស

ទន្ទឹមនេះ រាជរដ្ឋាភិបាល ក៏បន្តដំឡើងបៀវត្សរ៍អប្បបរមាជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ រហូតដល់ជិត៣ដងធៀបនឹងឆ្នាំ២០១៣, ដែលក្នុងនោះ÷

- បៀវត្សរ៍សម្រាប់មន្ត្រីរាជការស៊ីវិលកើនពី 34 ម៉ឺនរៀល នៅឆ្នាំ២០១៣ រហូតដល់លើស 91 ម៉ឺនរៀលនៅឆ្នាំ២០១៨ (344 000 រៀល នៅឆ្នាំ២០១៣ រហូតដល់ 914 450 រៀលនៅឆ្នាំ២០១៨)
- បៀវត្សរ៍គ្រូបង្រៀន និងគ្រូពេទ្យកើនពី 36 ម៉ឺនរៀល នៅឆ្នាំ២០១៣ រហូតដល់លើស 1 លានរៀលនៅឆ្នាំ២០១៨ (កើនពី 360 000 រៀល នៅឆ្នាំ២០១៣ រហូតជាង 1 លានរៀលនៅឆ្នាំ២០១៨)
- បៀវត្សរ៍នគរបាល កើនពី38 ម៉ឺនរៀលនៅឆ្នាំ២០១៣ រហូតដល់លើស 1 លានរៀល នៅឆ្នាំ២០១៨ (កើនពី 380 000 រៀលនៅឆ្នាំ២០១៣ រហូតដល់ ជាង 1 លានរៀល នៅឆ្នាំ២០១៨)
- បៀវត្សរ៍យោធិនកើនពី 31,6 ម៉ឺនរៀលនៅឆ្នាំ២០១៣ រហូតដល់លើស 1 លានរៀល នៅឆ្នាំ២០១៨ (កើនពី 316 000 រៀលនៅឆ្នាំ២០១៣ រហូតដល់ជាង 1 លានរៀល នៅឆ្នាំ២០១៨)។

រីឯមន្ត្រីរាជការនៅថ្នាក់ក្រោមជាតិ រួមមានក្រុមប្រឹក្សារាជធានី-ខេត្ត, ក្រុង-ស្រុក-ខណ្ឌ, ឃុំ-សង្កាត់ និងមេភូមិ ក៏ត្រូវបានដំឡើង ជាបន្តបន្ទាប់ផងដែរ។ លើសពីនេះ រាជរដ្ឋាភិបាលក៏បានសម្រេចផ្តល់ និងដំឡើងប្រាក់ឧបត្ថម្ភគោលនយោបាយគាំពារសង្គមចំនួន២ ទៀត ដែលគិតចាប់ពីខែមករា ឆ្នាំ២០១៨ តទៅ, រួមមានការផ្តល់ប្រាក់ឧបត្ថម្ភមាតុភាព និងផ្តល់ប្រាក់ឧបត្ថម្ភបុណ្យសពមន្ត្រីរាជការស៊ីវិលផងដែរ។

## ការយកចិត្តទុកដាក់ផ្សេងៗរួមទាំងមន្ទីរពេទ្យគន្ធបុប្ផា

ជាមួយនឹងថវិកាឆ្នាំ២០១៨ រាជរដ្ឋាភិបាលក៏បានផ្តល់អាទិភាពលើ

- ការថែទាំសុខភាពសម្រាប់កម្មករ
- ការឧបត្ថម្ភមាតុភាពសម្រាប់កម្មករនិយោជិត
- ការបន្តនិរន្តរភាពមន្ទីរពេទ្យគន្ធបុប្ផា ដោយបន្តឧបត្ថម្ភរហូតដល់ជិតប្រមាណ 15 លានដុល្លារអាមេរិក។

## ការប្រើប្រាស់ថវិកាមូលធន



ជាការកត់សម្គាល់ផងដែរ រាជរដ្ឋាភិបាលកម្ពុជានឹងប្រើប្រាស់ថវិកាមូលធនដោយផ្តោតការយកចិត្តទុកដាក់លើការទ្រទ្រង់កំណើនសេដ្ឋកិច្ច ដោយលើកកម្ពស់ភាពប្រកួតប្រជែង និងផលិតភាពសេដ្ឋកិច្ច ដែលរួមមាន÷គម្រោងក្នុងវិស័យថាមពល, វិស័យធារាសាស្ត្រ, វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, វិស័យកសិកម្ម, សុខាភិបាល, ទេសចរណ៍, ការផ្គត់ផ្គង់ទឹកស្អាត, និងអប់រំ។

## ❖ វិធានការដើម្បីសម្រេចបាននូវគោលបំណងខាងលើ និងសន្និដ្ឋានជារួម

ដូចនេះ ដើម្បីសម្រេចបានគោលបំណងទាំងអស់ខាងលើ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការដូចជា÷ វិធានការឆ្លើយតបនឹងផលប៉ះពាល់អវិជ្ជមានពីហានិភ័យខាងទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ច, វិធានការពង្រឹង និងកែលម្អគោលនយោបាយ និងការគ្រប់គ្រងចំណូល, ការគ្រប់គ្រងចំណាយ, ការជំរុញអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗ ជាពិសេសកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ គឺការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ, ការអនុវត្តយុទ្ធសាស្ត្រនៃកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥, ការកែទម្រង់រដ្ឋបាលសាធារណៈ, និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ បន្ថែមពីនេះ រាជរដ្ឋាភិបាលលុបចោលពន្ធសត្តឃាត, កែសម្រួលមាត្រា៤៧ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ដើម្បីដំឡើងកម្រិតអប្បបរមានៃបៀវត្សរ៍ជាប់ពន្ធឱ្យដល់ 1 200 000 រៀល ដើម្បីផ្តល់ការអនុគ្រោះដល់មន្ត្រីរាជការ និងកម្មករនិយោជិតដែលមានបៀវត្សរ៍ទាប និងការបញ្ចូលបទបញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែក្នុងច្បាប់ស្តីពី សារពើពន្ធផងដែរ។



*រាជរដ្ឋាភិបាល បន្តដំឡើងបៀវត្សរ៍អប្បបរមាជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ រហូតដល់ជិត ៣ ដង ធៀបនឹងឆ្នាំ២០១៣។*

ជារួម ការសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចក្នុងបរិការណ៍អតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាពខាងលើនេះ បានធ្វើឱ្យប្រជាជនកម្ពុជាគ្រប់ស្រទាប់ជាន់ថ្នាក់នៅទូទាំងប្រទេស កាន់តែមានឱកាសក្នុងការស្វែងរកការងារ និងបង្កើនប្រាក់ចំណូល ដោយក្នុងនោះមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ទទួលបានប្រាក់ចំណូលកាន់តែខ្ពស់ពីមួយឆ្នាំទៅមួយឆ្នាំ។

លើសពីនេះ វិធានការបុរេសកម្មជាច្រើនរបស់រាជរដ្ឋាភិបាលទាំងក្នុងទិដ្ឋភាពនយោបាយ និងគោលនយោបាយពាក់ព័ន្ធនឹងការបញ្ចុះតម្លៃថាមពលអគ្គិសនី និងទឹកស្អាត, ការបន្ធូរបន្ថយពន្ធ, និងការអនុគ្រោះពន្ធលើប្រភេទពន្ធមួយចំនួនជាដើម បាននិងកំពុងផ្តល់នូវគុណប្រយោជន៍ជូនដល់ប្រជាពលរដ្ឋទូទៅ ជាពិសេសអ្នកមានចំណូលទាប និងមន្ត្រីរាជការ, កងកម្លាំងប្រដាប់អាវុធ, គ្រូបង្រៀន, គ្រូពេទ្យ, និងកម្មករនិយោជិត។

ហេតុដូចនេះថវិកាឆ្នាំ២០១៨ត្រូវបានប្រសិទ្ធនាមថា ជាថវិកាយុទ្ធសាស្ត្រនៃការពូនផ្តុំកម្លាំង និងធនធានជាអតិបរមា ដើម្បីសម្រេចឱ្យខានតែបាននូវគោលដៅសំខាន់ៗនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា៕■

# បញ្ហា និងទស្សនៈ

## *ពិនិត្យទៅលើបញ្ហាជាក់ស្តែងក្នុងប្រទេសជាសមាជិកតាមរយៈទស្សនៈនៃសមាជិករបស់ខ្លួន (through the eyes of its members)។*

តាមរយៈសន្និសិទពេញអង្គនៃបណ្តាញគ្រប់គ្រងចំណាយសាធារណៈប្រចាំអាស៊ី(The PEMNA Plenary Conference) ឆ្នាំ២០១៨, លោក **មាស សុខសេនសាន** មកពីអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(**អ.គ.ហ.**)នៃរាជរដ្ឋាភិបាលកម្ពុជានឹងពន្យល់អំពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា (PFMRP) តាមរយៈកម្រងសំណួរនិងអត្ថាធិប្បាយដូចខាងក្រោម÷

### សំណួរទី១. អំពី **អ.គ.ហ.**

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(**អ.គ.ហ.**) គឺជាសេនាធិការនៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាលកម្ពុជាដោយអនុវត្តនូវគំនិតផ្តួចផ្តើមនៃយុទ្ធសាស្ត្រកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងស្នើសុំការអនុម័តពីគណៈកម្មាធិការ តាមរយៈកិច្ចប្រជុំទៀងទាត់ជាប្រចាំខែ ត្រីមាស និងឆ្នាំ។ យើងក៏បានបង្កើតនូវក្របខ័ណ្ឌនៃផែនការសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ដែលហៅថាផែនការសកម្មភាពរួម“CAP”) របស់រាជរដ្ឋាភិបាល និងធ្វើការតាមដាននូវការអនុវត្តផងដែរ។

### សំណួរទី២. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា÷សមិទ្ធផល និងបញ្ហាប្រឈម



*លោក មាស សុខសេនសាន អគ្គលេខាធិការរង **អ.គ.ហ.** "យើងប្តេជ្ញាក្នុងការបំពេញតួនាទីជាសេនាធិការនៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្តេជ្ញាកែលម្អប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា។ ការងារនេះនឹងសម្រេចបានប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ដោយផ្លាស់ប្តូរពីប្រព័ន្ធថវិកាផ្អែកលើធាតុចូល ទៅប្រព័ន្ធថវិកាផ្អែកលើធាតុចេញ ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ"។*

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា អនុវត្តជា ៤ ដំណាក់កាល។ តាមរយៈដំណាក់កាល ២ ដំបូងនៃកម្មវិធី, យើងបានបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងតាមក្រសួង-ស្ថាប័ន, បានកែលម្អនីតិវិធីនៃសំណើសុំធានាចំណាយ, អនុវត្តនូវអង្គភាពថវិកា ថវិកាកម្មវិធី និងចំណាត់ថ្នាក់ថវិកា, ដាក់ឱ្យដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS) ដំណាក់កាលទី១។ល។ មុននឹងសម្រេចបាននូវសមិទ្ធកម្មដែលមាននាពេលបច្ចុប្បន្ន, យើងបានប្រឈមនឹងឧបសគ្គ និងភាពលំបាកលំបិនជាច្រើន ដោយសារតែការយល់ដឹងនៅមានកម្រិតអំពីតម្លៃនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងកង្វះខាតធនធានមនុស្ស និងការប្តេជ្ញារបស់ក្រសួង-ស្ថាប័ន។ ជាក់ស្តែង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដើរតួនាទីឈានមុខគេក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ដោយបានបញ្ចប់ដំណាក់កាលទី១ និងទី២ នៃ PFMRP, យើងឈានមកដល់

| |
|---|
| ព័ត៌មាន |
| ឈ្មោះ |
| របប |
| រាជធានី |
| បំណែង |
| ផ្ទៃដី |
| ចំនួនប្រ (២០១ |
| ក្រុមជន |
| ភាសា |
| សាសនា |
| សេដ្ឋកិ |
| ផ.ស.ស |
| អត្រាកំ |
| អត្រាអ |
| អត្រានិ |
| ការនាំចេ |
| ទំនិញ |
| ការនាំចូ |
| ទំនិញ |
| ហិរញ្ញវ |
| ឆ្នាំសារ |
| ចំណូល |
| ចំណូល |
| ចំណាយ |
| បំណុល ធៀបនឹ |
| ប្រភព÷ |

| ...ទូទៅ | |
|---|---|
| ...ប្រទេស | ព្រះរាជាណាចក្រកម្ពុជា |
| | រាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ |
| ... | ភ្នំពេញ |
| ...ចែករដ្ឋបាល | ២៥ រាជធានី-ខេត្ត |
| | ១៨១ ០៣៥ គីឡូម៉ែត្រការ៉េ (ទី៩១ លើពិភពលោក) |
| ...ជាជន ...៧ ប៉ាន់) | ១៦,២ លាននាក់ (ទី៦៨ លើពិភពលោក) |
| ...ជាតិ (២០១៥) | ភាគច្រើន÷ ខ្មែរ ភាគតិច÷ ចិន, វៀតណាម, ចាម, ថៃ, ឡាវ |
| ...វការ | ខ្មែរ |
| ...ា (២០០៨) | ពុទ្ធសាសនា (ផ្លូវការ) ៩៦,៩% មូស្លីម ១,៩% ផ្សេងៗ ១,២% |
| ...ច្ច (២០១៧ ប៉ាន់) | |
| ..., ថ្លៃបច្ចុប្បន្ន | ២២,២៥ ប៊ីលានដុល្លារអាមេរិក |
| ...ណើន ផ.ស.ស. | ៧,០% |
| ...តិផរណា | ៣,៨% |
| ...កម្មភាព | ០,៣% |
| ...ចេញ | ១០,៨៤ ប៊ីលានដុល្លារអាមេរិក |
| ...ាំចេញ | សម្លៀកបំពាក់, ជ័រ ។ល។ |
| ...ល | ១៤,២២ ប៊ីលានដុល្លារអាមេរិក |
| ...ាំចូល | ប្រេងឥន្ធនៈ,ដែក, ស៊ីម៉ងត៍, ល. |
| ...ត្ថុរបស់រដ្ឋាភិបាល (២០១៧ ប៉ាន់) | |
| ...ពីពន្ធ | ឆ្នាំប្រតិទិន |
| ... | ១៩,៦៩% នៃ ផ.ស.ស. |
| ...ពន្ធ | ១៥,៩៧% នៃ ផ.ស.ស. |
| ...ប | ២៣,៣១% នៃ ផ.ស.ស. |
| ...សាធារណៈ ...ង ផ.ស.ស. | ២២,៨% នៃ ផ.ស.ស. |

CIA - ព័ត៌មានទូទៅ
IMF - ផ.ស.ស.
កសហវ - សេដ្ឋកិច្ច, ហិរញ្ញវត្ថុរបស់រដ្ឋាភិបាល
វិទ្យាស្ថានជាតិស្ថិតិ - ក្រុមជនជាតិ, អត្រានិកម្មភាព

ដំណាក់កាលទី៣ ដែលផ្តោតជាសារវន្តលើការធានាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយតាមរយៈការអនុវត្តពេញលេញនូវថវិកាកម្មវិធី និងអង្គភាពថវិកា។ ជាមួយគ្នានេះដែរ យើងបានដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ និងគម្រោងប្រព័ន្ធ FMIS ជំហានទី២ ខណៈនៅតែបន្តអនុវត្ត និងពង្រឹងកិច្ចការកែទម្រង់គន្លឹះក្នុងដំណាក់កាលមុនៗ។

*ដោយបានបញ្ចប់ដំណាក់កាលទី១ និងទី២ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, យើងបានឈានមកដល់ដំណាក់កាលទី៣ ដែលផ្តោតជាសារវន្តលើការធានាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយតាមរយៈការអនុវត្តពេញលេញនូវថវិកាកម្មវិធី និងអង្គភាពថវិកា។*

### សំណួរទី៣. ការរំពឹងទុកសម្រាប់សន្និសីទពេញអង្គ PEMNA ឆ្នាំ២០១៨

ក្នុងនាមជាម្ចាស់ផ្ទះ, សម្រាប់សន្និសីទពេញអង្គឆ្នាំនេះ, កម្ពុជាសូមចែករំលែកអំពីកិច្ចខិតខំប្រឹងប្រែងក្នុងការកែទម្រង់ជាមួយបណ្តាប្រទេសជាសមាជិកនៃអង្គសន្និសិទ។ បន្ថែមពីលើនេះ យើងក៏ចង់ទាញយកបទពិសោធពីបណ្តាប្រទេសជាសមាជិក PEMNA ក៏ដូចជាអ្នកជំនាញផងដែរ។ ជាពិសេស យើងចង់ដឹងពីវិធីសាស្ត្រដែលមានប្រសិទ្ធិភាព ក្នុងការគ្រប់គ្រងចំណូល, ចំណុចគន្លឹះនៃការបង្កើតគោលនយោបាយដើម្បីឱ្យស្របទៅនឹងអាទិភាពគោលនយោបាយជាតិ, បញ្ហាប្រឈមគន្លឹះៗដែលស្ថាប័ននិម្មាបនករ និងស្ថាប័នប្រតិបត្តិករជួបប្រទះ នៅពេលរៀបចំក្របខ័ណ្ឌកែទម្រង់ ដើម្បីធានាឱ្យមានការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងការកែលម្អបន្ថែមនៅក្នុងការគ្រប់គ្រងប្រព័ន្ធថវិកា។ ក្នុងន័យនេះ បទពិសោធ និងចំណេះដឹងដែលបានចែករំលែកនៅសន្និសីទពេញអង្គ PEMNA ឆ្នាំ ២០១៨ នេះ នឹងក្លាយជាធាតុចូលដ៏មានតម្លៃសម្រាប់ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវប្រព័ន្ធថវិកា ក៏ដូចជាសម្រាប់កំណើនសេដ្ឋកិច្ចជាតិ។

## ទិដ្ឋភាពទូទៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

នាខែធ្នូ ឆ្នាំ២០០៤, នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសដាក់ឱ្យអនុវត្តនូវកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(PFMRP) ដើម្បីកែលម្អការផ្តល់សេវាសាធារណៈ និងការបែងចែកធនធាន។ PFMRP មានគោលដៅផ្លាស់ប្តូរជាបណ្តើរៗ ពីប្រព័ន្ធថវិកាផ្អែកលើធាតុចូល និងមជ្ឈការទៅជាប្រព័ន្ធថវិកាផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ។ កម្មវិធីនេះ ត្រូវបានដាក់ចេញតាមអភិក្រមជាខឿនចំនួន៤ និងអនុវត្តជា៤ ដំណាក់កាលរួមមាន÷

- ដំណាក់កាលទី១. ភាពជឿទុកចិត្តបាននៃថវិកា (២០០៥-២០០៨)
- ដំណាក់កាលទី២. គណនេយ្យភាពហិរញ្ញវត្ថុ (២០០៩-២០១៥)
- ដំណាក់កាលទី៣. ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ (២០១៦-២០២០)
- ដំណាក់កាលទី៤) គណនេយ្យភាពសមិទ្ធកម្ម (២០២១-២០២៥)។

## វឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

តាមរយៈដំណាក់កាលទី១ និងទី ២ នៃការកែទម្រង់របស់ខ្លួន, កម្ពុជាសម្រេចបាន




នូវលទ្ធផលដូចខាងក្រោម÷

- ចំណូលស្ថិតនៅកៀកគោលដៅដែលបានកំណត់
- គ្មានបំណុលកកស្ទះថ្មីក្នុងឆ្នាំ២០១៤ និងឆ្នាំ២០១៥ ដោយរក្សាបាននូវបំណុលស្ថិតក្រោម ២% នៃចំណាយសរុប។
- អង្គភាពសវនកម្មផ្ទៃក្នុងត្រូវបានអនុវត្តនៅតាមក្រសួង-ស្ថាប័ន។
- អ្នកកាន់ថវិកាបានចំណាយស្របតាមថវិកាដែលបានអនុម័ត និងការព្យាករលំហូរសាច់ប្រាក់ក្នុងឆ្នាំសារពើពន្ធ ហើយអនុវត្តតាមចំណាត់ថ្នាក់ថវិកា (ឧទា. បៀវត្សរ៍, ទំនិញ/សេវា និងចំណាយមូលធន)។
- ច្បាប់ថ្មីស្តីពីប្រព័ន្ធហិរញ្ញវត្ថុត្រូវបានអនុម័ត និងអនុវត្ត។
- អង្គភាពថវិកា, ថវិកាកម្មវិធី និងចំណាត់ថ្នាក់ថវិកាត្រូវបានបង្កើត និងអនុវត្ត។
- ជំហានទី១នៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:(FMIS) ត្រូវបានដាក់ឱ្យដំណើរការក្នុងដំណាក់កាលទី២ នៃ PFMRP។

### ❖ ជំណាក់កាលទី៣(២០១៦-២០២០)÷ ការផ្សារភ្ជាប់ថវិកា នឹងគោលនយោបាយ

បន្ទាប់ពីបានផ្តោតលើការបង្កើតភាពជឿទុកចិត្តបាននៃថវិកា, ការត្រួតពិនិត្យផ្ទៃក្នុង, និងគណនេយ្យភាពហិរញ្ញវត្ថុ តាមរយៈដំណាក់កាលទី១ និងទី២, កម្ពុជាបាន

## អតីតកាល






ឈានដល់ដំណាក់កាលទី៣ (ការផ្សារភ្ជាប់ថវិកា ទៅនឹងគោលនយោបាយ) ក្នុងគោលដៅពង្រឹងការផ្សារភ្ជាប់រវាងថវិកា និងគោលនយោបាយ ដោយធានាការអនុវត្តពេញលេញនូវថវិកាកម្មវិធី និងអង្គភាពថវិកា។

*កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានគោលដៅផ្លាស់ប្តូរជាបណ្តើរៗ ពីប្រព័ន្ធថវិកាផ្អែកលើធាតុចូល និងមធ្យោបាយ ទៅជាប្រព័ន្ធថវិកាផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម និងវិមធ្យោបាយ។*

ការកែទម្រង់ប្រព័ន្ធថវិកាត្រូវបានអនុវត្តដោយផ្អែកលើយុទ្ធសាស្ត្រដូចខាងក្រោម÷

- ពង្រឹងការអនុវត្ត និងការបង្កើនប្រសិទ្ធភាពនៃផែនការយុទ្ធសាស្ត្រថវិកា (BSP)
- ការពង្រឹង និងការអនុវត្តថវិកាកម្មវិធីពេញលេញតាមក្រសួង-ស្ថាប័នរួមទាំងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យឡើងវិញ, កែសម្រួល និងអនុវត្តចំណាត់ថ្នាក់ថវិកាថ្មី, ប្លង់គណនេយ្យថ្មី និងដំណាក់កាលទី២ នៃប្រព័ន្ធ FMIS
- ការដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥។

## សន្និដ្ឋាន

រហូតមកដល់ពេលនេះ, កម្ពុជាសម្រេចបាននូវគោលដៅសំខាន់ៗ ដែលបានកំណត់ក្នុងដំណាក់កាលនីមួយៗ។ ក្នុងការសម្រេចបាននេះ ឆន្ទៈនយោបាយដ៏រឹងមាំ, ការប្តេជ្ញា និងភាពជាអ្នកដឹកនាំរបស់ថ្នាក់ដឹកនាំនៃគ្រប់ក្រសួង-ស្ថាប័នគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះភាពជោគជ័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ លើសពីនេះទៀត ចាំបាច់ត្រូវពង្រឹងការអភិវឌ្ឍធនធានមនុស្ស និងសមត្ថភាពស្ថាប័នដើម្បីគាំទ្រដល់ការអនុវត្តនូវប្រព័ន្ធថវិកាថ្មីប្រកបដោយភាពរឹងមាំ និងចីរភាព៕■

## អនាគតកាល



# លទ្ធផលនៃការអនុវត្តកម្មវិធីកែទម្រង់ក្នុងកិច្ចការគ្រប់គ្រង និងការប្រមូលចំណូលពន្ធដារ

*សន្តិភាព និងស្ថិរភាពនយោបាយបានផ្តល់ឱកាស និងលទ្ធភាពឱ្យអគ្គនាយកដ្ឋានពន្ធដារ ក្នុងនាមជាសេនាធិការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដាក់ចេញនូវយុទ្ធសាស្ត្រ និងវិធានការកែទម្រង់ស៊ីជម្រៅក្នុងការប្រមូលចំណូលពន្ធឱ្យបានគ្រប់ផែនការ។*

ស្ថិតក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាពិសេស ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម (២០១៤-២០១៨) អគ្គនាយកដ្ឋានពន្ធដារបានខិតខំប្រឹងប្រែងប្រមូលចំណូលពន្ធ ព្រមទាំងចូលរួមអនុវត្តយ៉ាងសកម្មក្នុងកិច្ចការកែទម្រង់គោលនយោបាយសារពើពន្ធ និងជាពិសេសការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ។ ការងារកែទម្រង់មិនមែនគ្រាន់តែជាកិច្ចការដែលអាចជួយបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការងារប្រចាំថ្ងៃប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាឧបករណ៍គោលនយោបាយដ៏មានសារៈសំខាន់ក្នុងការដោះស្រាយបញ្ហាប្រឈមនានា និងបង្កើតកាលានុវត្តភាពថ្មីៗ ឆ្ពោះទៅរកការអភិវឌ្ឍ និងវិបុលភាព។ ក្នុងន័យនេះ តាមរយៈការចូលរួមអនុវត្តយ៉ាងខ្លាំងក្លានូវកម្មវិធីកែទម្រង់ស៊ីជម្រៅ និងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ ប្រកបដោយគតិបណ្ឌិត, ភាពឈ្លាសវៃ និងបញ្ញាញាណដ៏ភ្លឺស្វាងរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងខិតខំយ៉ាងយកចិត្តទុកដាក់ ក្នុងការធានានូវប្រសិទ្ធភាព, ផលិតភាព, តម្លាភាព, សមភាព និងគណនេយ្យភាព នូវនីតិវិធីនៃការគ្រប់គ្រង និងការប្រមូលចំណូលពន្ធ តាមរយៈការពង្រឹង និងកែលម្អគោលនយោបាយសារពើពន្ធ ការកែលម្អរដ្ឋបាលសារពើពន្ធ និងការបញ្ជ្រាបវប្បធម៌នៃការបង់ពន្ធ។ ជាលទ្ធផល អគ្គនាយកដ្ឋានពន្ធដារសម្រេចបាននូវការប្រមូលចំណូលពន្ធលើសផែនការជារៀងរាល់ឆ្នាំ ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ។ ដើម្បីសម្រេចបានជោគជ័យដែលរំលេចឡើងតាមរយៈតួលេខខាងក្រោមនេះ អគ្គនាយកដ្ឋានបាននិងកំពុងអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវបរិបទថ្មីនៃការកែទម្រង់ស៊ីជម្រៅស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល តាមរយៈការពង្រឹង និងកែលម្អគោលនយោបាយសារពើពន្ធ



តារាងចំណូលពន្ធធៀបនឹងផែនការរយៈពេល ០៥ ឆ្នាំចុងក្រោយ

| បរិយាយ/ឆ្នាំ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|
| ចំណូល (ប៊ីលាន រៀល) | 3,604.89 | 4,267.00 | 5,210.00 | 6,010.48 | 7,754.81 |
| ចំណូល (លាន ដុល្លារ) | 901.22 | 1,067.00 | 1,302.00 | 1,502.62 | 1,938.70 |
| ផែនការ (ប៊ីលាន រៀល) | 3,463.61 | 3,975.16 | 4,659.50 | 5,686.26 | 6,863.30 |
| ផែនការ (លាន ដុល្លារ) | 865.9 | 993.79 | 1,164.88 | 1,421.56 | 1,715.83 |
| % ភាគរយនៃចំណូល | 104.08% | 107.40% | 111.80% | 105.70% | 113.00% |

*ចំណូលពន្ធមានការកើនឡើងប្រមាណជាង ១ ០០០ លានដុល្លារ ក្នុងរយៈពេល ០៥ ឆ្នាំចុងក្រោយ ពោលគឺមានការកើនឡើងពី ៩០១,២២ លានដុល្លារ នៅឆ្នាំ២០១៣ រហូតដល់ ១ ៩៣៨,៧០ លានដុល្លារ នៅឆ្នាំ២០១៧

ក្រាហ្វិចបង្ហាញពីការកើនឡើងនៃចំណូលពន្ធរយៈពេល ៥ ឆ្នាំចុងក្រោយ




ក៏ដូចជាការពង្រឹង និងកែលម្អរដ្ឋបាលសារពើពន្ធ។

*ទំនើបកម្មរដ្ឋបាលសារពើពន្ធ សំដៅលើកកម្ពស់ការផ្តល់សេវាសាធារណៈ ឱ្យកាន់តែមានគុណភាព រហ័ស, ងាយស្រួល, គួរឱ្យទុកចិត្ត និងសមស្របទៅនឹងតម្រូវការ ជាពិសេសដើម្បីធ្វើឱ្យការងារកែទម្រង់ស្ថាប័នពន្ធដារឱ្យកាន់តែមាន ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់។*

អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងបន្តធ្វើបច្ចុប្បន្នភាព និងទំនើបកម្មគ្រប់ផ្នែកទាំងអស់របស់ខ្លួនរួមមាន÷ ការកែលម្អនូវរចនាសម្ព័ន្ធ, រដ្ឋបាល, ធនធានមនុស្ស, ព័ត៌មានវិទ្យា រហូតដល់មុខងារប្រតិបត្តិការស្នូលទាំងអស់ដូចជា ផ្នែកចុះបញ្ជីពន្ធដារ, ផ្នែកផ្តល់សេវាអ្នកជាប់ពន្ធ, ផ្នែកចាត់ចែងលិខិតប្រកាស, ផ្នែកសវនកម្ម, ផ្នែកប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា។ ក្នុងរយៈពេល ៥ឆ្នាំ(២០១៣-២០១៧) ទោះបីជាបទប្បញ្ញត្តិស្តីពីពន្ធដារ និងលិខិតបទដ្ឋាននានា រួមមាន÷ ច្បាប់, អនុក្រឹត្យ, ប្រកាស, សារាចរ, សេចក្តីជូនដំណឹង និងសេចក្តីណែនាំត្រូវបានរៀបចំ និងធ្វើវិសោធនកម្មជារៀងរាល់ឆ្នាំក្តី ក៏អគ្គនាយកដ្ឋានពន្ធដារបានប្រកាន់យកនូវគោលការណ៍ទាំង ៤ ចំណុច ដែលបានចែងក្នុងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ របស់រាជរដ្ឋាភិបាលកម្ពុជារួមមាន÷

- ការប្រមូលឱ្យអស់លទ្ធភាពនូវសក្តានុពលចំណូលដែលមាននាពេលបច្ចុប្បន្ន,
- មិនបង្កើតប្រភេទពន្ធថ្មី,
- មិនដំឡើងអត្រាពន្ធ និងអាករ លើកលែងតែក្នុងករណីប៉ះប៉ូវដល់ការបាត់ចំណូល និងការការពារសុខភាព និងការការពារបរិស្ថាន
- ធានាឱ្យបាននូវភាពងាយស្រួល, សមធម៌ និងយុត្តិធម៌ ព្រមទាំងធានាប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ក្នុងការគ្រប់គ្រង និងប្រមូលចំណូលពន្ធ។

ក្រោមកិច្ចគាំទ្រ និងការលើកទឹកចិត្តយ៉ាងពេញទំហឹងពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ព្រមទាំងកិច្ចគាំទ្រ និងការផ្តល់អនុសាសន៍ណែនាំចង្អុលបង្ហាញដោយផ្ទាល់ពីសំណាក់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងធ្វើការកែលម្អគោលនយោបាយសារពើពន្ធ តាមរយៈការកែសម្រួល និងបំពេញបន្ថែមនូវបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ក្នុងន័យធ្វើឱ្យការអនុវត្តច្បាប់ស្តីពីសារពើពន្ធមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានសង្គតិភាព។ ជាលទ្ធផល អគ្គនាយកដ្ឋានពន្ធដារ បានសម្រេចនូវការងារសំខាន់ៗមួយចំនួនរួមមាន÷ ការកែប្រែរបបកំណត់ពន្ធ ដោយលុបចោលរបបម៉ៅការ និងកំណត់របបស្វ័យប្រកាសជារបបកំណត់ពន្ធតែមួយគត់នៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាការកំណត់អ្នកជាប់ពន្ធជា ៣ ប្រភេទ រួមមាន÷ អ្នកជាប់ពន្ធតូច, អ្នកជាប់ពន្ធមធ្យម, និងអ្នកជាប់ពន្ធធំ, ការលុបចោលការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទចំពោះទោចក្រយានយន្ត និងត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងគ្រឿងចក្រប្រហាក់ប្រហែល និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់ ១៥០ សេះ, ការរៀបចំដាក់ឱ្យអនុវត្តនូវវិធាន និងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធប៉ាតង់, ការរៀបចំដាក់ឱ្យអនុវត្តនូវការកំណត់វិធាន និងនីតិវិធី នៃការអនុវត្តបញ្ជីគណនេយ្យសាមញ្ញសម្រាប់អ្នកជាប់ពន្ធតូច, ការរៀបចំ និងកែសម្រួលយន្តការនៃបណ្តឹងតវ៉ាពន្ធដារ ព្រមទាំងការបង្កើតគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ, ការកែសម្រួលវាក្យសព្ទនៅក្នុងច្បាប់ស្តីពីសារពើពន្ធ (ប្រាក់ចំណូល, របបស្វ័យប្រកាស, ឆ្នាំជាប់ពន្ធ, ក្រុមហ៊ុនសហកម្មសិទ្ធិ, ក្រុមហ៊ុនមូលធន...), ការរៀបចំប្រកាសស្តីពីចំណាត់ថ្នាក់នៃអនុលោមភាព

សារពើពន្ធ, ការកែសម្រួលកម្រិតអប្បបរមានៃប្រាក់ចំណូលជាប់ពន្ធសម្រាប់រូបវន្តបុគ្គល ឬសហគ្រាសឯកបុគ្គល និងការកែសម្រួលពន្ធលើ សហគ្រាសធានារ៉ាប់រង, ការរៀបចំប្រកាសស្តីពីកាតព្វកិច្ចសារពើពន្ធចំពោះសហគ្រាសដែលអនុវត្តពហុគម្រោង, ការរៀបចំប្រកាសស្តីពីការលើកទឹកចិត្តពន្ធដារចំពោះគ្រឹះស្ថានសិក្សា, ការរៀបចំប្រកាសស្តីពី ការកំណត់នូវវិធាន និងនីតិវិធីនៃការចុះបញ្ជីពន្ធដារ, ការរៀបចំប្រកាសស្តីពី ការអនុវត្តអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃ, ការរៀបចំសេចក្តីណែនាំស្តីពីការប្រើប្រាស់វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារតាមរបបស្វ័យប្រកាស, ការរៀបចំប្រកាសស្តីពីការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើអត្ថប្រយោជន៍បន្ថែម, ការរៀបចំដាក់ឱ្យនិរាករណ៍ច្បាប់ស្តីពីការបង្កើតពន្ធសត្តឃាត, ការរៀបចំដំឡើងកម្រិតពិតាននៃបៀវត្សរ៍ដែលត្រូវជាប់ពន្ធ, ការរៀបចំ និងដាក់បញ្ចូលនូវបទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ, ការរៀបចំអនុក្រឹត្យ និងប្រកាសស្តីពីវិធាន និងនីតិវិធីនៃការលើកលែង និងអនុគ្រោះពន្ធប្រថាប់ត្រា, ការរៀបចំអនុក្រឹត្យ និងប្រកាសស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្តរបស់សហគ្រាសធុនតូចនិងមធ្យម, ការរៀបចំប្រកាសស្តីពីវិធាន និងនីតិវិធីសម្រាប់បែងចែកចំណូល និងចំណាយក្នុងចំណោមបុគ្គលទាក់ទិន (Transfer Pricing), ការរៀបចំកែសម្រួលការកំណត់មូលដ្ឋានគិតអាករ សម្រាប់បំភ្លឺសាធារណៈ, ការរៀបចំប្រកាសស្តីពីលក្ខណៈវិនិច្ឆ័យនៃការកាន់បញ្ជិកាគណនេយ្យមិនត្រឹមត្រូវ និងនីតិវិធីនៃការបង់ពន្ធអប្បបរមា, ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (DTA) រួមមាន÷ ប្រទេសសិង្ហបុរី, ចិន, ព្រុយណេ និងថៃ ដែលទទួលបានការអនុម័តដោយរដ្ឋសភា។

*ទស្សនវិស័យរបស់អគ្គនាយកដ្ឋានពន្ធដារ គឺធ្វើឱ្យស្ថាប័នប្រមូលចំណូលមួយនេះ ក្លាយជាអង្គភាពសាធារណៈមួយដែលត្រូវបានទទួលស្គាល់លើគុណភាព និងជំនាញក្នុងការប្រមូលចំណូលពន្ធដារក្នុងទិសដៅជំរុញកំណើនសេដ្ឋកិច្ច និងនិរន្តរភាព តាមរយៈការផ្តល់នូវសេវាកម្មដែលមានគុណភាពពង្រឹងការអនុវត្តច្បាប់ និងបទបញ្ញត្តិស្តីពីពន្ធដារប្រកបដោយភាពសុចរិត និងយុត្តិធម៌ចំពោះអ្នកជាប់ពន្ធទាំងអស់។*

ជាមួយគ្នានេះ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ សំដៅលើកកម្ពស់ការផ្តល់សេវាសាធារណៈឱ្យកាន់តែមានគុណភាព, រហ័សងាយស្រួល, គួរឱ្យទុកចិត្ត និងសមស្របទៅនឹងសេចក្តីត្រូវការ ជាពិសេសដើម្បីធ្វើឱ្យការងារកែទម្រង់ស្ថាប័នពន្ធដារ កាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់។ ការធ្វើទំនើបកម្មរបស់អគ្គនាយកដ្ឋានពន្ធដារបានសម្រេចនូវលទ្ធផលការងារ រួមមាន÷ ការរៀបចំមជ្ឈមណ្ឌលរក្សាទុកទិន្នន័យ (Data Storage Center) ដែលមានលក្ខណៈស្របតាមបទដ្ឋានអន្តរជាតិ(ទទួលបានវិញ្ញាបនបត្រ ISO 27001 2013 ផ្នែកប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ពីវិទ្យាស្ថានស្តង់ដារអង់គ្លេស) និងការរៀបចំប្រព័ន្ធ



គ្រប់គ្រងទិន្នន័យឱ្យទៅជា Centralized Database, ការរៀបចំដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងបង្កាន់ដៃបញ្ជាក់ពីការបង់ប្រាក់ពន្ធ (Tax Payment Receipt/Single Invoice) ដែលមានលក្ខណៈងាយស្រួលក្នុងការគ្រប់គ្រងផ្ទៀងផ្ទាត់ចំនួនប្រាក់ពន្ធដែលប្រមូលបាន, ការបង្កើត និងបន្តកែសម្រួលកម្មវិធី(Application) សម្រាប់បញ្ចូលក្នុងឧបករណ៍ Smart Device និងនៅលើគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ, ការរៀបចំបង្កើតមជ្ឈមណ្ឌលឆ្លើយតបតាមទូរស័ព្ទ (Call Center) ដើម្បីងាយស្រួលដល់ការឆ្លើយតបទៅនឹងរាល់ចម្ងល់របស់អ្នកជាប់ពន្ធទាក់ទងនឹងវិស័យពន្ធដារ, ការរៀបចំបង្កើត និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងបង់ពន្ធតាមអនឡាញ (E-Payment), ការរៀបចំ និងដាក់ឱ្យដំណើរការនូវបញ្ជរសម្រាប់ចុះបញ្ជីពន្ធដារថ្មី, ការរៀបចំ និងដាក់ឱ្យដំណើរការនូវសេវាទទួលប្រាក់ពន្ធគ្រប់ប្រភេទនៅតាមធនាគារ, ការរៀបចំឲ្យមានបញ្ជរពិគ្រោះយោបល់ពន្ធនៅអគ្គនាយកដ្ឋានពន្ធដារ និងនៅតាមសាខាពន្ធដារ, ការរៀបចំ និងដាក់ឲ្យដំណើរការការផ្តល់បណ្ណសម្គាល់ការបង់ពន្ធលើអចលនទ្រព្យ និងពន្ធលើមធ្យោបាយដឹកជញ្ជូន, ការរៀបចំ និងពង្រឹងយន្តការផ្តល់សេវា និងអប់រំតាមរយៈ Call Center, GDT Live Chat និងសិក្ខាសាលានានានៅរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្តទូទាំងប្រទេស។

ពិតណាស់ថា ការអនុវត្តកិច្ចការកែទម្រង់តែងជួបប្រទះនឹងឧបសគ្គ និងបញ្ហាប្រឈមនានាទាំងបញ្ហាបច្ចេកទេស និងបញ្ហានយោបាយដែលនេះជាការធម្មតាចៀសមិនផុត។ ដូច្នេះ ទាមទារឱ្យមានការសហការយ៉ាងពេញទំហឹងពីគ្រប់ក្រសួង- ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា និងមន្ត្រីទាំងអស់ដែលជាកម្លាំងចលករជំរុញ ក៏ដូចជាកត្តាគន្លឹះកំណត់ជោគជ័យនៃការកែទម្រង់នេះតាមការគ្រោងទុក ក្នុងស្មារតីនៃការគោរព និងលើកតម្កើងភាពជាម្ចាស់របស់កម្ពុជា ដូចប្រសាសន៍របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ថា “គ្មានលទ្ធផលណាដែលបានមក ដោយមិនមានការបង់ថ្លៃនោះទេ ហើយក៏គ្មានការកែទម្រង់ណាដែលសម្រេចបានដោយមិនមានការលះបង់នោះដែរ”។ យើងទាំងអស់គ្នាក៏ត្រូវចងចាំជាប់ជានិច្ចនូវសារនយោបាយគន្លឹះ និងជាយុទ្ធសាស្ត្ររបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ផងដែរ គឺ៖ “**បើកែទម្រង់ គឺរស់, តែបើមិនកែទម្រង់ គឺស្លាប់**”។ ក្នុងបរិបទនេះ អគ្គនាយកដ្ឋានពន្ធដារ បាននិងកំពុងអនុវត្តយ៉ាងសកម្មនូវវិធានការពាក់ព័ន្ធ ដោយផ្អែកលើគោលការណ៍អនុគ្រោះដល់កំណើន និងធានាយុត្តិធម៌, សមធម៌, សេវាល្អ, អភិបាលកិច្ចល្អ និងបង្កើនអនុលោមភាព។ ទស្សនវិស័យរបស់អគ្គនាយកដ្ឋានពន្ធដារ គឺធ្វើឱ្យស្ថាប័នប្រមូលចំណូលមួយនេះក្លាយជាអង្គភាពសាធារណៈមួយដែលត្រូវបានទទួលស្គាល់លើគុណភាព និងជំនាញក្នុងការប្រមូលចំណូលពន្ធដារក្នុងទិសដៅជំរុញកំណើនសេដ្ឋកិច្ច និងនិរន្តរភាព តាមរយៈការផ្តល់នូវសេវាកម្មដែលមានគុណភាព ពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារប្រកបដោយភាពសុចរិត និងយុត្តិធម៌ចំពោះអ្នកជាប់ពន្ធទាំងអស់ ដើម្បីជំរុញអនុលោមភាពដោយស្ម័គ្រចិត្តឈានទៅសម្រេចបាននូវការអភិវឌ្ឍ និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា៕■



# ការបង្កើនធនធានហិរញ្ញវត្ថុជូនរដ្ឋបាលថ្នាក់ក្រោមជាតិ

*ចំណូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិដែលមានរដ្ឋបាលរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងឃុំសង្កាត់ នឹងត្រូវបានបង្កើនថែមទៀតចាប់ពីឆ្នាំ២០១៨ នេះតទៅ បន្ទាប់ពីមានការសម្រេចថ្មីៗរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការបន្ថែមប្រភពចំណូលសារពើពន្ធជូនរដ្ឋបាលរាជធានី-ខេត្ត និងការបង្កើនទំហំធនធាននៃការឧបត្ថម្ភធនពីថវិការដ្ឋជូនរដ្ឋបាលក្រុង-ស្រុក*

ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានរដ្ឋបាលរាជធានី- ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងឃុំ-សង្កាត់ នឹងត្រូវបានបង្កើនថែមទៀតចាប់ពីឆ្នាំ២០១៨ នេះតទៅ បន្ទាប់ពីមានការសម្រេចថ្មីៗរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការបន្ថែមប្រភពចំណូលសារពើពន្ធជូនរដ្ឋបាលរាជធានី-ខេត្តនិងការបង្កើនទំហំធនធាននៃការឧបត្ថម្ភធនពីថវិការដ្ឋ ជូនរដ្ឋបាលក្រុងស្រុក និងឃុំ-សង្កាត់ តាមរយៈការបង្កើនអត្រាវិភាជន៍នៃចំណូលចរន្តថវិការដ្ឋដែលបានអនុម័តក្នុងឆ្នាំ។ លទ្ធផលសម្រេចបានទាំងនេះ គឺបានមកដោយសារតែជោគជ័យរបស់រាជរដ្ឋាភិបាលក្នុងការសម្រេចបានតាមការគ្រោងទុកនូវកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំក្នុងរង្វង់៧% ប្រកបដោយបរិយាប័ន្ននិងសមធម៌ ព្រមទាំងជោគជ័យនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលបានធ្វើឱ្យលទ្ធផលនៃការប្រមូលចំណូលមានកំណើនក្នុងចន្លោះ១៥% ទៅ ២០% ក្នុងមួយឆ្នាំ ក្នុងរយៈពេលចាប់ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៨។

មុនឆ្នាំ២០១៧ រដ្ឋបាលរាជធានី-ខេត្តត្រូវបានប្រគល់ជូននូវចំណូលសារពើពន្ធចំនួន ៨ ប្រភេទដែលរួមមាន÷ ពន្ធលើដីធ្លីមិនបានប្រើប្រាស់, ពន្ធប្រថាប់ត្រា, ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានយន្តគ្រប់ប្រភេទ, អាករបំភ្លឺសាធារណៈ, អាករស្នាក់នៅ, ពន្ធប៉ាតង់, ពន្ធសត្តឃាត, និងពន្ធអចលនទ្រព្យ។ ប្រភពចំណូលសារពើពន្ធទាំងនេះ គឺជាប្រភពធនធានហិរញ្ញវត្ថុដ៏ធំ និងមានសារៈសំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលរាជធានីខេត្ត ដើម្បីប្រើប្រាស់សម្រាប់ចំណាយលើការបើកបៀវត្សរ៍ និងប្រាក់ឧបត្ថម្ភជូនបុគ្គលិក មន្ត្រីរាជការ និងក្រុមប្រឹក្សា, គាំទ្រកិច្ចដំណើរការរដ្ឋបាល, និងចំណាយអភិវឌ្ឍមូលដ្ឋាន ខណៈដែលចំណូលមិនមែនសារពើពន្ធ និងការឧបត្ថម្ភធនពីថវិការដ្ឋនៅមានកម្រិត។

ដើម្បីសម្រាលបន្ទុកចំណាយ និងរួមចំណែកលើកកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋចាប់ពីឆ្នាំ២០១៧ និង



នៅដើមឆ្នាំ២០១៨ កន្លងមក, រាជរដ្ឋាភិបាលកែសម្រួលគោលនយោបាយសារពើពន្ធមួយចំនួន ដូចជា÷ លុបចោលការប្រមូលពន្ធមធ្យោបាយដឹកជញ្ជូន និងយានជំនិះប្រភេទទោចក្រយានយន្ត និងត្រីចក្រយានយន្ត, ត្រាក់ទ័រ, និងគ្រឿងយន្តប្រហាក់ប្រហែល,ជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់១៥០ សេះ, កែសម្រួល និងកំណត់ប្រាក់ពន្ធលើពន្ធមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ, កែសម្រួល លើកលែង និងអនុគ្រោះពន្ធប្រថាប់ត្រានៃការផ្ទេរកម្មសិទ្ធិក្នុងរង្វង់ញាតិ និងសិទ្ធិកាន់កាប់អចលនទ្រព្យរវាងឪពុកម្តាយ និងកូនបង្កើត រវាងប្តី និងប្រពន្ធ រវាងយាយនិងតា ព្រមទាំងចៅបង្កើត, លើកលែងពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ, ត្រាក់ទ័រ, និងជលយានយន្តដែលមានកម្លាំងដល់ ១៥០ សេះ, និងលុបចោលពន្ធសត្តឃាតជាដើម។ ទាំងនេះបានធ្វើឱ្យចំណូលសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មានការថមថយមួយចំនួនក្នុងក្របខ័ណ្ឌនៃចំណូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិ តែនៅរក្សាបានកំណើនក្នុងក្របខ័ណ្ឌនៃចំណូលថវិកាជាតិទាំងមូលជារៀងរាល់ឆ្នាំ។

ឆ្លើយតបនឹងបញ្ហាប្រឈមដែលកើតឡើងនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានសម្រេចប្រគល់ចំណូលពន្ធលើឈ្នួលអចលនទ្រព្យនិងចលនទ្រព្យរបស់រដ្ឋបាលថ្នាក់ជាតិជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមិនត្រឹមតែបំពេញនូវការថមថយដោយសារការកែសម្រួលគោលនយោបាយសារពើពន្ធនោះទេ ប៉ុន្តែបានធ្វើឱ្យធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានការកើនឡើងថែមទៀតផង។



*មុនឆ្នាំ២០១៧ រដ្ឋបាលរាជធានី-ខេត្តត្រូវបានប្រគល់ជូននូវចំណូលសារពើពន្ធចំនួន ៨ ប្រភេទដែលរួមមាន÷ ពន្ធលើដីធ្លីមិនបានប្រើប្រាស់, ពន្ធប្រថាប់ត្រា, ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានយន្តគ្រប់ប្រភេទ, អាករបំភ្លឺសាធារណៈ, អាករស្នាក់នៅ, ពន្ធប៉ាតង់, ពន្ធសត្តឃាត, និងពន្ធអចលនទ្រព្យ។*

ទន្ទឹមនឹងការបង្កើនចំណូលថវិកាសម្រាប់ជាគុណប្រយោជន៍, ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ, រដ្ឋបាលរាជធានី-ខេត្តបានធ្វើការបែងចែកសារឡើងវិញ នូវចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី-ខេត្តសាមីជូនរដ្ឋបាលក្រុង-ស្រុក-ខណ្ឌ ចំនួន៣% និងរដ្ឋបាលឃុំសង្កាត់ ១% ដែលកន្លងមក រដ្ឋបាលក្រុងស្រុក-ខណ្ឌ និងរដ្ឋបាលឃុំ-សង្កាត់ពឹងផ្អែកស្ទើរតែទាំងស្រុងលើចំណូលពីការឧបត្ថម្ភធនថវិការដ្ឋ។ ជាមួយគ្នានេះផងដែរ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក៏បាននិងកំពុងរៀបចំកែសម្រួលអនុក្រឹត្យស្តីពីការផ្ទេរធនធានថវិការដ្ឋជូនមូលនិធិក្រុង-ស្រុក និងមូលនិធិឃុំ-សង្កាត់ ដោយក្នុងនោះគ្រោងនឹងបង្កើនអត្រាវិភាជន៍ចំនួន ០.១% គឺស្មើនឹងពី១.១% ដល់១. ៥% នៃចំណូលចរន្តថវិការដ្ឋជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ សម្រាប់ឧបត្ថម្ភមូលនិធិក្រុង-ស្រុកនិងបង្កើនអត្រាវិភាជន៍ពី២. ៨% ទៅ ៣% នៃចំណូលចរន្តថវិការដ្ឋនៅឆ្នាំ២០១៩ និងបន្តកើនឡើងរៀងរាល់ឆ្នាំរហូតដល់ ៣. ៤% នៃចំណូលចរន្តថវិការដ្ឋនៅឆ្នាំ២០២៣ សម្រាប់ឧបត្ថម្ភមូលនិធិឃុំសង្កាត់៕■

# ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា

*រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានទស្សនវិស័យ និងគោលការណ៍ច្បាស់លាស់ ក្នុងការធានាបាននូវការគ្រប់គ្រងបំណុលសាធារណៈមួយ ប្រកបដោយចីរភាព តម្លាភាព គណនេយ្យភាព ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពខ្ពស់។*

ក្នុងទស្សនវិស័យខាងលើនេះ កិច្ចការពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ ត្រូវបានដាក់បញ្ចូលជាគោលបំណងមួយដ៏សំខាន់ ក្នុងចំណោមគោលបំណងជាច្រើន នៅក្នុងផ្នែកទី១ “បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា” របស់ផែនការសកម្មភាពរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ដោយអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, រាជរដ្ឋាភិបាលកម្ពុជាបានអនុម័ត និងដាក់ឱ្យអនុវត្តនូវអនុក្រឹត្យលេខ ១៣១ អនក្រ.បក ស្តីពីការគ្រប់គ្រងបំណុលសាធារណៈ នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ ដែលជាឯកសារគតិយុត្តគោល និងជាផែនទីចង្អុលផ្លូវ សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈនៅកម្ពុជា។ តាមរយៈនេះ សមិទ្ធផលធំៗជាច្រើន បានកើតឡើងជាបន្តបន្ទាប់ដូចជា÷ ការបង្កើតគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ, យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ២០១១-២០១៨, ប្រកាសស្តីពីគោលការណ៍ និងនីតិវិធីគ្រប់គ្រងការផ្តល់ឥណទានដល់សហគ្រាសសាធារណៈ, គ្រឹះស្ថានសាធារណៈ, នីតិបុគ្គលសាធារណៈដទៃទៀត និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ, បច្ចុប្បន្នកម្មយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ២០១៥-២០១៨ ដោយរួមបញ្ចូលទាំងគោលនយោបាយស្តីពីការគ្រប់គ្រងហានិភ័យបំណុលសាធារណៈ, ឯកសារស្តីពីការវិភាគចីរភាពបំណុល, និងផែនការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស។ល។

ក្នុងគោលបំណងបន្តលើកកម្ពស់តម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រងបំណុលសាធារណៈ ដូចមានចែងក្នុងមាត្រា ៣៤នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុលសាធារណៈ, រាជរដ្ឋាភិបាលដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យបំណុល ព្រមទាំងបង្កើតក្រុមការងារកត់ត្រា និងផ្ទៀងផ្ទាត់ទិន្នន័យបំណុល ដោយមានកម្មវិធីការងារច្បាស់លាស់ ពោលគឺផ្ទៀងផ្ទាត់ទាំងក្នុងដំណាក់កាលកត់ត្រា និងទាំងក្នុងដំណាក់កាលរៀបចំរបាយការណ៍ ដើម្បីធានានូវភាពអាចជឿទុកចិត្តបាននៃទិន្នន័យ និងឈានទៅបោះផ្សាយ និងផ្សព្វផ្សាយជាផ្លូវការនូវព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា ជាលើកដំបូងនៅឆ្នាំ២០១៦ ដែលជាសមិទ្ធផលថ្មីបន្ថែមទៀតរបស់រាជរដ្ឋាភិបាល នៅក្នុងកិច្ចការគ្រប់គ្រងបំណុលសាធារណៈ។ ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជាត្រូវបានរៀបរៀង និងបោះពុម្ពផ្សាយជាទៀងទាត់ រៀងរាល់មួយឆមាសម្តង ជា ២ ភាសា គឺភាសាខ្មែរ និងភាសាអង់គ្លេស ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ និងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា ដែលមានវិសាលភាពគ្របដណ្តប់លើទិន្នន័យស្តីពី÷ ១) បំណុលសាធារណៈក្រៅប្រទេស, ២)បំណុលសាធារណៈក្នុងប្រទេស, និង ៣) ការផ្តល់ឥណទានរបស់រដ្ឋដល់សហគ្រាសសាធារណៈ, គ្រឹះស្ថានសាធារណៈ, នីតិបុគ្គលសាធារណៈដទៃទៀត, និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកអាន, ទិន្នន័យទាំងអស់ត្រូវបានបែងចែកជា ៤ ក្រុមគឺ÷ ១)ការខ្ចី ២)ការដកសាច់ប្រាក់, ៣)សេវាបំណុល (ការទូទាត់ជូនឥណទានយក និងការប្រមូលពីឥណទាយិកក្រោមក្របខ័ណ្ឌនៃការផ្តល់ឥណទានរបស់រដ្ឋ), និង ៤) សន្និធិបំណុល ហើយដែលត្រូវបានចាត់ចំណាត់ប្រភេទទៅតាម÷ វិស័យ, ឥណទាយក/ឥណទាយិក, និងរូបិយប័ណ្ណ។ ទន្ទឹមនេះ ក៏មានការពន្យល់ជាលក្ខណៈបច្ចេកទេសលម្អិត អំពីនិយមន័យនៃវាក្យស័ព្ទគន្លឹះៗ ដែលប្រើនៅក្នុងព្រឹត្តិបត្រនេះផងដែរ។

*កិច្ចការពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ ត្រូវបានដាក់បញ្ចូលជាគោលបំណងមួយដ៏សំខាន់ ក្នុងចំណោមគោលបំណងជាច្រើន នៅក្នុងផ្នែកទី១ "បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា"។*

ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈនេះ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ នៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញ-



វត្ថុដែលសាធារណជនអាចទាញយកបានតាមរយៈ http://mef.gov.kh/public-debt-bulletin.html ព្រមទាំងត្រូវបានបោះពុម្ពជាសៀវភៅចែកជូនក្រសួង- ស្ថាប័នពាក់ព័ន្ធ, ស្ថានទូត, គ្រឹះស្ថានអប់រំ, ដៃគូអភិវឌ្ឍន៍, និងអង្គការក្រៅរដ្ឋាភិបាលនានា ដើម្បីប្រើប្រាស់តាមតម្រូវការជាក់ស្តែង។

តាមរយៈការចេញផ្សាយចំនួន ៥ លេខកន្លងមក ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈនេះ ទទួលបានការកោតសរសើរ និងវាយតម្លៃខ្ពស់ពីដៃគូអភិវឌ្ឍន៍ និងជំនាញការអន្តរជាតិមួយចំនួនថា ជាព្រឹត្តិបត្រស្ថិតិបំណុលដំបូងគេ ដែលមានពត៌មានគ្រប់ជ្រុងជ្រោយ និងរៀបចំបានល្អ ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលសូមអំពាវនាវដល់សាធារណជនទាំងអស់ ក៏ដូចជាតួអង្គពាក់ព័ន្ធទាំងឡាយ ជឿជាក់ និងប្រើប្រាស់តួលេខបំណុលផ្លូវការ ដែលត្រឹមត្រូវ និងជាក់ស្តែងរបស់រាជរដ្ឋាភិបាលដូចមាននៅក្នុងព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈ ជាមូលដ្ឋានចៀសវាងការប្រើប្រាស់តួលេខបំណុលពីប្រភពផ្សេង ដែលគ្រាន់តែជាតួលេខប៉ាន់ស្មាន និងគ្មានភាពច្បាស់លាស់ ឬជាតួលេខដើម្បីបំភាន់សាធារណជនក្នុងបំណងកេងចំណេញផ្នែកនយោបាយ៕■

# ការរួមចំណែករបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងតម្លាភាពថវិកានៅកម្ពុជា

## *តើការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា (OBS) គឺជាអ្វី?*

*OBS គឺជាវិធានឯករាជ្យ និងមានភាពត្រឹមត្រូវសម្រាប់ការវាស់វែងអំពីតម្លាភាព និងគណនេយ្យភាពថវិកានៅលើពិភពលោក។*

របាយការណ៍អំពីតម្លាភាពថវិកានេះ ត្រូវបានរៀបចំឡើងដោយអ្នកជំនាញខាងថវិកា តាមរយៈការកំណត់នូវកម្រងសំណួរដែលមានលក្ខណៈស្តង់ដារអន្តរជាតិ, ជាពិសេសធ្វើការវាស់វែងលើការអង្កេតតាមទិដ្ឋភាពជាក់ស្តែង ដោយប្រើប្រាស់ក្របខ័ណ្ឌសូចនាករចំនួន១៤៥ និងមានវិសាលភាពគ្របដណ្តប់ទៅលើ ១១៥ ប្រទេស។ គិតត្រឹម ឆ្នាំ២០១៨ នេះ របាយការណ៍ OBS ត្រូវបានចេញផ្សាយចំនួន ៦ ដងរួចមកហើយគឺនៅឆ្នាំ២០០៦, ២០០៨, ២០១០, ២០១២, ២០១៥, និង២០១៧។

### តើការអង្កេតនេះធ្វើការវាស់ស្ទង់លើទិដ្ឋភាពអ្វីខ្លះ?




IBP ដែលជាស្ថាប័នមិនមែនរដ្ឋាភិបាលអន្តរជាតិ បានរៀបចំការអង្កេតការបើកចំហថវិកានៅប្រទេសជុំវិញពិភពលោកក្នុងរយៈពេល ២ ឆ្នាំម្តង។ ការអង្កេតលើការបើកចំហថវិកានេះ ត្រូវបានវាស់វែងលើ ៣ ផ្នែករួមមាន÷ ការផ្សព្វផ្សាយឯកសារពាក់ព័ន្ធព័ត៌មានថវិកា, ការចូលរួមរបស់សាធារណជន និងការត្រួតពិនិត្យថវិកា (Budget Oversight)។ ការអង្កេតនេះ ប្រើប្រាស់វិធីសាស្ត្រកម្រងសំណួរដែលមានសំណុំលក្ខណៈវិនិច្ឆ័យ ដោយមានការទទួលស្គាល់ជាអន្តរជាតិ និងបង្កើតឡើងដោយអង្គការពហុភាគី រួមមាន÷ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF), អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD), អង្គការអន្តរជាតិនៃស្ថាប័នសវនកម្មជាន់ខ្ពស់(INTOSAI) និងអង្គការផ្តួចផ្តើមជាសកលសម្រាប់តម្លាភាពសារពើពន្ធ (GIFT) ។

### ❖ លទ្ធផលនៃការអង្កេតជាសកលឆ្នាំ ២០១៧

លទ្ធផលនៃការអង្កេតការបើកចំហថវិកាឆ្នាំ២០១៧ នៃប្រទេសជុំវិញពិភពលោក បានបង្ហាញឱ្យឃើញនូវលទ្ធផលធំៗចំនួន ៣ គឺ÷

១). សន្ទស្សន៍នៃការបើកចំហថវិកាជាសកល (Open Budget Index — OBI) សម្រាប់ឆ្នាំ២០១៧នៅមានកម្រិត ដោយមានពិន្ទុសរុបជាមធ្យម ៤២ លើ ១០០ ក្នុងចំណោមប្រទេសចំនួន១១៥ ដែលបានធ្វើការអង្កេត។ ក្នុងនោះ ប្រទេសចំនួន៨៩ ពុំបានផ្តល់ព័ត៌មានគ្រប់គ្រាន់អំពីថវិកាជាតិរបស់ខ្លួននៅឡើយ។ បើពិនិត្យមើលការអង្កេតក្នុងតំបន់វិញ មានតែប្រទេសម៉ាឡេស៊ី ថៃ ឥណ្ឌូនេស៊ី និងហ្វីលីពីនប៉ុណ្ណោះដែលទទួលបានពិន្ទុលើស ៤២។

២). ការផ្សព្វផ្សាយឯកសារថវិកាទាំង៨ មាននិន្នាការធ្លាក់ចុះជាសកលសម្រាប់ឆ្នាំ២០១៧ រួមមាន÷ ព័ត៌មានពីម៉ាក្រូសេដ្ឋកិច្ច និងអាទិភាពគោលនយោបាយធ្លាក់ចុះចំនួន០៨ពិន្ទុ, សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាលធ្លាក់ចុះ ០៥ ពិន្ទុ, ថវិកាដែលបានអនុម័តធ្លាក់ចុះ ០៨ ពិន្ទុ, របាយការណ៍ក្នុងឆ្នាំធ្លាក់ចុះ០៩ពិន្ទុ, របាយការណ៍ពាក់កណ្តាលឆ្នាំ ធ្លាក់ចុះ ០៤ ពិន្ទុ, របាយការណ៍ប្រចាំឆ្នាំបានធ្លាក់ចុះ ០៥ ពិន្ទុ, របាយ-ការណ៍ថវិកាសម្រាប់ប្រជាជន គឺពុំមានការប្រែប្រួលឡើយ និងរបាយការណ៍សវនកម្មមានការកើនឡើងចំនួន២ពិន្ទុ។

៣). ពុំមានប្រទេសណាមួយដែលបានធ្វើការអង្កេតនេះ បានអនុវត្តមុខងារទាំង ៣ បានពេញលេញនោះទេ។

### វិធីសាស្ត្រនៃការស្រាវជ្រាវ



ការអង្កេតនៃការផ្សព្វផ្សាយព័ត៌មានថវិកា ត្រូវបានរៀបចំឡើងពីការបំពេញកម្រងសំណួរសម្រាប់ប្រទេសនីមួយៗ ដោយអ្នកជំនាញថវិកាឯករាជ្យដែលពុំជាប់ទាក់ទងនឹងរដ្ឋាភិបាលរបស់ប្រទេសនីមួយៗ ឡើយ។

សេចក្ដីព្រាងលទ្ធផលរបស់ប្រទេសនីមួយៗ ត្រូវបានត្រួតពិនិត្យដោយឡែកៗពីគ្នា ដោយអ្នកជំនាញអនាមិក ដែលពុំមានជាប់ទាក់ទងជាមួយនឹងរដ្ឋាភិបាលឡើយ។

ទន្ទឹមនឹងនេះ អង្គការភាពជាដៃគូថវិកាអន្តរជាតិ (IBP) ជួបពិភាក្សាផ្ទាល់ជាមួយមន្ត្រីថវិកានៃប្រទេសនីមួយៗ ដើម្បីផ្ដល់អនុសាសន៍លើសេចក្ដីព្រាងលទ្ធផលនៃការអង្កេតនេះ និងធ្វើការពិនិត្យមើលអនុសាសន៍ទាំងនោះ មុនពេលរៀបចំបញ្ចប់សេចក្ដីព្រាងលទ្ធផលចុងក្រោយ ។

ក្រុមអ្នកស្រាវជ្រាវ ធ្វើការឆ្លើយតបទៅនឹងធាតុចូលរបស់ក្រុមត្រួតពិនិត្យ និងរដ្ឋាភិបាលនៃប្រទេសនីមួយៗ ហើយប្រសិនបើអាចទៅរួច ក្រុមការងារ IBP នឹងវិនិច្ឆ័យលើចម្លើយដែលមានភាពលំបាកនានា ដើម្បីធានាបាននូវភាពត្រឹមត្រូវ និងប្រទាក់ក្រឡាគ្នានៃប្រទេសនីមួយៗ ដែលបានចូលរួមការអង្កេតនេះ ផងដែរ ។

## លទ្ធផលអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិការបស់កម្ពុជា ឆ្នាំ២០១៧

កម្ពុជាបានចូលរួមសហការជាមួយ IBP និងNGOF ក្នុងការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាចាប់ពីឆ្នាំ២០០៨មក។ លទ្ធផលអង្កេតឆ្នាំ២០១៧ បានបង្ហាញថា កម្ពុជាទទួលបានពិន្ទុ ២០ លើការបើកចំហព័ត៌មានថវិកា, ពិន្ទុ ៤ នៃការចូលរួមរបស់សាធារណជន, និងពិន្ទុ៥៥ នៃការត្រួតពិនិត្យថវិកា (Budget Oversight)។ ពិន្ទុនៃការបើកចំហថវិកាឆ្នាំ២០១៧ គឺជាពិន្ទុខ្ពស់ជាងគេបំផុតចាប់តាំងពីត្រូវបានធ្វើការអង្កេត ក៏ប៉ុន្តែខ្ពស់ជាងតែ ២ ប្រទេសប៉ុណ្ណោះ គឺវៀតណាមបានពិន្ទុ ១៥ និងមីយ៉ាន់ម៉ាបានពិន្ទុ ០៧។ នៅក្នុងតំបន់ទីម័រខាងកើតបានពិន្ទុ៤០, ម៉ាឡេស៊ីបានពិន្ទុ៤៦, ថៃបានពិន្ទុ៥៦, ឥណ្ឌូនេស៊ីបានពិន្ទុ៦៤ និងហ្វីលីពីនបានពិន្ទុ៦៧ ដែលជាពិន្ទុខ្ពស់ជាងគេ។

កត្តាដែលនាំឱ្យកម្ពុជាមានការកើនឡើងនូវពិន្ទុនេះ គឺដោយសារកម្ពុជាបានផ្សព្វផ្សាយរបាយការណ៍ពាក់កណ្ដាលឆ្នាំ, របាយការណ៍សវនកម្ម និងរបាយការណ៍ថវិកាសម្រាប់ប្រជាជនបានទាន់ពេលវេលា។ តាមរយៈការអង្កេតរបស់ IBP ក្នុងឆ្នាំ២០១៧, កម្ពុជាបានផ្សព្វផ្សាយព័ត៌មានថវិកាជាសាធារណៈបានចំនួន៦។ ទោះជាយ៉ាងនេះក្ដី ឯកសារដែលបានផ្សព្វផ្សាយនោះ មានឯកសារចំនួន៥ ពុំទាន់បានផ្សព្វផ្សាយឱ្យមានភាពទូលំទូលាយនៅឡើយ លើកលែងតែឯកសារថវិកាដែលបានអនុម័តរួចប៉ុណ្ណោះ។ ក្រៅពីនេះ របាយការណ៍ថវិកាសម្រាប់ប្រជាជន, របាយការណ៍ថវិកាពាក់កណ្ដាលឆ្នាំ និងរបាយការណ៍សវនកម្ម គឺបានផ្សព្វផ្សាយនៅក្នុងកម្រិតអប្បបរមានៅឡើយ។ រីឯរបាយការណ៍ត្រៀមរៀបចំថវិកាវិញ បានផ្សព្វផ្សាយនៅមានកម្រិតនៅឡើយ ខណៈដែលរបាយការណ៍ថវិកាក្នុងឆ្នាំបានផ្សព្វផ្សាយទូលំទូលាយ។ ដោយឡែក ឯកសារចំនួន ០២ រួមមាន÷ សេចក្ដីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល និងរបាយការណ៍ថវិកាប្រចាំឆ្នាំ បានផ្សព្វផ្សាយយឺតជាងពេលវេលានៃការបិទបញ្ចប់ការអង្កេត, ដែលការផ្សព្វផ្សាយនេះត្រូវចាត់ទុកថាពុំបានធ្វើការផ្សព្វផ្សាយឡើយ។

*លទ្ធផលអង្កេតឆ្នាំ២០១៧ បានបង្ហាញថាកម្ពុជាទទួលបានពិន្ទុ២០ លើការបើកចំហព័ត៌មានថវិកា, ពិន្ទុ០៤ នៃការចូលរួមរបស់សាធារណជន, និងពិន្ទុ៥៥ នៃការត្រួតពិនិត្យថវិកា (Budget Oversight)។*

ផ្នែកការចូលរួមពីសាធារណជនក្នុងដំណើរការរៀបចំថវិកា កម្ពុជាទទួលបានពិន្ទុ ០៤ លើ១០០ គឺទាបជាងពិន្ទុមធ្យមសកល១២ លើ១០០។ បើប្រៀបធៀបក្នុងតំបន់ កម្ពុជាមានពិន្ទុទាបជាងវៀតណាម និងទីម័រខាងកើតបាន ០៧ ពិន្ទុ, ម៉ាឡេស៊ីបាន ០៩ ពិន្ទុ, ថៃ និងឥណ្ឌូនេស៊ីបាន ២២ ពិន្ទុ ខណៈដែលហ្វីលីពីនបានពិន្ទុខ្ពស់ជាងគេ គឺរហូតដល់ ៤១ ពិន្ទុ។ ទោះបីជាយ៉ាងណាក៏ដោយ, កម្ពុជាទទួលបានពិន្ទុល្អនៃការត្រួតពិនិត្យថវិកា (Budget Oversight) ពីព្រោះលទ្ធផលនៃការអង្កេតជាសកល ពុំមានប្រទេសណាមួយទទួលបានពិន្ទុខ្ពស់ជាង ៦០ ឡើយ ។

## ឧត្តមានុវត្តន៍របស់ប្រទេសផ្សេងៗនៃការចូលរួមពីប្រជាជនក្នុងដំណើរការរៀបចំថវិកា

ផ្អែកលើករណីសិក្សា បទពិសោធនៃការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ២០១៧ (Open Budget Survey) កន្លងទៅ បានបង្ហាញឱ្យឃើញថាយន្តការចំនួន៤ នៃការបើកទូលាយដល់សាធារ-

ណជនក្នុងដំណើរការរៀបចំថវិកាត្រូវបានប្រទេសផ្សេងៗ យកមកអនុវត្ត ដើម្បីបង្កើនពិន្ទុក្នុងផ្នែកនេះឱ្យបានខ្ពស់រួមមាន៖

- គោលនយោបាយពិគ្រោះយោបល់៖ ផ្តោតលើបញ្ហាជាក់លាក់ណាមួយ ហើយបញ្ហានោះនឹងមិនប៉ះពាល់ដល់ថវិកាជាតិប្រចាំឆ្នាំនោះទេ (អនុវត្តដោយប្រទេសម៉ុលដាវី, ក្រូអាត, សាធារណរដ្ឋឆែក និងចក្រភពអង់គ្លេស)។
- រៀបចំក្រុមការងារតាមវិស័យ៖ ក្រសួងហិរញ្ញវត្ថុ, ស្ថាប័ន និងតួអង្គពាក់ព័ន្ធធ្វើការពិភាក្សាលើផែនការតាមវិស័យ និងវិស័យអាទិភាព (អនុវត្តដោយប្រទេសកាហ្សាក់ស្ថាន និងរុស្ស៊ី)។
- យន្តការរាយការណ៍លើអ៊ីនធើណែត៖ រៀបចំជាគេហទំព័រសម្រាប់សាធារណជនចូលទៅធ្វើការចុះឈ្មោះ ដើម្បីវាយតម្លៃពីថវិកាជាតិ និងការរាយការណ៍ពីចំណុចមិនល្អណាមួយ (អនុវត្តដោយប្រទេសកូរ៉េខាងត្បូង, ម៉ាឡេស៊ី, ឥណ្ឌូនេស៊ី និងម៉ិចស៊ិកូ)។
- អភិក្រមពិគ្រោះយោបល់ពីក្រោមឡើងលើ (Bottom-Up Consultation Approach)៖ ធ្វើការពិគ្រោះយោបល់នៅថ្នាក់មូលដ្ឋានលើសំណើថវិកាជាមុនសិន មុននឹងជូនដំណឹងទៅភ្នាក់ងារថវិកា, បន្ទាប់មកនឹងដាក់ជូនក្រសួងហិរញ្ញវត្ថុ ពិនិត្យ និងសម្រេច (អនុវត្តដោយប្រទេសហ្វីលីពីន, ឥណ្ឌូនេស៊ី និងបុតស្វាណា)។

*កត្តាដែលនាំឱ្យកម្ពុជាមានការកើនឡើងពិន្ទុខ្ពស់នេះ គឺកម្ពុជាបានផ្សព្វផ្សាយរបាយការណ៍ពាក់កណ្តាលឆ្នាំ, របាយការណ៍សវនកម្ម, និងរបាយការណ៍ថវិកាសម្រាប់ប្រជាជនបានទាន់ពេលវេលា។*

### ❖ គោលនយោបាយសម្រាប់និសដៅការងារ

កម្ពុជាមានលទ្ធភាពក្នុងការបង្កើនសន្ទស្សន៍បើកចំហថវិកាបន្ថែមទៀត ដោយរក្សាឱ្យបាននូវកិច្ចខិតខំប្រឹងប្រែងកន្លងមក និងអាចពិនិត្យលទ្ធភាពលើចំណុចមួយចំនួនដូចខាងក្រោម៖

- ការផ្សព្វផ្សាយច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំ៖ ឯកសារនេះត្រូវបានផ្សព្វផ្សាយជារៀងរាល់ឆ្នាំ ប៉ុន្តែច្បាប់នេះ ត្រូវផ្សព្វផ្សាយជាផ្លូវការរយៈពេល ២ ឆ្នាំក្រោយឆ្នាំសារពើពន្ធ ដោយសារត្រូវអនុម័តដោយសភាជាតិ និងឡាយព្រះហត្ថលេខាដោយព្រះមហាក្សត្រ។ តាមនិយមន័យនៃការអង្កេត, ការអនុវត្តបែបនេះ ត្រូវចាត់ទុកថាជាការបើកចំហព័ត៌មានថវិកាយឺត និងត្រូវចាត់ទុកថាមិនបានផ្សព្វផ្សាយតែម្តង។ បញ្ហាប្រឈមនេះ អាចដោះស្រាយបាន ប្រសិនបើការផ្សព្វផ្សាយអាចធ្វើបានជាសេចក្តីព្រាងច្បាប់ទូទាត់ថវិកា ឬសង្ខេបឱ្យបានមុនឆ្នាំ។
- ការផ្សព្វផ្សាយសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ៖ ការផ្សព្វផ្សាយឯកសារនេះមានសារៈសំខាន់ជាងគេបំផុតក្នុងចំណោមឯកសារទាំងអស់។ ប្រសិនបើកម្ពុជាសម្រេចផ្សព្វផ្សាយសេចក្តីព្រាងច្បាប់ថវិកានេះ ពិន្ទុផ្នែកនេះ នឹងកើនឡើងខ្លាំង។
- ពង្រីកវិសាលភាពនៃរបាយការណ៍សវនកម្មនៅគ្រប់ចំណាយរបស់រាជរដ្ឋា-

## ចំនួនសូចនាករទាំង១០៩ ដើម្បីវាស់វែងលើឯកសារទាំង៨ ៖

| ឯកសារថវិកា | ចំនួនសំណួរ |
| --- | --- |
| របាយការណ៍ត្រៀមរៀបចំថវិកា | ៦ |
| សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល | ៥៤ |
| ឯកសារថវិកាដែលបានអនុម័តរួច | ៦ |
| របាយការណ៍ថវិកាសម្រាប់ប្រជាជន | ៤ |
| របាយការណ៍ថវិកាក្នុងឆ្នាំ | ៩ |
| របាយការណ៍ថវិកាពាក់កណ្តាលឆ្នាំ | ៩ |
| របាយការណ៍ថវិកាប្រចាំឆ្នាំ | ១៤ |
| របាយការណ៍សវនកម្ម | ៧ |

## ឯកសារថវិកាទាំង៨ ដែលកម្ពុជាបានផ្សព្វផ្សាយជាសាធារណៈសម្រាប់ឆ្នាំ២០០៨ ដល់ឆ្នាំ២០១៧

| ឯកសារ | ២០០៨ | ២០១០ | ២០១២ | ២០១៥ | ២០១៧ |
|---|---|---|---|---|---|
| របាយការណ៍បុរេថវិកា | 🟡 | 🟢 | 🟢 | 🟢 | 🟢 |
| សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល | 🟡 | 🟡 | 🟡 | 🟡 | 🟡 |
| ថវិកាដែលបានអនុម័ត | 🟢 | 🟢 | 🟢 | 🟢 | 🟢 |
| របាយការណ៍ថវិកាប្រជាជន | 🟤 | 🟤 | 🟤 | 🟡 | 🟢 |
| របាយការណ៍ក្នុងឆ្នាំ | 🟢 | 🟢 | 🟢 | 🟡 | 🟢 |
| របាយការណ៍ពាក់កណ្តាលឆ្នាំ | 🟡 | 🟡 | 🟡 | 🟡 | 🟢 |
| របាយការណ៍ប្រចាំឆ្នាំ | 🟢 | 🟢 | 🟢 | 🟤 | 🟡 |
| របាយការណ៍សវនកម្ម | 🟡 | 🟡 | 🟡 | 🟤 | 🟢 |

🟢 ផ្សព្វផ្សាយជាសាធារណៈ 🟤 មិនបានរៀបចំ ឬផលិត

🟡 ផលិតយឺត ឬសម្រាប់តែប្រើប្រាស់ផ្ទៃក្នុង

ភិបាល÷របាយការណ៍សវនកម្មលម្អិតបន្ថែម ត្រូវបានផ្សព្វផ្សាយ ដែលបានធ្វើឱ្យពិន្ទុ នៃការបើកចំហថវិកាកើនឡើងក្នុងឆ្នាំ២០១៧ ប៉ុន្តែរបាយការណ៍ទាំងនោះបានឆ្លុះបញ្ចាំងតែពីប្រតិបត្តិការរួមរបស់រាជរដ្ឋាភិបាលនៅឡើយ។ ពិន្ទុផ្នែកនេះ អាចនឹងកើនឡើងបន្ថែមទៀតប្រសិនបើរបាយការណ៍សវនកម្មកាន់តែលម្អិតត្រូវបានផ្សព្វផ្សាយ។ ជាទស្សនៈ របាយការណ៍សវនកម្មគួររក្សាទុកការផ្សព្វផ្សាយត្រឹមប៉ុណ្ណេះសិន និងបន្តលើកកម្ពស់ជាបន្តបន្ទាប់តាមវឌ្ឍនភាពនៃប្រព័ន្ធ។

- បង្កើនការចូលរួមរបស់ប្រជាជន ក្នុងដំណើរការរៀបចំថវិកា÷ឆ្លងតាមការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ២០១៧ ប្រទេសកម្ពុជាទទួលបានពិន្ទុ៤ នៃការចូលរួមពីសាធារណជនក្នុងដំណើរការថវិកា ដែលជាពិន្ទុលើប្រទេសចំនួន៨ ក្នុងចំណោមប្រទេសចំនួន១០០ដែលត្រូវបានធ្វើការអង្កេត គឺលើប្រទេសសេណេហ្គាល់,ទុយណេស៊ី, អាល់បានី, សេប៊ី, អេស្ប៉ាញ, សូម៉ាលី, ស៊ូដង់ខាងត្បូង និងកាតា។ តាមការអនុវត្តកន្លងមក, ការរៀបចំសិក្ខាសាលាប្រចាំឆ្នាំ ដើម្បីប្រមូលធាតុចូលក្នុងការរៀបចំថវិកា គឺជាវឌ្ឍនភាពសំខាន់ក្នុងផ្នែកនេះ។ កិច្ចការនេះ គួរបន្តធ្វើឱ្យក្លាយជាការងារប្រចាំឆ្នាំក្នុងការរៀបចំថវិកា និងបន្តបើកចំហឱ្យមានការចូលរួមបានទូលំទូលាយ និងចូលរួមឱ្យបានទូលំទូលាយ នឹងអាចជួយឱ្យពិន្ទុផ្នែកនេះកើនឡើងខ្ពស់។ ក្នុងន័យនេះផងដែរ កម្ពុជានឹងទទួលបានពិន្ទុល្អប្រសើរ ឬខ្ពស់ជាងនេះ ក្នុងករណីដែលរាជរដ្ឋាភិបាល អាចមានលទ្ធភាពអនុវត្តនូវយន្តការខាងលើបានចំនួន ១ ឬ ២ ដូចបានលើកឡើងក្នុងឧត្តមានុវត្តន៍របស់ប្រទេសផ្សេងៗ នៃការចូលរួមពីប្រជាជនក្នុងដំណើរការរៀបចំថវិកា។ ម្យ៉ាងវិញទៀត ក្រសួងក៏អាចប្រើនូវយន្តការផ្សេងទៀត ដែលសាកសមនឹងបរិបទកម្ពុជាផងដែរ។

- ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ÷ គឺជួយជំរុញការរៀបចំរបាយការណ៍ថវិកាបានទាន់ពេលវេលា ជាពិសេសការដាក់ឱ្យអនុវត្តនូវចំណាត់ថ្នាក់ថវិកាទាំង៧ (ចំណាត់ថ្នាក់រដ្ឋបាល, ភូមិសាស្ត្រ, សេដ្ឋកិច្ច, កម្មវិធី, មុខងារ, គម្រោង, និងមូលនិធិ) ទៅក្នុង FMIS នឹងធ្វើឱ្យព័ត៌មានអំពីថវិកាកាន់តែលម្អិត និងគ្រប់ជ្រុងជ្រោយ។ ការណ៍នេះ នឹងជួយឱ្យពិន្ទុតម្លាភាពថវិកាកម្ពុជាមានការកើនឡើងខ្ពស់សម្រាប់ការអង្កេតឆ្នាំបន្តបន្ទាប់ទៀត៕■

# លទ្ធផលនៃការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៧

*កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាកម្មវិធីកែទម្រង់ស្នូលមួយនៃកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឈានឆ្ពោះទៅពង្រឹងអភិបាលកិច្ច។*

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺមានចក្ខុវិស័យប្រកបដោយមហិច្ឆិតា និងប្រាកដនិយម ពោលគឺដើម្បីកសាងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជាឱ្យស្របតាមស្តង់ដារអន្តរជាតិ ដែលមានគោលដៅផ្លាស់ប្តូរប្រព័ន្ធដែលផ្តោតលើធាតុចូល និងមជ្ឈការ ឆ្ពោះទៅប្រព័ន្ធដែលផ្តោតលើធាតុចេញ ឬលទ្ធផល និងវិមជ្ឈការ។ ម្យ៉ាងទៀត ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរឹងមាំ នឹងឈានទៅសម្រេចបានលទ្ធផលចុងក្រោយទាំង៣ រួមមាន÷ បូរណភាពនៃការគោរពវិន័យថវិកា, ប្រសិទ្ធភាពនៃថវិកាទាំងក្នុងផ្នែកវិភាជន៍ និងផ្នែកប្រតិបត្តិការ ព្រមទាំងស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានផ្តល់អាទិភាព និងចាត់ទុកភាពរឹងមាំនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាឆ្អឹងខ្នងនៃការអនុវត្តកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាឱ្យសម្រេចបានប្រកបដោយជោគជ័យ និងចីរភាព។ ក្នុងន័យនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិតជាមានសារៈសំខាន់ក្នុងការជំរុញ ដើម្បីឱ្យមានការរីកចម្រើនប្រកបដោយជវភាព, វិបុលភាព និងបរិយាប័ន្ន។ អាស្រ័យហេតុនេះ បណ្តាដៃគូអភិវឌ្ឍន៍ រួមមាន÷ មូលនិធិរូបិយវត្ថុអន្តរជាតិ, ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី បានវាយតម្លៃខ្ពស់លើការខិតខំកែទម្រង់របស់រាជរដ្ឋាភិបាល និងមានជំនឿថាសេដ្ឋកិច្ចកម្ពុជា នៅតែអាចបន្តកំណើនខ្ពស់ និងរឹងមាំ ក្នុងរយៈពេលខ្លី និងមធ្យម ខាងមុខនេះ។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ត្រូវបានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) កំណត់ និងដាក់ចេញនូវគោលដៅអាទិភាពចំនួន៣ រួមមាន÷ (១). ពង្រឹងការគ្រប់គ្រង និងអនុវត្តផែនការប្រមូលចំណូល, (២). ពង្រឹង និងពង្រីកការដាក់ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Financial Management Information System-FMIS) និង (៣). ពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី។

*ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រឹងមាំ នឹងឈានទៅសម្រេចបាន លទ្ធផលចុងក្រោយទាំង៣ រួមមាន÷ បូរណភាពនៃការគោរពវិន័យថវិកា, ប្រសិទ្ធភាពនៃថវិកាទាំងក្នុងផ្នែក វិភាជន៍ និងផ្នែកប្រតិបត្តិការ និងស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។*

ទន្ទឹមនេះ អនុលោមតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៩ សរ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពី "វិធាន និងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ" **គ.ហ.ស.** បានធ្វើការត្រួតពិនិត្យវឌ្ឍនភាព និងបានរៀបចំរបាយការណ៍ត្រួតពិនិត្យជាប្រចាំត្រីមាស និងប្រចាំឆ្នាំ។ ជាក់ស្តែងក្នុងការរៀបចំរបាយការណ៍ត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០១៧ **គ.ហ.ស.** មិនត្រឹមតែធ្វើការត្រួតពិនិត្យសមិទ្ធកម្មនៃអង្គភាពចូលរួមអនុវត្តប៉ុណ្ណោះទេ តែថែមទាំងធ្វើការវាយតម្លៃលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូលផងដែរ ដើម្បីកំណត់ភាពខ្លាំង និងភាពខ្សោយសំដៅពង្រឹង និងបន្តកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈពីមួយឆ្នាំទៅមួយឆ្នាំ។

តាមរយៈលទ្ធផលនៃការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្របតាមក្របខណ្ឌផែនការសកម្មភាព ដំណាក់កាលទី៣ បានឆ្លុះបញ្ចាំងនូវវឌ្ឍនភាពដូចខាងក្រោម÷

- ការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលប្រកបដោយភាពម៉ឺងម៉ាត់ និងមុតស្រួចនេះ បានធ្វើឱ្យកំណើនចំណូលកើនឡើងជាលំដាប់ បើគិតជាមធ្យមចាប់ពីឆ្នាំ២០១៣-២០១៧ ចំណូលបានកើនឡើងប្រមាណ ០,៩៦ ពិន្ទុភាគរយនៃ ផ. ស. ស. ក្នុងមួយឆ្នាំ ។
- ប្រព័ន្ធ FMIS ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តដំណាក់កាលទី១ នៅឆ្នាំ២០១៤ និងដំណាក់កាលទី២ នៅឆ្នាំ២០១៧។

មុខងារស្នូល និងចំណាត់ថ្នាក់ថវិកា ត្រូវបានរៀបចំដាក់បញ្ចូលក្នុងប្រព័ន្ធFMIS ជាបន្តបន្ទាប់ទៅតាមផែនការពង្រីកការអនុវត្តប្រព័ន្ធ FMIS។ ជាក់ស្តែង មុខងារស្នូលនៃប្រព័ន្ធនេះ មានចំនួន៦ រួមមាន (១). មុខងារវិភាជន៍ថវិកា, (២). មុខងារគណនីត្រូវសង, (៣). មុខងារគណនីត្រូវទារ, (៤). មុខងារគ្រប់គ្រងសាច់ប្រាក់, (៥). មុខងារទិញ និង(៦). មុខងារសៀវភៅធំ។ ទន្ទឹមនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើការកែសម្រួលប្លង់គណនេយ្យថ្មីឱ្យស្របតាមស្តង់ដារអន្តរជាតិ និងបានរៀបចំ និងដាក់ឱ្យអនុវត្តប្រកាសស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់ថវិកាទាំង៧ រួមមាន÷ (១). ចំណាត់ថ្នាក់អង្គភាពប្រតិបត្តិ និងរដ្ឋបាល, (២). ចំណាត់ថ្នាក់ភូមិសាស្ត្រ, (៣). ចំណាត់ថ្នាក់សេដ្ឋកិច្ច, (៤). ចំណាត់ថ្នាក់កម្មវិធី, (៥). ចំណាត់ថ្នាក់មុខងារ, (៦). ចំណាត់ថ្នាក់គម្រោង និង(៧). ចំណាត់ថ្នាក់មូលនិធិ។ បន្ថែមពីនេះ នៅឆ្នាំ២០១៨ ក្រសួង-ស្ថាប័នចំនួន១០ អនុវត្តប្រព័ន្ធ FMIS រួមមាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសុខាភិបាល, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងកិច្ចការនារី, ក្រសួងបរិស្ថាន, ក្រសួងមុខងារសាធារណៈ, ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

- ការអនុវត្តថវិកាកម្មវិធី ត្រូវបាននិងកំពុងដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង ស្ថាប័ន និងគ្រប់រដ្ឋបាលរាជធានី-ខេត្ត។ ជាវឌ្ឍនភាព ក្រសួង-ស្ថាប័ន ចំនួន១០ អនុវត្តថវិកាកម្មវិធីសម្រាប់ឆ្នាំ២០១៥, ក្រសួង-ស្ថាប័ន ចំនួន ១៥ បន្ថែមសម្រាប់ឆ្នាំ ២០១៦ និងក្រសួង-ស្ថាប័ន ចំនួន ១១ បន្ថែមសម្រាប់ឆ្នាំ ២០១៧ និងក្រសួង-ស្ថាប័ន ចំនួន៣ បន្ថែមសម្រាប់ឆ្នាំ ២០១៨ ដែលសរុបចំនួន ៣៩។ រីឯគ្រប់រដ្ឋបាលរាជធានី-ខេត្ត ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីចាប់ពីឆ្នាំ២០១៧-២០២០។ ជាមួយគ្នានេះ ដើម្បីកំណត់ទិសដៅប្រព័ន្ធថវិកាឱ្យបានច្បាស់លាស់ និងប្រាកដនិយម, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ ហើយដែលត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី នៅថ្ងៃទី ១២ ខែមករា ឆ្នាំ ២០១៨ ដោយកំណត់ប្រព័ន្ធថវិកាកម្ពុជាគឺជាប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ឬថវិកាសមិទ្ធកម្ម។

តាមរយៈលទ្ធផលនៃការត្រួតពិនិត្យវឌ្ឍនភាពកម្មវិធីកែទម្រង់ឆ្នាំ២ ០ ១ ៧ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានសុទិដ្ឋិនិយម និងវាយតម្លៃជារួមថា÷

- ភាពជឿទុកចិត្តនៃថវិកានៅតែរក្សាបានជាសារវន្ត ប៉ុន្តែទាមទារឱ្យមានការពង្រឹងការព្យាករ និងការអនុវត្តកម្មវិធីចំណូលចំណាយប្រចាំត្រីមាស,
- ប្រព័ន្ធគណនេយ្យភាពបាននិងកំពុងកសាងតាមរយៈការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS ដំណាក់កាលទី២ ជាមួយនឹងភាពប្រុងប្រយ័ត្នខ្ពស់,
- ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធីជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំ និងកំណត់ការផ្លាស់ប្តូរប្រព័ន្ធថវិកាកម្ពុជា,
- យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ជាសមាសធាតុដ៏សំខាន់សម្រាប់កំណត់ទិសដៅនៃគណនេយ្យភាពសមិទ្ធកម្មដែលជាគោលដៅចុងក្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ,
- ការរៀបចំប្រព័ន្ធលើកទឹកចិត្តនឹងជំរុញធ្វើស្ថាប័ននីយកម្មឱ្យស្របតាមទិសដៅនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

*យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី នៅថ្ងៃទី ១២ ខែមករា ឆ្នាំ២០១៨ ដោយកំណត់ប្រព័ន្ធថវិកាកម្ពុជា ជាប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ឬថវិកាសមិទ្ធកម្ម។*

ទន្ទឹមនេះ ដើម្បីកំណត់ភាពខ្លាំង និងភាពខ្សោយនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានអនុញ្ញាតឱ្យអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រើប្រាស់ក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (Framework for Public Expenditure and Financial Accountability) ឆ្នាំ២០១១។

តាមរយៈលទ្ធផលនៃការវាយតម្លៃ PEFA ឆ្នាំ២០១៧ បង្ហាញថាប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ គឺមានភាពល្អប្រសើរជាងការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៥ ក្នុងនោះសូចនាករសមិទ្ធកម្មចំនួន ៩ បានកើនឡើងពិន្ទុ ដោយរួមមាន PI-2, PI-4, PI-7, PI-9, PI-10, PI-13, PI-14, PI-18 និង PI-19 និងធ្លាក់ពិន្ទុចំនួន ២ រួមមាន PI-3 និង PI-16។ ទន្ទឹមនេះ សូចនាករពាក់ព័ន្ធដៃគូអភិវឌ្ឍន៍ចាប់ពីD1-D3 គឺមិនត្រូវបានធ្វើការវាយតម្លៃ ដែលស្ថិតនៅក្រៅវិសាលភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៕■

## តារាងបម្រែបម្រួលលើលទ្ធផល/សមិទ្ធកម្មឆ្នាំ២០១៧ ធៀបនឹងការវាយតម្លៃឆ្នាំ២០១៥

| *សូចនាករសមិទ្ធកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ* | | វិធីសាស្ត្រដាក់ពិន្ទុ | ២០១៥ | ២០១៧ | ពិន្ទុអាចប្រៀបធៀបបាន | បម្រែបម្រួល |
|---|---|---|---|---|---|---|
| A. *លទ្ធផលនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ÷ភាពជឿទុកចិត្តនៃថវិកា* | | | | | | |
| PI-1 | ចំណាយសរុបធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | M1 | A | A | បាន | គ្មាន |
| PI-2 | សមាសធាតុចំណាយធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | M1 | D+ | B | បាន | ↑ |
| PI-3 | ចំណូលសរុបធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | M1 | A | B | បាន | ↓ |
| PI-4 | សន្និធិបំណុលកកស្ទះ និងការតាមដានបំណុលកកស្ទះ | M1 | D+ | C+ | បាន | ↑ |
| B. *ការងារគ្រួតស៊ីគ្នាសំខាន់ៗ÷ភាពគ្រប់ជ្រុងជ្រោយ និងតម្លាភាពនៃថវិកា* | | | | | | |
| PI-5 | ចំណាត់ថ្នាក់ថវិកា | M1 | C | C | បាន | គ្មាន |
| PI-6 | ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មានដែលត្រូវបានបញ្ចូលនៅក្នុងឯកសារថវិកា | M1 | C | C | បាន | គ្មាន |
| PI-7 | ទំហំនៃប្រតិបត្តិការរបស់រដ្ឋាភិបាលដែលមិនត្រូវបានរាយការណ៍ | M1 | C | C+ | បាន | ↑ |
| PI-8 | តម្លាភាពនៃទំនាក់ទំនងហិរញ្ញវត្ថុនៅគ្រប់ថ្នាក់នៃរដ្ឋបាល | M2 | B | B | បាន | គ្មាន |
| PI-9 | ការត្រួតពិនិត្យហានិភ័យថវិកាពីអង្គភាពសាធារណៈដទៃទៀតក្រៅពីក្រសួង-ស្ថាប័នរដ្ឋ | M1 | C+ | B+ | បាន | ↑ |
| PI-10 | លទ្ធភាពរបស់សាធារណជនក្នុងការទទួលបានព័ត៌មានថវិកាសំខាន់ៗ | M1 | D | B | បាន | ↑ |
| C. *វដ្តថវិកា* | | | | | | |
| C(i) *ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ* | | | | | | |
| PI-11 | កាលានុក្រម និងការចូលរួមក្នុងកិច្ចដំណើរការរៀបចំថវិកាប្រចាំឆ្នាំ | M2 | A | A | បាន | គ្មាន |
| PI-12 | ទស្សនវិស័យច្រើនឆ្នាំក្នុងការធ្វើផែនការថវិកា, គោលនយោបាយចំណាយ និងការរៀបចំថវិកា | M2 | C+ | C+ | បាន | គ្មាន |
| C(ii) *ភាពអាចប៉ាន់ប្រមាណបាន និងការត្រួតពិនិត្យការអនុវត្តថវិកា* | | | | | | |
| PI-13 | តម្លាភាពនៃកាតព្វកិច្ចជាប់ពន្ធ និងបំណុលពន្ធរបស់អ្នកជាប់ពន្ធ | M2 | C+ | B | បាន | ↑ |
| PI-14 | ប្រសិទ្ធភាពនៃវិធានការសម្រាប់ចុះបញ្ជីអ្នកជាប់ពន្ធ និងការវាយ-តម្លៃពន្ធ | M2 | D+ | C | បាន | ↑ |
| PI-15 | ប្រសិទ្ធភាពនៃការប្រមូលពន្ធ | M1 | D+ | D+ | បាន | គ្មាន |
| PI-16 | ភាពអាចប៉ាន់ប្រមាណបាននូវអត្ថិភាពថវិកាសម្រាប់ធានាចំណាយ | M1 | C+ | C | បាន | ↓ |
| PI-17 | ការកត់ត្រា និងការគ្រប់គ្រងសមតុល្យសាច់ប្រាក់, បំណុល និងការធានា | M2 | C+ | C+ | បាន | គ្មាន |
| PI-18 | ប្រសិទ្ធភាពនៃការត្រួតពិនិត្យបញ្ជីប្រាក់បៀវត្ស | M1 | D+ | C+ | បាន | ↑ |

| *សូចនាករសមិទ្ធកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ* | | វិធីសាស្ត្រដាក់ពិន្ទុ | ២០១៥ | ២០១៧ | ពិន្ទុអាចប្រៀបធៀបបាន | បម្រែបម្រួល |
|---|---|---|---|---|---|---|
| PI-19 | តម្លាភាព ការប្រកួតប្រជែង និងយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងកិច្ចលទ្ធកម្ម | M2 | D+ | C | បាន | ⬆ |
| PI-20 | ប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងទៅលើចំណាយមិនមែនបៀវត្ស | M1 | C | C | បាន | គ្មាន |
| PI-21 | ប្រសិទ្ធភាពនៃសវនកម្មផ្ទៃក្នុង | M1 | C | C | បាន | គ្មាន |
| C(iii) *គណនេយ្យ, ការកត់ត្រា និងរបាយការណ៍* | | | | | | |
| PI-22 | ភាពទាន់ពេល និងភាពទៀងទាត់នៃការផ្ទៀងផ្ទាត់គណនី | M2 | C | C | បាន | គ្មាន |
| PI-23 | អត្ថិភាពនៃព័ត៌មានស្តីពីធនធានដែលទទួលបានពីអង្គភាពផ្តល់សេវា | M1 | D | D | បាន | គ្មាន |
| PI-24 | គុណភាព និងភាពទាន់ពេលនៃរបាយការណ៍ថវិកាក្នុងឆ្នាំ | M1 | C+ | C+ | បាន | គ្មាន |
| PI-25 | គុណភាព និងភាពទាន់ពេលវេលានៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ | M1 | D+ | D+ | បាន | គ្មាន |
| C(iv) *ការត្រួតពិនិត្យ និងសវនកម្មផ្ទៃក្រៅ* | | | | | | |
| PI-26 | វិសាលភាព/ ចរិតលក្ខណៈ និងការតាមដានបន្តនៃសវនកម្មផ្ទៃក្រៅ | M1 | NR | D+ | មិនបាន | - |
| PI-27 | ការត្រួតពិនិត្យលើច្បាប់ថវិកាប្រចាំឆ្នាំដោយអង្គនីតិបញ្ញត្តិ | M1 | C+ | C+ | បាន | គ្មាន |
| PI-28 | ការត្រួតពិនិត្យលើរបាយការណ៍សវនកម្មផ្ទៃក្រៅដោយអង្គនីតិ-បញ្ញត្តិ | M1 | B | B | បាន | គ្មាន |
| D. *ការអនុវត្តរបស់ដៃគូអភិវឌ្ឍន៍( ផ្នែកនេះ គឺមិនត្រូវបានធ្វើការវាយតម្លៃដោយមិនពាក់ព័ន្ធដោយផ្ទាល់សម្រាប់ប្រព័ន្ធ*PFM) | | | | | | |
| D-1 | ការប៉ាន់ប្រមាណនៃការគាំទ្រថវិកាដោយផ្ទាល់ | M1 | D | NA | មិនបាន | - |
| D-2 | ព័ត៌មានហិរញ្ញវត្ថុដែលត្រូវបានផ្តល់ដោយដៃគូអភិវឌ្ឍន៍សម្រាប់ការរៀបចំថវិកា និងការរាយការណ៍ពីហិរញ្ញប្បទានសម្រាប់គម្រោង និងកម្មវិធី | M1 | D+ | NA | មិនបាន | - |
| D-3 | ទំហំនៃហិរញ្ញប្បទានដែលត្រូវបានគ្រប់គ្រងតាមនីតិវិធីជាតិ | M1 | D | NA | មិនបាន | - |

# សមិទ្ធផល និងទិសដៅ ៥ ឆ្នាំ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

*កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) គឺជាកម្មវិធីកែទម្រង់ស្នូលមួយនៃកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីពង្រឹងអភិបាលកិច្ច និងទ្រទ្រង់ការអភិវឌ្ឍសេដ្ឋកិច្ច ប្រកបដោយបរិយាប័ន្ន និងសមធម៌ដូចបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។*

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានគោលដៅកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅកាន់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលផ្តោតលើលទ្ធផល និងវិមជ្ឈការស្របតាមស្តង់ដារអន្តរជាតិ។

សមិទ្ធផលរយៈពេល ៥ឆ្នាំ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បង្ហាញនូវសមិទ្ធផលរបស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភាក្នុងការខិតខំអនុវត្ត ព្រមទាំងកំណត់នូវបញ្ហាប្រឈម និងទិសដៅបន្តរយៈពេល ៥ ឆ្នាំ សម្រាប់រាជរដ្ឋាភិបាល នីតិកាលទី៦នៃរដ្ឋសភា និងឆ្លុះបញ្ចាំងនូវសមាសធាតុគន្លឹះទាំង៤ដែលបាននិងកំពុងរៀបចំ និងពង្រឹងការអនុវត្តរួមមាន÷ការរៀបចំប្រព័ន្ធ, ការរៀបចំក្របខ័ណ្ឌគតិយុត្ត, ការរៀបចំយន្តការ និងការកសាងធនធានមនុស្សលើវិស័យហិរញ្ញវត្ថុសាធារណៈ។ ទន្ទឹមនឹងនេះ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានសុទិដ្ឋិនិយម និងវាយតម្លៃសមិទ្ធផលសម្រេចបានរយៈពេល ៥ ឆ្នាំជារួមថា÷ (១).ភាពជឿទុកចិត្តនៃថវិកានៅតែរក្សាបានជាសារវន្ត, (២).ប្រព័ន្ធគណនេយ្យភាពបាននិងកំពុងកសាងតាមរយៈការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS ដំណាក់កាលទី២ ជាមួយនឹងភាពប្រុងប្រយ័ត្នខ្ពស់, (៣).ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធីជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំ និងកំណត់ការផ្លាស់ប្តូរប្រព័ន្ធថវិកាកម្ពុជា, (៤).ការរៀបចំនិងដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ ជាសមាសធាតុដ៏សំខាន់សម្រាប់កំណត់ទិសដៅនៃគណនេយ្យភាពសមិទ្ធកម្ម និង(៥).ការរៀបចំប្រព័ន្ធលើកទឹកចិត្តនឹងជំរុញការធ្វើស្ថាប័ននីយកម្មឱ្យស្របតាមទិសដៅនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

បន្ថែមពីនេះ ក្នុងក្របខ័ណ្ឌសេដ្ឋកិច្ច រាជរដ្ឋាភិបាលសម្រេចបានកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំក្នុងរង្វង់ ៧% ព្រមទាំងសម្រេចបាននូវបង្គោលចរជាប្រវត្តិសាស្ត្រ គឺការឆ្លងពីប្រទេសមានចំណូលមធ្យមកម្រិតទាបជាផ្លូវការនៅឆ្នាំ២០១៥ និងត្រូវបានប្រសិទ្ធនាមថាជា “**ខ្លាសេដ្ឋកិច្ចនៅអាស៊ី**” នៅឆ្នាំ២០១៦។ រីឯភាពគ្មានការងារធ្វើស្ថិតក្នុងអត្រា ០,៣%, ភាពក្រីក្រតោកយ៉ាកត្រូវបានលុបបំបាត់ចោលទាំងស្រុងក្នុងឆ្នាំ ២០១៧ និងប្រាក់ចំណូលក្នុងមនុស្សម្នាក់កើនពី១ ០៤២ ដុល្លារអាមេរិកក្នុងឆ្នាំ២០១៣ ដល់ប្រមាណ១ ៤២៧ ដុល្លារអាមេរិកក្នុងឆ្នាំ២០១៧។

ចំណែកឯក្នុងក្របខ័ណ្ឌកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការប្រមូលចំណូលនៅតែមានភាពរឹងមាំ ដែលចំណូលមានការកើនឡើងក្នុងចន្លោះ ១៥%-២០% ក្នុងមួយឆ្នាំសម្រាប់រយៈពេល៥ឆ្នាំចុងក្រោយ ហើយចំណូលចរន្តថវិកាជាតិបានកើនឡើងពីប្រមាណ១៥,០៦% នៃ ផ. ស. ស. ក្នុងឆ្នាំ ២០១៣ ដល់១៩,៦៤% ក្នុងឆ្នាំ ២០១៧។ រីឯថវិកាចំណាយ បានកើនឡើងប្រមាណ ១,៨ ដង ហើយការវិភាជថវិកាត្រូវបានគិតគូរលើវិស័យអាទិភាពសំខាន់ៗ និងការអនុវត្តថវិកាផ្នែកចំណាយក៏កាន់តែមានប្រសិទ្ធភាព ទាំងកម្រិតវិភាជន៍ និងកម្រិតប្រតិបត្តិការ។

*សមាសធាតុ៤ ដែលបានកំពុងរៀបចំ និងពង្រឹងការអនុវត្ត រួមមាន÷ ការរៀបចំប្រព័ន្ធ, ការរៀបចំក្របខ័ណ្ឌគតិយុត្ត, ការរៀបចំយន្តការ និងការកសាងធនធានមនុស្សលើវិស័យហិរញ្ញវត្ថុសាធារណៈ។*

## សមិទ្ធផលសម្រេចបានក្នុងរយៈពេល ៥ ឆ្នាំ

សមិទ្ធផលរយៈពេល ៥ ឆ្នាំ ត្រូវបានបង្ហាញក្នុងទិដ្ឋភាពចំនួន២ លើទិដ្ឋភាពទូទៅនៃ PFMRP ទាំងភាពខ្លាំង និងភាពខ្សោយនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដោយប្រើប្រាស់នូវក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) ឆ្នាំ២០១១ ដូចដ្យាក្រាមសង្ខេបជូនខាងក្រោមនេះ÷



















ទន្ទឹមនឹងនេះ លទ្ធផលវាយតម្លៃ PEFA ឆ្នាំ២០១៧ ឆ្លុះបញ្ចាំងថា ប្រព័ន្ធ PFM គឺមានភាពប្រសើរជាងមុន លើប្រសិទ្ធភាពនៃការអនុវត្តថវិកា, ការពង្រឹងរដ្ឋបាលប្រមូលចំណូល, តម្លាភាពថវិកា និងលទ្ធកម្មសាធារណៈ និងប្រសិទ្ធភាពនៃការគ្រប់គ្រងបៀវត្សរ៍៕■

# ទិសដៅរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- បូរណភាពនៃការគោរពវិន័យថវិកា
- ប្រសិទ្ធភាពនៃថវិកា ទាំងក្នុងផ្នែកវិភាជន៍, ទាំងក្នុងផ្នែកប្រតិបត្តិការ
- ស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ

## ទិសដៅនៃ PFMRP សម្រាប់ក្រសួង ស្ថាប័ន

ជាទិសដៅសម្រាប់ការចូលរួមការអនុវត្ត PFMRP ក្នុងឆ្នាំ២០១៨-២០២២ ក្រសួង- ស្ថាប័ន គួរផ្តោតលើសកម្មភាពអាទិភាព ដូចខាងក្រោម÷

**ហិរញ្ញវត្ថុសាធារណៈ**

- ប្រសិទ្ធភាពការប្រមូលចំណូល និងចំណាយ
- តម្លាភាពលទ្ធកម្មសាធារណៈ
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- សវនកម្ម និងអធិការកិច្ច

**ថវិកាកម្មវិធី**

- ផែនការយុទ្ធសាស្រ្តថវិកា
- កែលម្អរចនាសម្ព័ន្ធស្ថាប័ន និងអង្គភាពថវិកា
- ត្រួតពិនិត្យការអនុវត្តថវិកា
- ការអនុវត្តប្រព័ន្ធ FMIS និងកសាងសមត្ថភាព

# ទិសដៅនៃ PFMRP សម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- រៀបចំក្របខ័ណ្ឌគោលនយោបាយពន្ធរយៈពេលមធ្យមឆ្នាំ២០១៩-២០២៣
- អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥
- ពង្រឹង និងពង្រីកការអនុវត្តប្រព័ន្ធ FMIS ស្របតាមផែនការយុទ្ធសាស្ត្រដំណាក់កាលទី២
- រៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យម (MTFF) និងក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF)
- ធ្វើវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ ដើម្បីឱ្យស្របតាមបរិបទប្រព័ន្ធថវិកាថ្មី
- បញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- រៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិឆ្នាំ២០១៨-២០២៥
- រៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥
- រៀបចំក្របខ័ណ្ឌវិនិយោគសាធារណៈ និងភាពជាដៃគូរវាងរដ្ឋ និងឯកជន
- រៀបចំផែនទីចង្អុលបង្ហាញផ្លូវគណនេយ្យបង្គរ
- រៀបចំមគ្គុទេសក៍គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាល
- រៀបចំមូលនិធិនៃ PFMRP គ្រប់ជ្រុងជ្រោយ និងកសាងសមត្ថភាពធនធានមនុស្សលើវិស័យហិរញ្ញវត្ថុសាធារណៈ

# ថវិកាសង្ខេបឆ្នាំ២០១៨ របស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

*កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានគោលដៅកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅកាន់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលផ្តោតលើលទ្ធផល និងវិមជ្ឈការស្របតាមស្តង់ដារអន្តរជាតិ។*

នាពេលបច្ចុប្បន្ននេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានឈានមកដល់ដំណាក់កាលទី៣ “ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ” ចាប់ពីឆ្នាំ២០១៦ ស្របពេលដែលរាជរដ្ឋាភិបាលកំពុងជំរុញល្បឿននៃការងារកែទម្រង់លើគ្រប់វិស័យ។ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(**អ.គ.ហ.**) ក្នុងនាមជាសេនាធិការរបស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(**គ.ហ.ស**) បានរៀបចំថវិកាប្រចាំឆ្នាំដើម្បីគាំទ្រដល់ការអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី៣ ជូនអង្គភាពទាំងអស់ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

*ថវិកាឆ្នាំ២០១៨ មានការកើនឡើង៣៥% បើធៀបនឹងថវិកាឆ្នាំ២០១៧ ដោយសារមានការពង្រីកការប្រើប្រាស់ប្រព័ន្ធ FMIS*

### ផែនការថវិកាឆ្នាំ២០១៨ របស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:

ថវិកាឆ្នាំ២០១៨ របស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានផ្តល់អាទិភាពទៅលើ ៤ ចំណុចរួមមាន÷

- ការពង្រឹងការគ្រប់គ្រងការប្រមូលចំណូល,
- ការដាក់ឱ្យអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ,
- ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី
- ទិសដៅកែទម្រង់ប្រព័ន្ធថវិការបស់រាជរដ្ឋាភិបាលកម្ពុជា។

លើសពីនេះ ថវិកាឆ្នាំ២០១៨ ត្រូវបានរៀបចំដោយអនុលោមទៅតាមសកម្មភាពដែលស្ថិតក្រោមផែនការសកម្មភាពរួមដំណាក់កាលទី៣ និងសូចនាករសមិទ្ធកម្មគន្លឹះដែលបានព្រមព្រៀងជាមួយដៃគូអភិវឌ្ឍន៍ក្រោមប្រភពថវិកាបដិភាគរបស់រាជរដ្ឋាភិបាល, ថវិកាទ្រទ្រង់ហិរញ្ញប្បទានដោយសហភាពអឺរ៉ុប, ជំនួយជាឥណទានសម្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី និងថវិកាពីអង្គការយូនីសេហ្វ។ ថវិកាឆ្នាំ២០១៨ មានការកើនឡើង៣៥% បើធៀបនឹងថវិកាឆ្នាំ២០១៧ ដោយសារមានការពង្រីកការប្រើប្រាស់ប្រព័ន្ធ FMIS ជូនក្រសួង-ស្ថាប័ន៕■

## ក១. ផែនការថវិកាឆ្នាំ២០១៨ និងភាគរយតាមប្រភេទចំណាយ

| ប្រភេទចំណាយ | សរុប | % |
|---|---|---|
| សិក្ខាសាលា | ១៦,២១៤ | ៣២% |
| ទីប្រឹក្សា | ៩,៩៣៧ | ១៩% |
| ទំនិញ (កសាងប្រព័ន្ធ) | ២៣,៣៩៤ | ៤៦% |
| ប្រតិបត្តិការ | ១,៥១០ | ៣% |
| សរុប *(គិតជាលានរៀល)* | ៥១,០៥៥ | ១០០.% |



## ...ការប្រៀបធៀបផែនការថវិកាឆ្នាំ២០១៨និងឆ្នាំ២០១៧

| ប្រភេទចំណាយ | ២០១៨ | ២០១៧ |
|---|---|---|
| សិក្ខាសាលា | ១៦,២១៤ | ១៤,១៣៧ |
| ទីប្រឹក្សា | ៩,៩៣៧ | ៥,៣៧៣ |
| ទំនិញ (កសាងប្រព័ន្ធ) | ២៣,៣៩៤ | ១៧,៦៦២ |
| ប្រតិបត្តិការ | ១,៥១០ | ៦៣៩ |
| **សរុប** *(គិតជាលានរៀល)* | ៥១,០៥៥ | ៣៧,៨១១ |







## គ. ប្រភេទចំណាយតាមអង្គភាពអនុវត្តគម្រោងក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:







## ...អង្គភាពអនុវត្តគម្រោង ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រង...វត្ថុសាធារណៈ:

| ...អង្គភាពអនុវត្តគម្រោង | ២០១៨ | % |
|---|---|---|
| ...ងារគ្រប់គ្រងគម្រោង FMIS | ២៧,៤៩៩ | ៥៤% |
| ...ក្រោម ឱវាទ កសហវ. | ១៨,៩២៦ | ៣៧% |
| ...ស្ថាប័ន | ៤,៦៣០ | ៩% |
| **សរុប** *(គិតជាលានរៀល)* | ៥១,០៥៥ | ១០០.% |







*សម្គាល់ ÷ *ចំពោះក្រសួង-ស្ថាប័នចំនួន ៦ដែលពុំទាន់មានតម្រូវការថវិកា÷ (១). គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត, (២). ទីស្តីការគណៈរដ្ឋមន្ត្រី, (៣). សាលាឧទ្ធរណ៍,(៤). តុលាការកំពូល ,(៥). ក្រសួងព្រះបរមរាជវាំង និង (៦). ក្រសួងយុត្តិធម៌ ។*

## ...ពហិរញ្ញវត្ថុទ្រទ្រង់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ...ណៈ:

| ប្រភពហិរញ្ញវត្ថុ | ២០១៨ | % |
|---|---|---|
| ...ការ បដិភាគរបស់រាជរដ្ឋាភិបាល | ២៤,៦៨២ | ៤៨% |
| ...កាទ្រទ្រង់ហិរញ្ញប្បទាន ដោយសហភាពអឺរ៉ុប | ២២,៣២០ | ៤៤% |
| ...ណទាន សម្បទាន ពីធនាគារ អភិវឌ្ឍន៍អាស៊ី | ៣,៦៥៣ | ៧% |
| ...គូអភិវឌ្ឍន៍ដទៃទៀត | ៤០០ | ១% |
| **សរុប** *(គិតជាលានរៀល)* | ៥១,០៥៥ | ១០០.% |



យុទ្ធសាស្ត្រ និង
គោលនយោបាយ
ច្បាស់លាស់



ឆន្ទៈ និងភាពជាអ្នកដឹកនាំ






ប្រសិទ្ធភាពនៃការចូលរួម
ប្រកបដោយបរិយាប័ន្ន






ប្រសិទ្ធភាពនៃកម្មវិធី
កែទម្រង់ការគ្រប់គ្រង
ហិរញ្ញវត្ថុសាធារណៈ

ការអភិវឌ្ឍ និងកំណើន
ប្រកបដោយចីរភាព



ប្រសិទ្ធភាពនៃការរៀបចំ
និងការអនុវត្ត



ការផ្សព្វផ្សាយ និងតម្លាភាព

# ផ្នែកទី ៣ ៖ ទស្សនៈ និងមតិ



ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់
ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

*"ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺមិនមែនគ្រាន់តែត្រូវផ្តោតលើការប្រមូលចំណូលដើម្បីបំពេញបង្គ្រប់សេចក្តីត្រូវការចំណាយប៉ុណ្ណោះទេ ប៉ុន្តែគឺជាការគ្រប់គ្រង និងការបែងចែកប្រកបដោយប្រសិទ្ធភាព នូវធនធានកម្ររបស់ជាតិ ដើម្បីបម្រើឱ្យការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ច។ ក្នុងន័យនេះ រដ្ឋត្រូវថ្លឹងថ្លែងប្រមូលចំណូល (ដោយដាក់បន្ទុកពន្ធ) នៅក្នុងកម្រិតដែលសេដ្ឋកិច្ចអាចទ្រទ្រង់បាន ដើម្បីបង្កើតបរិយាកាសអនុគ្រោះសម្រាប់ការវិនិយោគ និងសកម្មភាពធុរកិច្ច ហើយទន្ទឹមនេះ ក៏គិតគូរអំពីសមធម៌សង្គម និងការជំរុញកំណើនសេដ្ឋកិច្ចផងដែរ តាមរយៈការសម្រាលបន្ទុកពន្ធដល់ប្រជាពលរដ្ឋដែលមានចំណូលទាបផង និងការវិភាជចំណាយប្រកបដោយវិចារណភាព សំដៅទ្រទ្រង់កំណើនសេដ្ឋកិច្ច ដោយធានាឱ្យបាននូវចីរភាពនៃថវិកាជាតិផង៕"*

*"ក្នុងការសម្រេចបាន និងធានាបាននូវលទ្ធផលដែលកើតចេញពីការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវការងារកែទម្រង់ និងគោលបំណងគោលនយោបាយផ្សេងៗ, កិច្ចខិតខំប្រឹងប្រែង និងការចូលរួមពីរដ្ឋាភិបាល និងភាគីពាក់ព័ន្ធគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់។ ប៉ុន្តែ ដោយតម្រូវការគ្មានដែនកំណត់ទន្ទឹមនឹងកង្វះខាតធនធាន, ដំណើរការនៃការអនុវត្តចាំបាច់ត្រូវមានប្រសិទ្ធភាព និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។ ហេតុផលនេះហើយ ដែលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានផ្តួចផ្តើមឡើងដើម្បីដើរតួនាទីដ៏សំខាន់មួយនេះ៕"*



លោកជំទាវ **ខួន សុខា** រដ្ឋលេខាធិការ
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ឯកឧត្តម **រស់ សីលវ៉ា** អគ្គលេខាធិការ
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់
ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

*“ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទទួលបានជោគជ័យនៅពេលដែលលែងមានអគ្គលេខាធិការដ្ឋានកែទម្រង់ ដោយការងារនេះត្រូវបានច្របាច់ចូល និងប្រែក្លាយជាការងារស្នូលរបស់អគ្គនាយកដ្ឋាន និងក្រសួង/ស្ថាប័ន នីមួយៗ រៀងៗខ្លួន។ នៅក្នុងរយៈពេលអន្តរកាលនេះ អគ្គលេខាធិការដ្ឋានកែទម្រង់នឹងខិតខំសម្របសម្រួល និងតាមដានការអនុវត្តការងារកែទម្រង់ស្របតាមទិសដៅដែលបានដាក់ចេញដោយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៕"*



លោកស្រី Ellen Goldstein, នាយកធនាគារពិភពលោក
ប្រចាំប្រទេសកម្ពុជា មីយ៉ាន់ម៉ា និងឡាវ

*"ភាពប្រសើរឡើងនៃសេវាសាធារណៈដែលរួមបញ្ចូលទាំងសុខុមាលភាពមូលដ្ឋាន ការអប់រំ និងសេវាមូលដ្ឋានផ្សេងទៀត នឹងមានសារៈសំខាន់សម្រាប់កាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ រាជរដ្ឋាភិបាល បាននិងកំពុងគាំទ្រព្រមទាំងបង្កើនថវិកាដើម្បីពង្រីក និងកែលម្អការផ្តល់សេវាសាធារណៈសម្រាប់ប្រជាពលរដ្ឋ។ សារៈសំខាន់នៃ PFM ក្នុងការផ្តល់សេវាសាធារណៈគឺដូចជាសារៈសំខាន់នៃទឹកចំពោះកសិករអញ្ចឹងដែរ។ PFM ចាំបាច់ត្រូវមានប្រសិទ្ធភាពដើម្បីសម្រួលដល់ការផ្តល់សេវាសាធារណៈ។ ជាឧទាហរណ៍ មានធនធានគ្រប់គ្រាន់, លំហូរនៃតម្រូវការមូលនិធិទៅកាន់អ្នកផ្តល់សេវាសាធារណៈផ្ទាល់ មានលក្ខណៈទាន់ពេល, ហើយអ្នកគ្រប់គ្រងថវិកាអាចអនុវត្តថវិកាប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាពដើម្បីធានាប្រសិទ្ធភាពនៅក្នុងការផ្តល់សេវាសាធារណៈ៕"*

*"ដោយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈអនុញ្ញាតឱ្យធ្វើវិមជ្ឈការបន្ថែមទៀតលើការគ្រប់គ្រងហិរញ្ញវត្ថុ, ការកសាងសមត្ថភាពគឺរឹតតែមានសារៈសំខាន់ដើម្បីធានាថាមន្ត្រីពាក់ព័ន្ធមានជំនាញត្រឹមត្រូវ និងធ្វើការងារចំកន្លែង។ ដៃគូអភិវឌ្ឍន៍សូមអបអរសាទរក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់ការអនុម័តលើផែនការយុទ្ធសាស្ត្រស្តីពីការកសាង និងអភិវឌ្ឍសមត្ថភាព និងសូមជំរុញក្រសួង-ស្ថាប័ន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពង្រឹងប្រព័ន្ធគណនេយ្យភាព និងសមិទ្ធកម្ម ដោយផ្សារភ្ជាប់កំណើនបៀវត្សរ៍ជាមួយនឹងភាពប្រសើរឡើងនៃសមិទ្ធកម្ម និងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ៕"*



លោក FRANK VIAULT ប្រធានផ្នែកសហប្រតិបត្តិការ
នៃស្ថានតំណាងសហភាពអឺរ៉ុបប្រចាំកម្ពុជា



លោក Wansup Kim សហប្រធាននៃគណៈកម្មាធិការ PEMNA
និងជាអគ្គនាយកគ្រប់គ្រងសមិទ្ធកម្មសារពើពន្ធ ក្រសួងយុទ្ធសាស្ត្រ
និងហិរញ្ញវត្ថុ ប្រទេសកូរ៉េ

*"ខណៈពេលដែលបណ្តាញគ្រប់គ្រងចំណាយសាធារណៈ ប្រចាំអាស៊ី (PEMNA) មានការរីកចម្រើនគួរឱ្យកត់សម្គាល់, បណ្តាញនេះបានក្លាយទៅជាបណ្តាញដ៏រឹងមាំ និងជាវេទិកាគាំទ្រដល់ភាពជាដៃគូក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) នៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក។ ជាឧទាហរណ៍ អ្នកជំនាញ PFM អាចបង្វែរកិច្ចពិភាក្សារបស់យើង ទៅជារបាយការណ៍វិភាគគោលនយោបាយដែលរួមមានអនុសាសន៍ និងការណែនាំ។ នៅពេលយើងចូលរួមជាមួយគ្នាដោយចែករំលែកបទពិសោធ ក៏ដូចជាឧត្តមានុវត្តន៍នានា យើងនឹងអាចទទួលបានឥទ្ធិពលជាវិជ្ជមានដល់បរិការណ៍នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់យើងរៀងៗខ្លួនផងដែរ៕"*

# អគ្គលេខាធិការដ្ឋានគណៈកម្មាធិការ
# ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## គណៈគ្រប់គ្រង ៖

| | |
|---|---|
| រស់ សីលវ៉ា | អគ្គលេខាធិការ **អ.គ.ហ.** |
| បណ្ឌិត ហ៊ែល ចំរើន | អគ្គលេខាធិការរង **អ.គ.ហ.** |
| មាស សុខសេនសាន | អគ្គលេខាធិការរង **អ.គ.ហ.** |
| ប៉ែន ធីរុង្គ | អគ្គលេខាធិការរង **អ.គ.ហ.** |
| ប៊ូ វង្សសុខា | អគ្គលេខាធិការរង **អ.គ.ហ.** |
| អ៊ុង លុយណា | អគ្គលេខាធិការរង **អ.គ.ហ.** |
| យ៉េត វីណែល | អគ្គលេខាធិការរង **អ.គ.ហ.** |

## រៀបចំអត្ថបទដោយ ៖

ផ្នែកការងារកែទម្រង់ទាំង៣, គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ

| | |
|---|---|
| លី វ៉ុង | មន្ត្រីជំនាញជាន់ខ្ពស់ |
| វុទ្ធី សត្រា | មន្ត្រីជំនាញ |

ផ្នែកនវានុវត្តន៍ ផ្សព្វផ្សាយ និងកសាងសមត្ថភាព

| | |
|---|---|
| សុគន្ធ ចរិយា | មន្ត្រីជំនាញជាន់ខ្ពស់ |
| ឈុន ម៉ារឌី | មន្ត្រីជំនាញ |
| លី ពង្សរតនា | មន្ត្រីជំនាញ |

ផ្នែកអនុវត្តថវិកា

| | |
|---|---|
| ប៉ុម លៃហេង | មន្ត្រីជំនាញជាន់ខ្ពស់ |
| លឹម សុខហេង | ជំនួយការ |

ផ្នែកចំណូលសារពើពន្ធ

| | |
|---|---|
| អ៊ុង មករា | មន្ត្រីជំនាញ |
| រស់ ដាលីន | ជំនួយការ |

ផ្នែកគោលនយោបាយ និងរៀបចំថវិកា

| | |
|---|---|
| ម៉េត វ៉ាម៉ន | ជំនួយការ |
| ផែង សុខម៉ៃ | ជំនួយការ |

ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ

| | |
|---|---|
| អ៊ុំ យុទ្ធី | ប្រធានផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ |
| អ៊ូច សោភ័ណ | មន្ត្រីត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| យន ម៉ាលីមឆេង | មន្ត្រីថវិកា |
| លឿង សុវណ្ណឌី | ជំនួយការមន្ត្រីថវិកា |

ការចូលរួមផ្សេងៗ

ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ

ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃអគ្គនាយកដ្ឋានពន្ធដារ

## នវានុវត្ត និងកែសម្រួលដោយ ៖

ផ្នែកនវានុវត្តន៍ ផ្សព្វផ្សាយ និងកសាងសមត្ថភាព

| | |
|---|---|
| សុគន្ធ ចរិយា | មន្ត្រីជំនាញជាន់ខ្ពស់ |
| ឈុន ម៉ារឌី | មន្ត្រីជំនាញ |
| លី ពង្សរតនា | មន្ត្រីជំនាញ |

អាសយដ្ឋានទំនាក់ទំនង÷
ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (៨៥៥) ៨៥ ៧៧៧ ៩២០
admin@pfm.gov.kh
www.pfm.gov.kh
www.facebook.com/gscpfm